# ពាក្យខុស ពាក្យត្រូវ ខ្មែរ



អក្សរសាស្ត្ររលត់ ជាតិរលាយ អក្សរសាស្ត្រពណ្ណរាយ ជាតិថ្កើងថ្កាន

ចងក្រងដោយ ខន ស៊ីងហោ

ព.ស. ២៥៦៨ គ.ស. ២០២៥

ចងក្រងដោយ ខន ស៊ីងហោ ពាក្យខុស ពាក្យត្រូវខ្មែរ ព.ស. ២៥៦៨ គ.ស. ២០២៥

# ពាក្យខុស ពាក្យត្រូវខ្មែរ

អក្សរសាស្ត្ររលត់ ជាតិរលាយ អក្សរសាស្ត្រពណ្ណរាយ ជាតិថ្កើងថ្កាន

ចងក្រងដោយ

**ខន ស៊ាងហោ**

ពុទ្ធសករាជ ២៥៦៨ គ្រិស្តសករាជ ២០២៥

# ពាក្យខុស ពាក្យត្រូវខ្មែរ

អក្សរសាស្ត្ររលត់ ជាតិរលាយ អក្សរសាស្ត្រពណ្ណរាយ ជាតិថ្កើងថ្កាន

ចងក្រងដោយ : ខន ស៊ាងហោ

ត្រួតពិនិត្យនិងកែសម្រួល: កិ សុខា, ហេង ហុង

រចនាគម្រប : វ៉ុន វណ្ណា

លេខ ISBN- 13 : 9 789924 -9738-29

បោះពុម្ពលើកទី១

ខ្នាត១២.៥ x ១៧.៦ សង់ទីម៉ែត្រ កម្រាស់ ៣៦៤ ទំព័រ

អាសយដ្ឋាន ៖ ភូមិតំបែរ ឃុំតំបែរ ស្រុកតំបែរ ខេត្តត្បូងឃ្មុំ

លេខទូរសព្ទ : 097 9 468 504

ហ្វេសប៊ុក : ខន ស៊ាងហោ

សារអេឡិចត្រូនិក : seanghor.khorn@gmail.com

© រក្សាសិទ្ធិគ្រប់យ៉ាង

# អារម្ភបទ

តាមរយៈការបង្រៀនបន្ថែមមុខវិជ្ជាសីលធម៌ ខ្ញុំបាទបានកត់សម្គាល់ឃើញមានការសរសេរខុសអក្ខរាវិរុទ្ធជាច្រើនលើសន្លឹកកិច្ចការប្រឡងរបស់សិស្សានុសិស្ស។ ខ្ញុំតែងកត់ចម្លងចូលក្នុងសៀវភៅរបស់ខ្ញុំដើម្បីយកទៅកែតម្រូវកំហុសលើក្ដារខៀនរួមគ្នាតាមថ្នាក់នីមួយៗ។ ពេលយើងធ្លាប់ឃើញពាក្យសរសេរត្រូវ យើងអាចនឹងពិបាកនឹករកថាពាក្យសរសេរខុសបែបណា។ ទន្ទឹមនឹងនោះខ្ញុំក៏បានលួចកែតម្រូវពាក្យដែលខ្លួនខ្ញុំសរសេរខុសពីការសរសេរត្រូវរបស់សិស្សដែរ។ ខ្ញុំក៏បានកត់សម្គាល់ឃើញការសរសេរភាសាខ្មែរខុសក្នុងបណ្ដាញសង្គម តួយ៉ាងហ្វេសប៊ុកជាដើម។ ជាពិសេសតាមរយៈបទពិសោធផ្ទាល់ខ្លួនរបស់ខ្ញុំដែលធ្លាប់បានជួយកែកំហុសអក្ខរាវិរុទ្ធសៀវភៅមួយចំនួនមុនការបោះពុម្ព នាំឱ្យខ្ញុំបានចម្លងទុកពាក្យទាំងឡាយណាដែលគេភាន់ច្រឡំសរសេរខុស។ ខ្ញុំខ្លួនឯងក៏ឧស្សាហ៍សរសេរខុសដែរ តែខ្ញុំតែងព្យាយាមត្រួតពិនិត្យផ្ទៀងផ្ទាត់អក្ខរាវិរុទ្ធក្នុងវចនានុក្រម។ មួយចំនួន

ទៀត ខ្ញុំបានកត់សម្គាល់ឃើញពាក្យខុស ពាក្យត្រូវតាមរយៈការចែករំលែកក្នុងបណ្ដាញសង្គមហ្វេសប៊ុក និងយូធូបជាដើមពីទំព័រហ្វេសប៊ុកក្រសួងអប់រំ យុវជន និងកីឡា ផេកលោកម្ចាស់គ្រូ **ហាក់ សៀងហៃ** និង**ឯកឧត្ដម អ៊ឹង សុផល្លែត** ព្រមទាំងអ្នកដែលបានចែករំលែកជាច្រើនទៀត។ ខ្ញុំជាគ្រូបង្រៀនឯកទេសភាសាអង់គ្លេស ខ្ញុំទទួលស្គាល់ថាអ្នកដែលចេះភាសាអង់គ្លេសច្រើនកម្រនឹងសរសេរពាក្យភាសាអង់គ្លេសខុសណាស់ ទោះបីនោះជាភាសាទីពីរក៏ដោយចុះ តែពេលខ្លះបែរជាសរសេរខុសពាក្យដែលជាភាសាកំណើតរបស់ខ្លួនទៅវិញ។

ទាំងនេះហើយជាបុព្វហេតុជម្រុញឱ្យខ្ញុំចងក្រងសៀវភៅពាក្យខុស ពាក្យត្រូវខ្មែរ ទោះបីជាមិនបានគ្រប់ជ្រុងជ្រោយក៏ដោយចុះ។ តាមពិតពាក្យត្រូវទាំងអស់នេះ គឺមានស្រាប់ទៅហើយនៅក្នុងវចនានុក្រម **សម្ដេចព្រះសង្ឃរាជ ជួន ណាត** តែអ្វីដែលខ្ញុំចងក្រងនេះ គឺគ្រាន់តែរំលេចចេញឱ្យឃើញពាក្យដែលគេឧស្សាហ៍យល់ច្រឡំសរសេរខុសញឹកញាប់ប៉ុណ្ណោះ និងមានបំណងឱ្យការសរសេរភាសាជាតិរបស់យើងឱ្យ

កាន់តែបានត្រឹមត្រូវមួយកម្រិតទៀត។ ភាសា អក្សរ ជាអត្តសញ្ញាណមួយរបស់ជាតិយើង កាលណាយើងឱ្យតម្លៃ និង លើកតម្កើងអក្សរសាស្ត្រជាតិយើង ក៏ដូចជាការរួមចំណែកឱ្យតម្លៃជាតិយើងដែរ។ ខ្ញុំសង្ឃឹមថាសៀវភៅមួយនេះនឹងអាចចូលរួមចំណែកដ៏តិចតួចស្តួចស្តើងក្នុងការលើកកម្ពស់អក្សរសាស្ត្រជាតិយើង។

ខន ស៊ាងហោ -៥

# កតញ្ញុតា

ខ្ញុំបាទសូមគោរពដឹងគុណ និងដឹងគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ៖

- ទឹកដីមាតុភូមិកម្ពុជាដែលបានផ្តល់ទីជ្រកកោន និងការរស់នៅដ៏សុខសាន្ត
- លោកតា **លឹម ផន** និងលោកយាយ **ហ៊ត សារុ** (លោកទាំងពីរបានទទួលអនិច្ចកម្មហើយ)
- អ្នកម្តាយ**ផន់ សាំងហេន** និងលោកឪពុក **ផន សាខន** ដែលបានចិញ្ចឹមបីបាច់ អប់រំប្រៀនប្រដៅ និងផ្តល់ឱកាសឱ្យរូបខ្ញុំបានទទួលការសិក្សា
- អ្នកម្តាយក្មេក **យាន សុខយ** និងលោកឪពុកក្មេក **ភិហ៍ ឈុនលាង**
- បងប្រុស **ខន ខួច** បងស្រី **ខន សាំងហេន** បងប្រុស **ខន សាំងហាក់** ដែលបានជួយមើលថែ
- ឧត្តមភរិយា **ភិ សុខា** និងកូនស្រីជាទីស្រឡាញ់ **ហោ សុគិរិយា**

- យុវសិស្ស **ហុង សត្យា**ដែលបានជួយផ្ទៀងផ្ទាត់ក្នុងវចនានុក្រមខ្មែរ
- លោក **ហេង ហុង** ដែលបានជួយផ្នែកបច្ចេកទេសកុំព្យូទ័រ
- ប្អូនប្រុស **ទុំន វណ្ណា** ដែលបានជួយរចនាគម្របសៀវភៅ
- **លោកគ្រូអ្នកគ្រូទាំងអស់** ដែលបានជួយបង្ហាត់បង្រៀន
- សាច់ញាតិ និងមិត្តភក្តិទាំងអស់។

# មាតិកា

អារម្ភបទ..............................................................3-5
កតញ្ញុតា...............................................................6-7
ពាក្យផ្តើមដោយព្យញ្ជនៈ ក....................................... 10-38
ពាក្យផ្តើមដោយព្យញ្ជនៈ ខ....................................... 39-44
ពាក្យផ្តើមដោយព្យញ្ជនៈ គ.......................................45-54
ពាក្យផ្តើមដោយព្យញ្ជនៈ ឃ .....................................55-58
ពាក្យផ្តើមដោយព្យញ្ជនៈ ង.......................................59-60
ពាក្យផ្តើមដោយព្យញ្ជនៈ ច....................................... 61-73
ពាក្យផ្តើមដោយព្យញ្ជនៈ ឆ....................................... 74-78
ពាក្យផ្តើមដោយព្យញ្ជនៈ ជ.......................................79-90
ពាក្យផ្តើមដោយព្យញ្ជនៈ ញ ..................................... 91-93
ពាក្យផ្តើមដោយព្យញ្ជនៈ ដ.................................... 94-103
ពាក្យផ្តើមដោយព្យញ្ជនៈ ប.................................. 104-105
ពាក្យផ្តើមដោយព្យញ្ជនៈ ត.................................. 106-111
ពាក្យផ្តើមដោយព្យញ្ជនៈ ថ.................................. 112-114
ពាក្យផ្តើមដោយព្យញ្ជនៈ ទ...................................115-129
ពាក្យផ្តើមដោយព្យញ្ជនៈ ធ.................................. 130-132

ពាក្យផ្ដើមដោយព្យញ្ជនៈ ន ................................. 133-139
ពាក្យផ្ដើមដោយព្យញ្ជនៈ ប ................................. 140-171
ពាក្យផ្ដើមដោយព្យញ្ជនៈ ផ ................................. 172-183
ពាក្យផ្ដើមដោយព្យញ្ជនៈ ព ................................. 184-199
ពាក្យផ្ដើមដោយព្យញ្ជនៈ ភ ................................. 200-203
ពាក្យផ្ដើមដោយព្យញ្ជនៈ ម ................................. 204-216
ពាក្យផ្ដើមដោយព្យញ្ជនៈ យ ................................. 217-219
ពាក្យផ្ដើមដោយព្យញ្ជនៈ រ ................................. 220-235
ពាក្យផ្ដើមដោយព្យញ្ជនៈ ល ................................. 236-245
ពាក្យផ្ដើមដោយព្យញ្ជនៈ វ ................................. 245-259
ពាក្យផ្ដើមដោយព្យញ្ជនៈ ស ................................. 260-317
ពាក្យផ្ដើមដោយព្យញ្ជនៈ ហ ................................. 318-324
ពាក្យផ្ដើមដោយ អ ................................. 325-352
ពាក្យផ្ដើមដោយស្រៈពេញតួ ឥ ................................. 353-355
ពាក្យផ្ដើមដោយស្រៈពេញតួ ឯ ................................. 356-360
ពាក្យផ្ដើមដោយស្រៈពេញតួ ឱ ................................. 361-364

# ពាក្យផ្ដើមដោយព្យញ្ជនៈ

# ក

កង្កែបបោក ☒ កង្កែបបោប ☑

បោប

[បោប]

កិ. ចម្អិនម្ហូបដែលហៅថា បោប។

ន. ឈ្មោះម្ហូបដែលមានដាក់ញាត់គ្រឿងផ្សំផ្សេងៗ ក្នុងពោះកង្កែបឬទន្សាយតាយសាក ដែលបានលាត់យកស្បែកនិងអាការៈសោកគ្រោកខាងក្នុងចេញអស់ហើយ ចម្អិនដោយអាំងឬឆ្អើរ : កង្កែបបោប, ទន្សាយបោប។



កង្ហា ☒ កង្ហារ ☑

កង្ហារ

[កង់-ហា]

ន. ប្រដាប់មានស្លាបដែលអាចនឹងវិលដោយកម្លាំងខ្យល់បាន។

កតញុតា ☒ កតញ្ញុតា ☑

កតញ្ញុតា

[កៈ-ត័ញ-ញុ-តា] (បា.)

ន. សេចក្តីដឹងឧបការគុណដែលអ្នកដទៃបានធ្វើដល់ខ្លួន : បុត្រធីតា ត្រូវមានកតញ្ញុតាចំពោះមាតាបិតា។

| | |
|---|---|
| កតញូ ☒ | កតញ្ញូ ☑ |

កតញ្ញូ

[កៈ-ត័ញ-ញូ] (បា.)

ន., គុ. អ្នកដឹងឧបការគុណដែលអ្នកឯទៀតគេបានធ្វើហើយដល់ខ្លួន គឺអ្នកដែលមិនភ្លេច, មិនរមិលគុណគេ : បុរសកតញ្ញូ, ស្ត្រីកតញ្ញូ។ (ព.ផ្ទ. អកតញ្ញូ)។

| | |
|---|---|
| កន្និដ្ឋា ☒ | កនិដ្ឋា ☑ |

កនិដ្ឋា

[កៈ-និត-ឋា] (បា. កនិដ្ឋ)

ន. ប្អូន, ប្អូនតូច, ប្អូនពៅ។ ច្រើនប្រើក្នុងពាក្យកាព្យ ហៅស្ត្រីជាគូសង្សារ, គូសម្លាញ់ : (ព.កា.) ឱ្យតែបានជួបកែវកនិដ្ឋា សមតាមប្រាថ្នានៅនែបនិត្យ បង់ខាតប៉ុន្មានរៀមពុំគិត ស៊ូប្តូរជីវិតឥតងាករេ។

កសិន ☒ កសិណ ☑

កសិណ៤

[កៈ-សិន]

ន. គូឬស្រះធំវែងដែលគេជីកជុំវិញកំពែងបន្ទាយឬប្រាសាទ។ (ម.ព. គូនិងសិន្ធុ ផង)។

កាកបាត ☒ កាកបាទ ☑

កាកបាទ

[កា-កៈ-បាត] (បា. "ជើងក្អែក")

ន. ឈ្មោះវណ្ណយុត្តម្យ៉ាងមានសណ្ឋានដូចជើងក្អែក សម្រាប់ប្រើជៀតអក្សរដែលសរសេរខុសហើយសរសេរជៀតពីលើឬពីក្រោមត្រូវការជើងក្អែកនេះ (+)។

ការងា ☒ ការងារ ☑

ការងារ

[កា-ងា]

ន. កិច្ចដែលត្រូវធ្វើតាមមុខងាររបស់ខ្លួន : ធ្វើការងារ, មានការងារ។

ការពិសោធន៍ ☒ ការពិសោធ ☑

ពិសោធ

[ពិ-សោត] (បា. វិសោធ; សំ. វិឝោធ "សម្អាត, ជម្រះ, រំលីង")

កិ. ល្បងមើល, សាកមើលឱ្យឃើញពិត; ពិនិត្យដោយការល្បងឱ្យឃើញប្រាកដ : ចាំពិសោធមើលសិន, ត្រូវពិសោធឱ្យឃើញពិត។

| | |
|---|---|
| ការអភិវឌ្ឍន៍ ☒ | ការអភិវឌ្ឍ ☑ |

អភិវឌ្ឍ

[អៈ-ភិ-វ័ត] (បា.)

កិ. ចម្រើនក្រៃលែង, លូតលាស់ចម្រើន។

| | |
|---|---|
| កាលទេស ☒ | កាលៈទេសៈ ☑ |

កាលៈទេសៈ

[កា-ឡៈ-ទេ-សៈ] (បា. កាល "គ្រា, ពេល, សម័យ" + ទេស "ស្រុក, ប្រទេស")

១). ន. កាលសម័យរបស់ស្រុកទេស; កាលនិងប្រទេស, លក្ខខណ្ឌនៃពេលវេលា ទីកន្លែងជាដើម ដែលអម ឬមានឥទ្ធិពលលើព្រឹត្តិការណ៍ ឬលក្ខខណ្ឌ : មុននឹងប្រកបមុខរបរផ្សេងៗ គប្បីពិចារណាមើលឱ្យសមរម្យទៅតាមកាលៈទេសៈ។

កាស្សែត ☒ កាសែត ☑

កាសែត

[កា-សែត] (បារ. gazette)

ន. សារព័ត៌មាន, សេចក្ដីផ្សាយដំណឹងផ្សេងៗដែលបោះពុម្ពផ្សាយលើក្រដាសបត់ជាច្រើនសន្លឹក : អានកាសែត, រឿងរ៉ាវក្នុងកាសែត។

កិលេះ ☒ កិលេស ☑

កិលេស

[កិ-ឡេះ] (បា.)

ន. សេចក្ដីសៅហ្មងចិត្ត : លះកិលេស។

កីឡាដ្ឋាន ☒ | កីឡដ្ឋាន ☑

កីឡដ្ឋាន

[កី-ឡាត់-ឋាន] (បា.)

ន. ទីកន្លែងសម្រាប់លេងល្បែងផ្សេងៗ, កន្លែងសម្រាប់លេងកីឡាផ្សេងៗ។

កឹបភ្ជាប់ ☒ | កិបភ្ជាប់ ☑

កិប១

[កិប]

កិ. ភ្ជាប់អ្វីមួយឱ្យជាប់គ្នា ដោយប្រើកិបឬឃ្នាប : កិបឡេវអាវ, កិបសៀវភៅ។

ន. ប្រដាប់ធ្វើពីលោហជាតិ មានសណ្ឋានជារបៀបញីឈ្នោល សម្រាប់ដាក់ភ្ជាប់សាច់សំពត់ : ដាក់កិប, ឡេវកិប។

កិប២

[កិប]

កិ. បន្លំលាក់ទុកខ្លះ, តែបំបាត់យកខ្លះ : កិបប្រាក់។

កិប៣

[កិប]

ន. គូទការ៍ទូសកាំភ្លើង។

| | |
|---|---|
| កុកនឹងក្អែក ☒ | កុកនិងក្អែក ☑ |

និង

[និង] ឬ [នឹង]

ឈ. សព្ទជាសន្ធាន ជាទ្វន្ទ្វសម្រាប់និយាយតពាក្យឬតឃ្លារបះពីមួយទៅមួយ ដែលមានដំណើរសេចក្ដីថា ទាំង, ព្រមទាំង, ផង, នេះផង, នុះផង : អ្នកនិងខ្ញុំ; គោនិងក្របី; ផ្ទះនេះផ្ទះនុ៎ះនិងផ្ទះឯណោះ; សុខនិងទុក្ខ; ទៅនិងមិនទៅ; ឱ្យនិងមិនឱ្យ; យកចាននិងផ្ដិលមកផង។ល។

| | |
|---|---|
| កុងស៊ី ☒ | កុងស៊ីយ៍ ☑ |

កុងស៊ីយ៍

[កុង-ស៊ី] (បារ. conseil)

ន. ក្រុមឬពួកអ្នកទូន្មាន។

| | |
|---|---|
| កុដ ☒ | កុដិ ☑ |

កុដិ

[កុត] (សំ.បា.)

ន. ខ្ទម; ផ្ទះ; លំនៅរបស់អ្នកបួស។

| | |
|---|---|
| កុម្ភះ ☒ | កុម្ភៈ ☑ |

កុម្ភៈ១

[កុម-ភៈ] (បា.សំ.)

ន. ក្អម, ឆ្នាំង។

កុម្ភៈ២

[កុម-ភៈ]

ន. ឈ្មោះខែទី២តាមសុរិយគតិមាន២៨ឬ២៩ថ្ងៃនិងមាន រាសីរូបក្អម។

កុម្មុយនីស ☒ កុម្មុយនីស្ត ☑

កុម្មុយនីស្ត

[កុំ-មុយ-នីស] (ជើង ត) (បារ. communiste)

គុ. (ឬ.ន.) ដែលមានចលនានយោបាយមួយបែបដែលរដ្ឋាភិបាលជាអ្នកគ្រប់គ្រងប្រព័ន្ធសេដ្ឋកិច្ច ក្នុងគោលបំណងបង្កើតសង្គមមួយដែលមនុស្សម្នាក់ៗមានឋានៈស្មើៗគ្នា ៈរដ្ឋកុម្មុយនីស្តមួយនេះមានអាវុធនុយក្លេអ៊ែរ។

កុសល់ ☒ កុសល ☑

កុសល១

[កុ-សល់] (បា.)

ន. កម្មដែលកម្ចាត់បង់នូវអំពើអាក្រក់ (បុណ្យ)។ (ព.ផ្ទ. អកុសល)។

កុសល២

[កុ-សល់] (បា.)

១). គុ. ដែលល្អប្រពៃ, ដែលជាបុណ្យ : ចិត្តកុសល។

២). ដែលប៉ិនប្រសប់, ឈ្លាសវាងវៃ : កុសលបណ្ឌិត។

កុហាក់ ☒ កុហាក ☑

កុហាក

[កុ-ហាក់] (បា.)

កិ. និយាយឱ្យគេភាន់ជំនឿ : កុំកុហកគេបាប។ (គួរលែងប្រើពាក្យ កហាក់ឬក្រហាក់ ត្រូវប្រើ កុហកវិញ)។

គុ. ដែលបំភាន់ជំនឿគេ : ពាក្យកុហក, មនុស្សកុហក។

| | |
|---|---|
| កុះក ☒ | កុះករ ☑ |

កុះករ

[កុះ-ក]

គុ. ច្រើន, បរិបូណ៌, សម្បូណ៌, ដេរដាស : ស្រុកនេះមានមនុស្សកុះករ។

| | |
|---|---|
| កូលាប ☒ | កុលាប ☑ |

កុលាប

[កុ-ឡាប]

ន. ឈ្មោះដើមផ្កាមួយប្រភេទសណ្ឋានជាវល្លិមានបន្លា មានក្លិនក្រអូបឆ្ងាញ់។

| | |
|---|---|
| កៀ ☒ | កៀរ ☑ |

កៀរ

[កៀ]

១). កិ. ជូត, ប្រមូលដោយខ្នៀរ; ប្រមូលនាំយកទៅ។

២). (ភូមិ.) ប្រមូលនិងនាំយកទៅដោយបង្ខំនូវប្រជាជនពីកន្លែងមួយទៅកាន់កន្លែងមួយទៀតក្នុងប្រទេសឬឆ្លងប្រទេស។

| | |
|---|---|
| កេងប្រវ៉ាញ់ ☒ | កេងប្រវ័ញ្ច ☑ |

កេងប្រវ័ញ្ច

[កេង-ប្រ-វ៉ាញ់]

កិ. យកចំណេញដោយគៃបន្លំ, គៃបំបាត់ដោយបញ្ឆោតឬឧបាយកលផ្សេងៗ ដើម្បីយកប្រយោជន៍អ្វីមួយ : កុមារប្រឈមនឹងការកេងប្រវ័ញ្ចផ្នែកសេដ្ឋកិច្ច។

| | |
|---|---|
| កេតនភ័ណ្ឌ ☒ | កេតនភណ្ឌ ☑ |

កេតនភណ្ឌ

[កេ-តៈ-ណាៈ-ភ័ន] (បា.)

ន. របស់ដែលទុកដូចជាទង់សម្រាប់ជាតិឬសម្រាប់ប្រទេស, វត្ថុដ៏ឧត្តុង្គឧត្តម; និមិត្តរូប : ប្រទេសនីមួយៗ លុះត្រាតែមានឯករាជ្យពេញបរិបូណ៌ ដោយសេរីភាពគ្រប់យ៉ាង ទើបឈ្មោះថា មានកេតនភណ្ឌ។

| | |
|---|---|
| កែរ ☒ | កែ ☑ |

កែ

[កែ]

កិ. រើធ្វើឡើងទៀតឱ្យខុសអំពីភាពដើម : ត្រូវកែជាថ្មី, កែតម្រូវ, កែសម្ដី, កែខ្លួន, កែប្រែ។

| | |
|---|---|
| ក្ដាខៀន ☒ | ក្ដារខៀន ☑ |

ក្ដារខៀន

[ក្ដា-ខៀន] (ស. ខៀន អ.ថ. ខៀ៌ន "សរសេរ, គូរ")

ន. ប្រដាប់សម្រាប់សរសេរធ្វើដោយឈើឬកញ្ចក់ រាងបួនជ្រុងទ្រវែងធំ ច្រើនភ្ជាប់នឹងជញ្ជាំងបន្ទប់រៀនឬមានជើងទម្រ។

| | |
|---|---|
| ក្រដាស់ ☒ | ក្រដាស ☑ |

ក្រដាស

[ក្រ-ដាស]

ន. សន្លឹកស្តើងៗធ្វើពីវត្ថុផ្សេងៗ គឺចំបើង, កំណាត់សំពត់, សំបកឈើឬសាច់ឈើជាដើម សម្រាប់ប្រើបោះពុម្ពអក្សរ, សរសេរ, វេចខ្ចប់របស់ទាំងឡាយ។ល។

| | |
|---|---|
| ក្របីវាត់ ☒ | ក្របីវ័ធ ☑ |

វ័ធ

[វ៉ាត់] (បា. វធ < ហន "បៀតបៀន; សម្លាប់")

កិ. ជួសឆ្កឹះខ្លាំងដោយចុងស្នែង : ក្របីវ័ធ។ (សរសេរជា វាត់ ក៏មាន; គួរប្រើ វ័ធ នេះវិញ ត្រឹមត្រង់តាមប្រភពដើម)។

| | |
|---|---|
| ក្រម៉ា ☒ | ក្រមា ☑ |

ក្រមា

[ក្រ-ម៉ា]

ន. សំពត់ត្បាញដោយអំបោះ មានក្រឡាខ្វែងសម្រាប់ផ្លាស់ ងូតទឹក បង់ក ជួតក្បាល។ល។

ក្រលេក ☒ ក្រឡេក ☑

ក្រឡេក

[ក្រ-ឡេក]

កិ. មើលចំហៀងភ្នែកដោយរហ័ស គឺមើលភ្លាម ងាកមកវិញភ្លាម។

ក្រវ៉ាត់ ☒ ក្រវាត់ ☑

ក្រវាត់

[ក្រ-វ៉ាត់]

កិ. ព័ទ្ធជុំវិញភ្ជាប់មុខគ្នា : ក្រវាត់ខ្សែក្រវាត់។

ក្រឡៃ ☒ កាឡៃ ☑

កាឡៃ១

[កា-ឡៃ] (ស. កាហ្លៃ)

កិ. ជ្រលក់កែប្រាក់ទៅជាមាស, កែស្ពាន់ជាប្រាក់ជាដើម។

ន. របស់ដែលកាឡៃ។

កាឡៃ២

[កា-ឡៃ]

កិ. បំភ័ន្ត បំភ្លៃ ភូតភរ : កាឡៃការពិត

ក្រូចឆ្មា ☒ ក្រូចឆ្មារ ☑

ក្រូចឆ្មារ១

[ក្រូច-ឆ្មា]

ន. ឈ្មោះស្រុកមួយឋិតនៅតាមដងទន្លេមេគង្គក្នុងខេត្តត្បូងឃ្មុំ : ស្រុកក្រូចឆ្មារ។

ក្រូចឆ្មារ២

[ក្រូច-ឆ្មា]

ន. ក្រូចដើមទាប ផ្លែតូចៗ សម្រាប់ប្រើការបានច្រើនយ៉ាង មានប្រើធ្វើម្ជូរជ្រក់ជាដើម។

ក្រៀល ☒ ទ្រៀល ☑

ទ្រៀល

នាមសព្ទ

ឈ្មោះឈើតូចនិងវល្លិដើមរឹង មាន ២ ប្រភេទគឺ ទ្រៀលស្វា មានដើមតូចៗដុះបែកជាគុម្ពធំៗ មានផ្លែតូចៗជាចង្កោមៗ ស្រដៀងនឹងផ្លែជើងចាបតូច ផ្លែទុំមានសម្បុរក្រហមបរិភោគបាន មានរសផ្អែមស្រទន់បន្តិច; ទ្រៀលដោះក្របី មានដើមជាវល្លិ ថ្លោសៗ សាច់រឹង ឡើងតោងដើមឈើខ្ពស់មានផ្លែថ្លោសៗ ប៉ុនៗដោះក្របីញី ផ្លែជាចង្កោមៗ ផ្លែទុំមានសម្បុរក្រហម បរិភោគបាន មានរសជូរអែម; ទ្រៀលទាំង ២ ប្រភេទនេះ ដុះឯងពុំដែលឃើញមានអ្នកណា

មួយដាំទេ ជាផលព្រឹក្សមានប្រយោជន៍គួររក្សាទុកឲ្យមានជិតភូមិដែលវាដុះឯង ។ សរសេរជា ត្រៀល ក៏បាន ។

ក្លាហ៊ាន ☒ ក្លាហាន ☑

ក្លាហាន

[ក្លា-ហាន]

គុ. ហ៊ាន, លុះ, មោះមុត, អង់អាច : ចិត្តក្លាហាន, មនុស្សក្លាហាន។

ក្សិនក្ស័យ ☒ ក្សិណក្ស័យ ☑

ក្សិណក្ស័យ

[ក្សិន-ក្សៃ]

ន., កិ. ការបាត់បង់សូន្យទៅក្នុងមួយស្របក់ គឺការស្លាប់ភ្លាម។ សព្វថ្ងៃប្រើជា កិ. : ជីតាខ្ញុំក្សិណក្ស័យទៅហើយ គឺជីតាខ្ញុំស្លាប់ភ្លាមទៅហើយ។

កំចី ☒ កម្ចី ☑

កម្ចី១

[កំ-ចី]

គុ., ន. អ្វីៗ មានផ្លែឈើជាដើមដែលខ្ចី : ផ្លែកម្ចី (ព.ទ្រ.)។

កម្ចី២

[កំ-ចី]

ន., គុ. របស់ឬប្រាក់ឬទំនិញដែលបានខ្ចីហើយត្រូវទូទាត់សងវិញតាមលក្ខខណ្ឌនៃកិច្ចសន្យា, ដែលទាក់ទងនឹងការខ្ចី : កម្ចីខ្នាតតូច, ប្រាក់កម្ចី។

កំដៅ ☒ កម្ដៅ ☑

កម្ដៅ

[កំ-ដៅ]

ន. ចំហាយក្ដៅ : កម្ដៅថ្ងៃ, កម្ដៅភ្លើង, កម្ដៅសុរា។

(រូប.) ចំហាយក្ដៅ ដែលភាយចេញពី សារធាតុណាមួយ : ថាមពលកម្ដៅ, កម្ដៅភាយពីចំហេះ។

កិ. ធ្វើឱ្យក្ដៅ : កម្ដៅសម្ល, កម្ដៅពោះ; កម្ដៅចិត្ត។

កំណាប ☒ កំណាព្យ ☑

កំណាព្យ [កំ-ណាប]

ន. ពាក្យកាព្យ, អត្ថបទពាក្យចួន ផ្ទួនរណ្ដំ ណែងណង ប្រកបដោយរូបារម្មណ៍រស់រវើក : លើកកំណាព្យ, តែងកំណាព្យ។

កំទិច ☒ កម្ទេច ☑

កម្ទេច [កំ-ទេច]

កិ. ធ្វើឱ្យខ្ទេច : កម្ទេចជាធូលី, កម្ទេចជាផេះ។

កិ. (ព.ប្រ.) បំផ្លាញ, ធ្វើឱ្យវិនាស អន្តរាយ : កម្ទេចផលិតផលក្លែងក្លាយចោល, កម្ទេចសត្រូវ។

ន. អ្វីៗដែលខ្ទេច។

កំនាន់ ☒ កំណាន់ ☑

កំណាន់

[កំ-ណាន់]

ន. របស់ដែលផ្ទាប់ប្រកាន់; មុខងារដែលផ្ទាប់ប្រកាន់ : សហាយកំណាន់, បាវកំណាន់, កំណាន់ខេត្ត។

កំនើត ☒ កំណើត ☑

កំណើត

[កំ-ណើត]

ន. ជាតិ, ដំណើរដែលកើត; កាលវេលាដែលកើត; ទីតំបន់ដែលកើត : ចាប់កំណើត, ឆ្នាំកំណើត, ស្រុកកំណើត។

កំពស់ ☒ កម្ពស់ ☑

កម្ពស់១

[កំ-ពស់]

ន. ភាពខ្ពស់, សណ្ឋានបញ្ឈរ, ជំហរ : ព្រះវិហារខ្លះមានកម្ពស់២០ម៉ែត្រ។

កម្ពស់២

[កំ-ពស់]

ន. (គណិត.) អង្កត់ដែលភ្ជាប់ពីចំណុចកំពូលមួយទៅកែងនឹងជ្រុងឈមណាមួយនៃពហុកោណ។

កំរាស់ ☒ ក្រមាស់ ☑

ក្រមាស់

[កំ-រ៉ាស់]

គុ., ន. ទោលឬជម្រៅរបស់វត្ថុដែលរឹង : ក្ដារក្រមាស់ ១ធ្នាប់។

កំរើក ☒ កម្រើក ☑

កម្រើក

[កំ-ក្រើក]

កិ. កក្រើក, រំជួល : កម្រើកចិត្ត, កម្រើកខ្លួន។

| | |
|---|---|
| កំរៃ ☒ | កម្រៃ ☑ |

កម្រៃ

[កំ-រ៉ៃ]

ន., គុ. អ្វីៗដែលចំណេញ, ដែលបានមកលើសដើម : ធ្វើការមានកម្រៃ, ជួញមានកម្រៃ។

| | |
|---|---|
| កំសាន្ត ☒ | កម្សាន្ត ☑ |

កម្សាន្ត

[កំ-សាន]

កិ. សម្រាកចិត្ត, ធ្វើឱ្យក្សាន្តចិត្ត, លំហើយចិត្ត, ធ្វើចិត្តឱ្យស្រាកស្រាន្ត, ឱ្យស្បើយចាកអារម្មណ៍ផ្សេងៗ : ដើរលេងកម្សាន្តចិត្ត។ (ម.ព. ក្សាន្ត ផង)។

កំឡាំង ☒ កម្លាំង ☑

កម្លាំង [កំ-ឡាំង]

១). ន. អំណាចធាតុដែលធ្វើអវយវៈឱ្យកម្រើក, ឱ្យខ្លាំង, ឱ្យប្រព្រឹត្តទៅបាន។

២). ថាមពលធ្វើឱ្យអង្គធាតុផ្លាស់ប្ដូរចលនាឬខូចទ្រង់ទ្រាយ : កម្លាំងអគ្គិសនីចលករ, កម្លាំងមេកានិក។

៣). ចំនួនមនុស្ស (កងទ័ព, នគរបាល, កងសន្តិសុខ ជាដើម) សម្រាប់បំពេញការងារអ្វីមួយ : កម្លាំងការពារព្រំដែន, ថែមកម្លាំងដប់នាក់ទៀត។

កំឡុង ☒ អំឡុង ☑

អំឡុង

[អំ-ឡុង]

ន. កាលយូរ : ក្នុងអំឡុង១០ឆ្នាំ។ (បុរាណសរសេរ អំលុង)។

# ពាក្យផ្ដើមដោយព្យញ្ជនៈ

# ខ

ខណះ ☒ ខណៈ ☑

ខណៈ

[ខៈ-ណាៈ] (បា.; សំ. ក្សណ)

ន. ស្របក់, រំពេច : ខណៈនោះ, មួយខណៈ។

ខិតប័ណ្ណ ☒ ខិត្តបណ្ណ ☑

ខិត្តប័ណ្ណ

[ខិត-តៈ-ប័ន] (បា.)

ន. សំបុត្រដែលគេបោះបាចឬចែកផ្សាយ ដើម្បីឱ្យដឹងដំណឹងអ្វីមួយ។

ខ្វែ ☒ ខ្វែរ ☑

ខ្វែរ១

[ខ្វែ]

ន. ឈ្មោះវល្លិមួយប្រភេទ ផ្លែមានមមីសរមាស់ណាស់ : វល្លិ ខ្វែរ, ខ្វែររោល។

ខ្នុល/ ខ្នោរ ☒ ខ្នុរ ☑

ខ្នុរ១

[ខ្នុល]

ន. ឈ្មោះរោគបូសដែលច្រើនតែកើតនៅក្បាលកូនក្មេង : ក្មេងកើតខ្នុរ, បូសខ្នុរ។

ខ្នុរ២

[ខ្នុល]

ន. ឈ្មោះឈើដំណាំមួយប្រភេទ មានផ្លែជាអាហារ ខ្លឹមប្រើស្ងោរយកទឹកជ្រលក់សំពត់ចីវរអ្នកបួសក្នុងព្រះពុទ្ធសាសនា។ ខ្នុរមានច្រើនយ៉ាងគឺ ខ្នុរណាំង សាច់រឹង, ខ្នុរបាយស្រា សាច់ជ្រាយជាដើម។

| | |
|---|---|
| ខ្ពុលមាត់ ☒ | ខ្ពុរមាត់ ☑ |

ខ្ពុរ [ខ្ពុល]

កិ. បៀមទឹកអង្រង់លាងមាត់ : បរិភោគអាហារហើយត្រូវខ្ពុរមាត់។

| | |
|---|---|
| ខ្ទាស់ ☒ | ខ្ទាស ☑ |

ខ្ទាស១

[ខ្ទាស]

ន. គុយ្ហប្រទេស គឺអង្គជាតប្រុសស្រី ជាពាក្យប្រើជាជំនួសដើម្បីមិនឱ្យហៅអង្គជាតចំពោក តែច្រើនហៅថា កេរខ្ទាស។

ខ្ទាស២

[ខ្នាស]

គុ., ន. សេចក្ដីអៀនអន់, ដែលអៀនខ្នាស។

| | |
|---|---|
| ខ្លោចផ្សារ ☒ | ខ្លោចផ្សា ☑ |

[ខ្លោច-ផ្សា]

គុ. សង្រេងសង្រៃខ្លាំង ហាក់ដូចជាឆេះខ្លោចហើយផ្សាក្នុងចិត្ត។

| | |
|---|---|
| ខ្សែក្រ៉វាត់ ☒ | ខ្សែក្រវាត់ ☑ |

[ខ្សែ-ក្រ-វ៉ាត់]

ន. ប្រដាប់សម្រាប់ក្រវាត់ចង្កេះ ធ្វើដោយសំពត់, ដោយស្បែក, ដោយអំបោះ, ឬដោយលោហជាតិផ្សេងៗ មានមាសនិងប្រាក់ជាដើម។

ខ្មៅវិញ ☒ ខ្មៅវេញ ☑

វេញ

[វេញ]

កិ. ត្របាញ់បញ្ចូលផ្លុង : វេញខ្សែ។

ខ័ណ្ឌសីមា ☒ ខណ្ឌសីមា ☑

ខណ្ឌសីមា

[ខ័ន-ឌៈ-សី-ម៉ា] ឬ [ខ័ន-សី-ម៉ា] (បា.)

ន. សីមាតូច។ ឈ្មោះពទ្ធសីមាតូច ដែលព្រះភិក្ខុសង្ឃសន្មត ដោយញត្តិទុតិយកម្មវាចា ផ្ដាច់ចេញចាកមហាសីមា ដើម្បីធ្វើសង្ឃកម្មដោយងាយ (ពរិ.)។

# ពាក្យផ្ដើមដោយព្យញ្ជនៈ

# គ៍

ខន សាំងហោ -៤៥

គង់វង់ ☒ គង់វង្ស ☑

គង់វង្ស

[គង់-វង់]

កិ., គុ. គង់ពូជវង្សនៅមិនសូន្យ, គង់ដំណែល ឬប្រពៃណីនៅដូចដើម : យើងត្រូវរក្សាសុជីវធម៌ឱ្យគង់វង្ស, រក្សាប្រពៃណីល្អឱ្យគង់វង្ស។ (វង់ និងវង្ស មានសំឡេងដូចគ្នា, គួរប្រយ័ត្នកុំសរសេរឱ្យច្រឡំ វង់ ជាវង្សឬវង្ស ជាវង់)។

គណាកម្មាការ ☒ គណៈកម្មការ ☑

គណៈកម្មការ

[គៈ-ណៈ-កាំ-ម៉ៈ-កា] (បា.)

ន. ជនមួយក្រុមឬក្រុមជំនុំដែលចាត់តាំងឡើង ដោយពិធីបោះឆ្នោតឬដោយការជ្រើសតាំង សម្រាប់ឱ្យពិនិត្យកិច្ចការណាមួយដាច់មុខដោយឡែក : គណៈកម្មការវប្បធម៌ បានបង្កើតពាក្យខ្មែរថ្មីៗជាច្រើន។

គណៈបក្ស ☒ គណបក្ស/ គណបក្ខ ☑

គណបក្ស

[គៈ-ណៈ-ប៉ាក់] (សំ.)

ន. (ម.ព. គណបក្ខ)។

គម្រូ ☒ គំរូ ☑

គំរូ

[គុំ-រូ]

ន. បែប, សំណាក, តួយ៉ាង, ផែនទី : គំរូស្ពានបេតុង, គំរូផ្ទះឈើ ...។

គិចរៀន ☒ គេចរៀន ☑

គេច

[គេច]

កិ. ចៀសវាង : គេចចុះគេចឡើង, ទាហានទៅខាងឆ្វេង ចោរគេចទៅខាងស្តាំ។

| | |
|---|---|
| គិលានុបដ្ឋាកយិកា ☒ | គិលានុបដ្ឋាយិកា ☑ |

គិលានុបដ្ឋាយិកា

[គិ-លា-នុ-ប៉ុត-ឋា-យិ-កា]

ន. (ម.ព. គិលានុបដ្ឋាក)។

គិលានុបដ្ឋាក (—ប៉ុត-ឋាក) អ្នកបម្រើ, អ្នកថែទាំអ្នកជម្ងឺ ។ ឥត្ថី. គិលានុបដ្ឋាយិកា ។ គិលានុបដ្ឋាន (—ប៉ុត-ឋាន) ការបម្រើ, ថែទាំ, ទំនុកបម្រុងអ្នកជម្ងឺ; មន្ទីរពេទ្យព្យាបាលអ្នកជម្ងឺ ។ គិលានុបដ្ឋានព្រះមហាក្សត្រិយានី ឈ្មោះមន្ទីរសង្ឃពេទ្យមួយក្នុងព្រះរាជធានីភ្នំពេញ ។

| | |
|---|---|
| គុណាណូបការៈ ☒ | គុណូបការៈ ☑ |

គុណូបការៈ

[គុ-ណូ-ប៉ៈ-កា-រ៉ៈ] (<គុណ + ឧបការ)

១). ន. សេចក្ដីទំនុកបម្រុង, អនុគ្រោះដោយគុណ គឺសេចក្ដីទំនុកបម្រុងឱ្យល្អ, ឱ្យដុះដាលចម្រើន; ហៅថា ឧបការគុណ វិញក៏បាន។

២). ឧត្ដមភាពឬតម្លៃដែលសក្តិសមនឹងទទួលបានការតបស្នងជារង្វាន់ឬកិត្តិយស : គុណូបការៈចែកចេញជាពីរ គឺ គុណូបការៈសីលធម៌ ដូចជា គុណធម៌ ជាដើម និងគុណូបការៈមិនមែនសីលធម៌ ដូចជា ជំនាញ បំណិន ជាដើម : គុណូបការៈជាគុណសម្បត្តិដែលត្រូវគោរពនិងកោតសរសើរ។

គុម្ពោធ ☒ គុម្ពោត ☑

គុម្ពោត

[គុំ-ពោត] (បា. ថា គុម្ពោ តាមវិធីបំបែកនាមសព្ទ)

១). ន. គុម្ពឈើតូចៗ ដែលដុះជុំគ្នាមួយជុំៗ : គុម្ពោតឈើ។

២). (ព.ប្រ.) ល្បិច កន្លៀត, អាថ៌កំបាំង : អញស្គាល់ហើយគុម្ពោតនុ៎ះ!

គុំចេក ☒ គុម្ពចេក ☑

គុម្ព

[គុំ] (បា.; សំ. គុល្មៈ ពួក, ប្រជុំ, បន ...)

ន. ពួក, ប្រជុំដើមឈើឬដំណាំផ្សេងៗ : គុម្ពឈើ, ចេក១ គុម្ព។

គូរប្រេង ☒ គូព្រេង ☑

ព្រេង

[គូ-ព្រេង]

ន. គូសំណាងដែលបានសាងសូមប្រាថ្នាជាមួយគ្នាពីជាតិមុនមក (ប្រើចំពោះតែបុរសនិងស្ត្រី)។

គោរប់ ☒ គោរព ☑

គោរព

[គោ-រប់] (សំ. គៅរវ; បា. គារវ)

ន. សេចក្ដី លំអុត, លំអុតលំ ឱន, ឱនលំ ទោន, ដំណើរ ប្រតិបត្តិតាមសេចក្ដីកោតក្រែង, ដំណើរយកចិត្តទុកដាក់។

កិ. ប្រើក្លាយមកជា កិ. : កូនត្រូវគោរពមាតាបិតា, សិស្សត្រូវគោរពគ្រូ, អ្នកបួសត្រូវគោរពសិក្ខាបទ, ប្រជាជនត្រូវគោរពព្រះមហាក្សត្រ, ជនានុជនត្រូវគោរពច្បាប់, ពុទ្ធសាសនិកជនត្រូវគោរពព្រះពុទ្ធសាសនា។

គៀក ☒ កៀក ☑

កៀក

[កៀក]

កិ. ឱបដោយដៃម្ខាង : កៀក ក។

គៀងគរ ☒ កៀរគរ ☑

កៀរគរ

[កៀ-គ]

១). កិ. កៀរឱ្យបានជាគំនរ, ប្រមូលឱ្យបានច្រើន : ខំដើរកៀរគរ។

២). និយាយបញ្ចុះបញ្ចូលផ្សែផ្សំពីនេះខ្លះ ពីនោះខ្លះ ដើម្បីឱ្យគេចុះចូលមកខាងខ្លួន : និយាយកៀរគរ។

| | |
|---|---|
| គៀន ☒ | កៀន ☑ |

កៀន១

[កៀន]

១). ន. ញ្ញោចឬឈ្លូងតូច : កៀនសមុទ្រ។

២). កន្លៀត : កៀនជញ្ជាំង។

កៀន២

[កៀន]

ន. ឈ្មោះក្អមតូចៗធ្វើនៅភូមិកៀន ក្នុងស្រុកកណ្ដាលស្ទឹង, សម្រាប់ដាក់ស្ករត្នោត : ក្អមកៀន។

| | |
|---|---|
| គ្រវែង ☒ | គ្រវ៉ែង ☑ |

គ្រវ៉ែង

[គ្រ-វ៉ែង]

កិ. ចាប់អ្វីៗ បោះចោលឱ្យឃ្លាតឆ្ងាយពីខ្លួន : គ្រវ៉ែងដំបង, ចាប់ពស់គ្រវ៉ែងឆ្ងាយពីខ្លួន។

| | |
|---|---|
| គ្រាដើរ ☒ | គ្រាហ៍ដើរ ☑ |

គ្រាហ៍

[គ្រា] (សំ. គ្រាហ; បា. គាហ)

ន. ដំណើរអង, អបអង, កៀកអង។

កិ. ប្រើក្លាយមកជា កិ. : គ្រាហ៍មនុស្សឈើ, គ្រាហ៍មនុស្ស មានរបួស។

គ្រីស្តសករាជ ☒ គ្រិស្តសករាជ ☑

គ្រិស្តសករាជ

[គ្រិស-សៈ-កៈ-រ៉ាច] (ជើង ត)

ន. ការកំណត់ឆ្នាំចាប់ពីថ្ងៃកំណើតព្រះយេស៊ូគ្រិស្ត (អក្សរកាត់ គ.ស.) : សម័យអង្គរចាប់ផ្តើមពីឆ្នាំ៨០២ នៃគ្រិស្តសករាជ។ (ម .ព. យេស៊ូ ផង)។

គំហគ ☒ គំហក ☑

គំហក

[គុំ-ហ៊ក]

កិ. ស្រែកសង្ឃ្សកដាក់ : គាត់គំហ៊កដាក់ខ្ញុំថា ឆ្កួត! អាចម្កួត!

# ពាក្យផ្ដើមដោយព្យញ្ជនៈ

# ឃ

ខន ស៊ាងហោ -៥៥

ឃាតក ☒ ឃាតករ ☑

ឃាតករ

[ឃា-តៈ-ក]

ន. សព្ទថ្ងៃប្រើក្លាយមកពី ឃាតកៈ។ (ម.ព. ឃាតកៈ)។

ឃុបឃិត ☒ គប់គិត ☑

គប់គិត

[គប់-គិត]

កិ.រួមគំនិតគ្នា, គិតគូរគ្នា។

ឃោសណា ☒ ឃោសនា ☑

ឃោសនា

[ឃោ-ស្នា] (បា.)

ន. សម្ដីគឹកកង, សំឡេងកងរំពង, អឺងអាប់; ការប្រកាស, ការស្រែកប្រកាសឮខ្លាំងៗ ផ្សាយដំណឹងឱ្យសាធារណជនដឹង, ការផ្សាយដំណឹងឱ្យឮសាយសុសសព្វគ្នា។ ប្រើតាមទម្លាប់ចំពោះតែការប្រកាសអង្គាសវត្ថុផ្សេងៗ ធ្វើបុណ្យឱ្យទាន។

កិ., គុ. បន្លឺសម្ដីគឹកកង, បន្លឺសំឡេងកងរំពង; ដែលអឺងអាប់, ដែលកងរំពង : សេចក្ដី ឃោសនា, សំបុត្រឃោសនា;អាចារ្យឃោសនាចង្ហាន់, ឃោសនាចតុបច្ច័យ។ (សរសេរក្លាយជា ឃោស្នា តាមសូរសំនៀងនិយាយក៏មាន; សរសេរបែបនេះសម្រាប់ប្រើក្នុងកាព្យ, សរសេរត្រឹមត្រូវជា ឃោសនា អ.ថ. ឃោស្នា)។

ឃ្លាងឃ្លាត ☒ ឃ្លៀងឃ្លាត ☑

ឃ្លៀងឃ្លាត

[ឃ្លៀង-ឃ្លាត]

កិ., គុ. ឃ្លៀងឃ្លាតចេញ, ងាកបែរចេញ, លាកចេញពីគ្នា : សេចក្ដីឃ្លៀងឃ្លាត។

ឃ្វៀលគោ ☒ ឃ្វាលគោ ☑

ឃ្វាល

[ឃ្វាល]

កិ. ចាំ, រក្សាសត្វចិញ្ចឹម : ឃ្វាលគោ, ឃ្វាលក្របី, ក្មេងឃ្វាលក្របី ជិតបឹងមួយ។

# ពាក្យផ្ដើមដោយព្យញ្ជនៈ

# ង

ងងិត ☒ ងងឹត ☑

ងងឹត

[ង-ងឹត]

១). គុ. ទីទៃពីភ្លឺ, ដែលឥតមានពន្លឺ : យប់ងងឹត, ខែងងឹត។

២). ដែលទើសគំនិតគិតមិនយល់ : ងងឹតមុខ គឺដែលងោងជ្រប់មើលអ្វីមិនឃើញ, គិតអ្វីមិនទាន់ ដោយខ្យល់ដើរមិនស្រួលឬដោយខឹងខ្លាំងជាដើម។ (កុំប្រើប្រែឡំជា ល្ងឹត, ល្ងឹតល្ងង់)។

ងឿយឆ្ងល់ ☒ ងឿងឆ្ងល់ ☑

ងឿងឆ្ងល់

[ងឿង-ឆ្ងល់]

កិ. ឆ្ងល់ងឿងគំនិតគិតមិនឃើញ។

# ពាក្យផ្តើមដោយព្យញ្ជនៈ

# ប

ខន សាំងហោ -៦១

| | |
|---|---|
| ចក្រវាល ☒ | ចក្រវាឡ/ ចក្កវាល ☑ |

ចក្រវាល

[ច័ក-ក្រៈវ៉ាល] (សំ.)

១). ន. លោកធាតុ គឺភ្នំជាកំពែងព័ទ្ធជុំវិញនៃពិភពលោកទាំងមូល។ (ម.ព. លោកធាតុ ផង)។

២). (ភូមិ.) សំណុំនៃអង្គនភានិងកាឡាក់ស៊ីទាំងអស់ ដោយគិតទាំងលំហដែលវាស្ថិតនៅផង។

| | |
|---|---|
| ចង្អេ ☒ | ចង្អេរ ☑ |

ចង្អេរ

[ចង់-អេ]

ន. ប្រដាប់ត្បាញដោយបន្ទោះឬស្សី សម្រាប់អុំស្រូវ, អុំអង្ករជាដើម;ឬសម្រាប់ហាលអ្វីៗ; ចង្អេរមានបីយ៉ាងគឺ ចង្អេរអុំ សម្រាប់ប្រើអុំ; ចង្អេរគ្រាង សម្រាប់ប្រើហាលអ្វីៗ; ចង្អេរកឡោប៊ី គឺចង្អេរ

ដំទើរតូចស្មើរជាងច្រែង រាក់ជាងចង្អេរអុំសម្រាប់ហាលឬសំដិល អ្វីៗ : អំបុកមួយចង្អេរកឡេប៊ី។ (ម.ព. កឡេប៊ី ផង)។

| | |
|---|---|
| ចចាម៉ារ៉ាម ☒ | ចចាមអារ៉ាម ☑ |

ចចាមអារ៉ាម

[ច-ចាម-អា-រ៉ាម]

គុ. ដែលលេចឮដោយនិយាយតៗគ្នា ពីមួយទៅមួយរកចុង រកដើមមិនឃើញ, ដែលមិនទាន់ប្រាកដ : ដំណឹងចចាមអារ៉ាម, សម្ដីចចាមអារ៉ាម។

| | |
|---|---|
| ចម្ប៉ាដក់ ☑ | ចម្ប៉ាដាក់ ☑ |

ចម្ប៉ាដាក់

[ចំ-ប៉ា-ដាក់]

ន. ឈ្មោះឈើមានផ្លែដូចខ្នុរ តែផ្លែតូចៗ ហើយមានក្លិនក្រអូប, ផ្អែមល្ហាន់ជាងខ្នុរ។ (ជួនគេហៅ ចម្ប៉ាដក់)។

| | |
|---|---|
| ចរចារ ☒ | ចរចា ☑ |

ចរចា

[ច-ចា]

កិ. និយាយប្រាស្រ័យ, សំណេះសំណាលរកគ្នា : គេកំពុងចរចាគ្នា; សត្វសារិកាកែវ វាកំពុងទំលើមែកឈើ វាចរចាគ្នា វាដូចមនុស្សយើងដែរហ្ន៎!

| | |
|---|---|
| ចារៈបុរស ☒ | ចារបុរស ☑ |

ចារបុរស

[ចា-រ៉ៈ-បុ-រ៉ស់] (បា. ចរបុរិស ឬ ចារបុរិស)

ន. អ្នកស៊ើបសួរ, អ្នកឈ្លប, អ្នកស៊ើបការណ៍សម្ងាត់។

ចឹញៀន ☒ ចិញ្ចៀន ☑

ចិញ្ចៀន១

[ចិញ-ចៀន]

ន. គ្រឿងប្រដាប់សម្រាប់ពាក់ម្រាមដៃមួយប្រភេទ ធ្វើដោយប្រាក់ឬដោយមាស មានរង្វង់មូល លាតឬដាំត្បូងផ្សេងៗ : ចិញ្ចៀនប្រាក់, ចិញ្ចៀនមាស, ចិញ្ចៀនពេជ្រ។

ចិញ្ចៀន២

[ចិញ-ចៀន]

ន. ឈ្មោះស្មៅមួយប្រភេទ : ស្មៅចិញ្ចៀន។

ចេតិយ៍ ☒ ចេតិយ ☑

ចេតិយ

[ចេ-ដី] ឬ [ចៃ-ដី] (បា.; សំ. ចៃត្យ)

ន. ទីដែលគេគោរពបូជា គឺទីណាមួយ ទោះមានដើមឈើធំជាប្រធានជាទីសម្គាល់ក្ដី, មានថ្មធំៗ ជាទីចំណាំក្ដី ។ល។ ដែលអ្នកផងគេសន្មត គេជឿថាជាទីស័ក្ដិសិទ្ធិ គេតែងធ្វើសក្ការបូជាគោរព ក៏ហៅ ចេតិយ ទាំងអស់; តែក្នុងប្រទេសយើងសព្វថ្ងៃនេះ ចំពោះតែគារវវត្ថុ ដែលគេកដោយឥដ្ឋជាដើម សម្រាប់តម្កល់សារីរិកធាតុនៃព្រះសម្មាសម្ពុទ្ធជាដើមនោះទើបហៅថា ចេតិយ (ខ្មែរហៅ ចៃដី ក៏មាន, ហៅក្លាយជា ចាយដី ក៏មាន); គួរសរសេរចេតិយឬចៃដី។

ចោមពង់ ☒ ចោមពុង ☑

ចោមពុង

[ចោម-ពុង]

កិ. ដណ្ដាប់សំពត់ព័ទ្ធក្រោមក្លៀកប្រសព្វជាយទាំងពីរខាងមុខបិទដោះ ហើយសៀតភ្ជាប់ចុកត្រសុកត្រង់ដើមទ្រូង : រដូវក្ដៅស្ត្រីសម័យពីដើមច្រើនតែចោមពុងធ្វើការ។ (ម.ព. ពុង ផង)។

ច្នៃប្រឌិត ☒ ច្នៃប្រតិដ្ឋ ☑

ច្នៃប្រឌិត

[ច្នៃ-ប្រ-ឌឹត]

កិ., គុ. មានសមត្ថភាពបង្កើតអ្វីៗទៅតាមទេពកោសល្យ : គាត់បានច្នៃប្រឌិតម៉ាស៊ីនភ្លើងដោយមិនប្រើប្រេង, គំនិតច្នៃប្រឌិត។

ប្រងេងប្រង៉ាង ☒ ប្រងេងប្រងាង ☑

ប្រងេងប្រងាង

[ប្រ-ង៉េង-ប្រ-ង៉ាង]

គុ.កិ., គុ. ដែលប្រងាង ទទឹងទទែងពេញពាស : ដាក់ឬស្សីរាយប្រងេងប្រងាងពេញផ្លូវ។

ប្រលំ ☒ ប្រទ្បំ ☑

ប្រទ្បំ

[ប្រ-ឡំ]

កិ., គុ. ដែលចំណាំមិនបាន ព្រោះលាយឡំគ្នា។

ច្រវ៉ាក់ ☒    ច្រវាក់ ☑

ច្រវាក់

[ច្រ-វ៉ាក់]

ន. ប្រដាប់ ធ្វើ ដោយដែកមានច្រួល មានកងចុងដើម សម្រាប់ដាក់មនុស្សទោស ឬសត្វចតុប្បាទ ឬក៏ប្រើចងក្រៀកអ្វីៗ ឱ្យមាំមួន។

ចំការ ☒    ចម្ការ ☑

ចម្ការ

[ចំ-កា]

ន. ទីដែលគេឆ្ការ សម្រាប់ដាំសរពើដំណាំ : ចម្ការឪឡឹក, ចម្ការមន, ចម្ការពោត។

ចំនី ☒ ចំណី ☑

ចំណី

[ចំ-ណី]

១). វត្ថុសម្រាប់ឆី, ខាទនីយវត្ថុ គឺអាហារដែលផ្អែម : ម្ហូប ចំណី គឺចម្អាបនិងបង្អែម។

២). គ្រឿងចិញ្ចឹមជីវិតរបស់សត្វតិរច្ឆានក៏ហៅថា ចំណី ដែរ : ស្មៅ, ស្លឹកឈើ ...ជាចំណីគោ, ក្របី។

ចំនុច ☒ ចំណុច ☑

ចំណុច

[ចំ-ណុច]

ន. ស្នាមដែលចុច : ចំណុចមួយ, ចំណុចពីរ, ចំណុចបី។

ចំរិត ☒ ចម្រិត ☑

ជំរិត

[ជុំ-រិត]

កិ. តឿនតឹងឱ្យបានឆាប់, បង្ខំទារ។

ចំរុះ ☒ ចម្រុះ ☑

ចម្រុះ

[ចំ-រ៊ុះ]

គុ. ដែលមានអាការៈច្រូងច្រាង លាយឡំគ្នា ច្រើនប្រភេទឬ ត្រៀបត្រាដូចគេច្រុះ : ផ្ទះចម្រុះគ្នា, បទចម្រៀងចម្រុះពីរោះៗ។

ចំលើយ ☒ ចម្លើយ ☑

ចម្លើយ

[ចំ-ឡើយ]

ន. ពាក្យឆ្លើយ, ការឆ្លើយ។

ចំហ ☒ ចំហរ ☑

ចំហ

[ចំ-ហ]

កិ., គុ.កិ. បើកឱ្យប្រហ : ចំហទ្វារ, ចំហបង្អួច; ចំហខ្លួន។

ច័ន្ទ ☒ ចន្ទ ☑

ចន្ទ១

[ច័ន] (បា.)

១). ន. សភាវៈសម្រាប់បំភ្លឺ ជាចម្បងជាងពន្លឺទាំងអស់ ដែលភ្លឺក្នុងវេលាយប់ : ព្រះចន្ទពេញវង់ ហៅតាមពាក្យធម្មតាថា លោកខែ, ខែរះ, ខែលិច, ខែភ្លឺ។

២). ផ្កាយរណបធម្មជាតិរបស់ផែនដី ហើយទទួលពន្លឺពីព្រះអាទិត្យ : ព្រះចន្ទវិលជុំវិញផែនដី។

ចន្ទ២

[ច័ន]

ន. ឈ្មោះថ្ងៃទី២នៃសប្តាហ៍ : ថ្ងៃចន្ទជាថ្ងៃដើមទ្រព្យ។

ចន្ទ៣

[ច័ន]

ន. ទេវៈតំណាងសោភណភាពនិងជាអ្នកថែរក្សារុក្ខជាតិ ហើយបើតាមទេវកថា ព្រះចន្ទកើតពីទឹកសោម (ស្រាសោមដែលគេថ្វាយព្រះឥន្ទ) ដូច្នេះហើយ បានមានឈ្មោះម្យ៉ាងទៀតថាព្រះសោម។

# ពាក្យផ្ដើមដោយព្យញ្ជនៈ

# ឆ

ឆក់ផ្លូន់ ☒ ឆក់ប្លូន់ ☑

ប្លន់

[ប្លន់]

កិ. ផ្ដុំ ឬចងគ្នា ជាពួក មានគ្រឿងសស្ត្រាវុធរាល់ ដៃចូលកំហែងគំរាមបៀតបៀនយកទ្រព្យគេ។

ឆ្គួត ☒ ឆ្កួត ☑

ឆ្កួត

[ឆ្កួត]

គុ. ដែលខូចសតិ, ខូចចរិត វិលវក់ឥតដឹងខុសត្រូវ : មនុស្សឆ្កួត, ឆ្កែឆ្កួត។

ឆ្នាស់ ☒ ឆ្នាស ☑

ឆ្នាស

[ឆ្នាស]

គុ. (និយាយអំពីស្រីៗ) ដែលហៃរករឿងឈ្លោះប្រកែក ជេរប្រទេចមិនព្រមចាញ់នរណា; ឬអំពីសត្វញីមានមាន់ជាដើម ដែលហៃដេញចឹកមាន់ឯទៀតនៅជិតៗ : ស្រីឆ្នាស, មេមាន់ហ្នឹងឆ្នាសណាស់។

ឆ្នាំកុល ☒ ឆ្នាំកុរ ☑

កុរ

[កុល]

ន. ឈ្មោះឆ្នាំទី១២(ជ្រូក) : ឆ្នាំកុរ។

| | |
|---|---|
| ឆ្វេងយល់ ☒ | ឈ្វេងយល់ ☑ |

ឈ្វេងយល់

[ឈ្វេង-យល់]

កិ. រំពឹងគិតយល់ដោយប្រាជ្ញាដ៏ភ្លឺថ្លា។

| | |
|---|---|
| ឆ័ត្រ ☒ | ឆត្រ ☑ |

ឆត្រ

[ឆាត់] (សំ.; បា. ឆត្ត)

ន. ប្រដាប់មានដងឆ្អឹង គន្លឹះ ពាសសំពត់ បើក តម្លោះបិទបាន សម្រាប់ បើកកាន់បាំងកម្ដៅ ថ្ងៃ, បាំងភ្លៀង : បើកឆត្រ, បាំងឆត្រ, តម្លោះឆត្រ។

ឈៀងចូល ☒ ឆៀងចូល ☑

ឆៀង

[ឆៀង]

គុ.កិ. ល្មៀងបន្តិចៗពីគ្នា : ស្ពាយឆៀងឬព័ទ្ធឆៀង គឺស្ពាយឬព័ទ្ធតែមួយចំហៀង។

ឈ្វេងដៃ ☒ ឆ្វេងដៃ ☑

ឆ្វេងដៃ

[ឆ្វេង-ដៃ]

ន. នៅផ្នែកខាងឆ្វេង,អ្វីៗដែលស្ថិតនៅខាងឆ្វេង : បើកបរនៅខាងឆ្វេងដៃ។

# ពាក្យផ្ដើមដោយព្យញ្ជនៈ

# ផ

ខន ស៊ាងហោ -៧៩

ជន់ជោ ☒ ជន់ជោរ ☑

ជោរ១

[ជោ]

កិ. ពោរឡើង : ទឹកជោរ (ព.ផ្ទ. នាច)។

ជោរ២

[ជោ]

កិ., គុ. ឡើងចិត្ត, ស្រស់ចិត្ត, រីកចិត្ត ដោយពាក្យបញ្ជោរ។

ជោរ៣

[ជោ]

គុ. ដែលញោស, ជ្រុលហួស : ទុំជោរ; ចាស់ជោរណាស់ហើយ។

| ជីវចម្រុះ ☒ | ជីវៈចម្រុះ ☑ |
|---|---|

ជីវៈចម្រុះ

[ជី-វៈ-ចំ-រ៉ុះ]

១). ន. ភាវៈរស់គ្រប់យ៉ាងដែលកើតឡើងដោយធម្មជាតិ ហើយមានជីវិតរស់នៅលើផែនដី។: តំបន់ជីវៈចម្រុះនៅប្រទេសកម្ពុជា។

២). បណ្តុំនៃសត្វនិងរុក្ខជាតិជាច្រើនប្រភេទនៅក្នុងតំបន់ណាមួយ : ជីវៈចម្រុះ សំដៅដល់សារពាង្គកាយខុសគ្នា នៅក្នុងប្រភេទតែមួយឬប្រភេទផ្សេងគ្នា។

| ជុំហរ ☒ | ជំហរ ☑ |
|---|---|

ជំហរ១

[ជុំ-ហ៊]

ន. កម្ពស់ដែលឈរ, ឥរិយាបថឈរ, ភាពដែលឈរ : មួយជំហារមនុស្ស។

ជំហារ២

[ជុំ-ហ៊ា]

គុ.កិ. ដែលឈរតែ, ដែលមិនសូវបានការ, បានតែខាងអួត, បានតែខាងស៊ីខាងចាយ ជាដើម : ជំហារតែថាឱ្យគេ, ជំហារតែអួត, ជំហារតែស៊ី, ជំហារតែចាយ

ជំហារ៣

[ជុំ-ហ៊ា]

ន. ទស្សនៈ, គោលការណ៍ : ជំហាររបស់ថ្នាក់ដឹកនាំ។

ជំហារ៤

[ជុំ-ហ៊ា]

ន. អ្នកដែលជាមនុស្សសំខាន់ឬបង្គោលក្នុងគ្រួសារឬក្នុងកិច្ចការអ្វីមួយ : គាត់ជាជំហារក្នុងគ្រួសារ។

| | |
|---|---|
| ជួន ☒ | ចួន ☑ |

ចួន១

[ចួន]

ន., គុ. ពាក្យរៀលរណ្ដំ : កាព្យនេះមានចួនល្អ, កាព្យនេះមានចុងចួនស្របពាក្យគ្នា, ចម្រៀងឥតចួន, ពាក្យចួន, ច្រៀងចួន។

ចួន២

[ចួន]

គុ.កិ. ដែលចួប, ដែលប្រទះ, ដែលរាប : ចួនក៏បាន, ចួនក៏មិនបាន។

| | |
|---|---|
| ជួបប្រសប់ ☒ | ជួបប្រសព្វ ☑ |

ប្រសព្វ

[ប្រ-សប់] (សំ. ប្រ + សវ ឬ សវន; បា. ប + សវ ប្រើជា ន."ការធ្វើ ហោមពិធី, ការបានសម្រេចប្រយោជន៍, ការបានប្រទះ, ការសម្រាលកូន ...")

កិ. ចួបប្រទល់មុខគ្នា; រួមចិត្តគំនិតគ្នា; នៅរួមសុខទុក្ខនឹងគ្នា : ប្ដីប្រពន្ធគេទាំងពីរនាក់នុះ មានអធ្យាស្រ័យល្អណាស់ តាំងពីប្រសព្វគ្នាមក មិនដែលពួឈ្លោះទាស់ទែងខ្វែងគំនិតគ្នាដល់ម្ដងណាឡើយ។

គុ.កិ., គុ. ដែលមានមុខប្រទល់រួមចូលគ្នា : ទន្លេប្រសព្វមុខ; ទឹកប្រសព្វគ្នា។

ជូរជាតិ ☒ ជូជាតិ ☑

ជូជាតិ

[ជូ-ជាត]

គុ. ដែលមានជាតិទន់ទាប, ថោកថយ; អាក្រក់ជូជាតិ គឺអាក្រក់ណាស់។

ជេ ☒ ជេរ ☑

ជេរ

[ជេ]

កិ. ពោលពាក្យអសប្បុរស ដោយកំហឹង ឬដោយអាការៈឡេះឡោះផងក៏មាន។

| | |
|---|---|
| ជេរប្រមាទ ☒ | ជេរប្រមាថ ☑ |

ប្រមាថ

[ប្រ-ម៉ាត] (សំ.)

ន. ការបៀតបៀនគេ, ការញាំញីគេ, ការធ្វើទុក្ខបុកម្នេញឱ្យគេលំបាក; ការមើលងាយគេ : មនុស្សប្រមាថចាស់ គឺមនុស្សមើលងាយចាស់។

កិ. បៀតបៀន, ញាំញីគេ, មើលងាយគេ : មនុស្សប្រមាថសត្វ គឺមនុស្សបៀតបៀនសត្វ។

| | |
|---|---|
| ជ្រាំង ☒ | ច្រាំង ☑ |

ច្រាំង

[ច្រាំង]

ន.រឹមស្នឹង, ទន្លេ, សមុទ្រ ...។ (គួរកុំច្រឡំពាក្យ ច្រាំង នេះនឹងពាក្យ ជ្រាំង)។

ជំងឺជំកាត់ ☒ ជំងឺតម្កាត់ ☑

តម្កាត់

[តំ-កាត់]

ន. ជំងឺតិចតួច, ជំងឺស្រាលៗ, ថ្កាត់។ ច្រើនតែប្រើជាបរិវារសព្ទ សម្រាប់ជារណបនឹងពាក្យជំងឺ : ជំងឺតម្កាត់។ (ម.ព. ថ្កាត់ ផង)។

ជំនុំ ☒ ជំនំ ☑

ជំនំ

[ជុំ-នំ]

គុ. ដែលទើបនឹងប្រើប្រាស់ទក់សាច់បន្តិចបន្តួច, ដែលស្ទើរថ្មីស្ទើរចាស់ : សំពត់ជំនំ។

| | |
|---|---|
| ជំនះ ☒ | ជម្នះ ☑ |

ជម្នះ

[ជុំ-នះ]

កិ. ធ្វើឱ្យឈ្នះ, បំពារ, ចចេសឱ្យតែឈ្នះ : ខ្ញុំហាមថាកុំឱ្យធ្វើ វាប្រឹងជម្នះធ្វើទាល់តែបាន។

ន. ការឈ្នះ, សេចក្តីឈ្នះ, ដំណើរដែលឈ្នះ : ចាំមើលរឿងនេះ ជម្នះនឹងបានទៅខាងណា?

| | |
|---|---|
| ជំរាបសួរ ☒ | ជម្រាបសួរ ☑ |

ជម្រាបសួរ

[ជុំ-រាប-សួ]

កិ., គុ.កិ., ឧ. សម្ដែងការគួរសមពេលជួបគ្នា : ជម្រាបសួរ ប្រិយមិត្ត!

| | |
|---|---|
| ជំរុំ ☒ | ជំរំ ☑ |

ជំរំ

[ជុំ-រុំ]

ន. ទីសម្រាប់ជ្រកអាស្រ័យបណ្ដោះអាសន្ន, ធ្វើដោយមែកឈើ ស្លឹកឈើឬចំបើង ជាដើម។

| | |
|---|---|
| ជំហ៊ាន ☒ | ជំហាន ☑ |

ជំហាន

[ជុំ-ហ៊ាន]

១). ន. រង្វាស់ដែលឈានជើងពី១ទៅ១, ចន្លោះជើងដែលឈានដើរ : ដើរមួយជំហាន, វាស់ពីរជំហាន។

២). ជំណាក់បន្តបន្ទាប់នៃសកម្មភាពដែលគេត្រូវធ្វើដើម្បីសម្រេចការអ្វីមួយ : រៀបគម្រោងសម្រាប់ជំហានបន្ទាប់។

| | |
|---|---|
| ជ័យឃោស ☒ | ជយឃោសន៍ ☑ |

ជយឃោស

[ជៈ-យៈ-ឃោស] ឬ [ជៃ-យៈ-ឃោស]

ន. ពាក្យស្រែកប្រកាស, ស្រែកហៅថា សូមឱ្យឈ្នះ! ឬថា ឈ្នះហើយៗ! ដូចពាក្យថា ជយតុ! ជយតុ ភវំ! ជយោ! ជិតំ ជិតំ! ជាដើមដែរ។ (ម.ព. ជយតុ! ជយតុ ភវំ! ជយោ! ជិតំ ជិតំ! ផង)។

| | |
|---|---|
| ជ័យមង្គល ☒ | ជយមង្គល ☑ |

ជយមង្គល

[ជៈ-យៈ-មង់-គល់] ឬ [ជៃ-មង់-គល់]

ន. ជម្នះនិងសេចក្ដីចម្រើន, សេចក្ដីចម្រើនព្រោះជ័យជម្នះ។

ជ័យវរ្ម័ន ☒ ជយវរ្ម័ន ☑

ជយវរ្ម័ន

[ជៈ-យៈ-វ័រ-ម៉ុន]

១). ន. អាវក្រោះមានជ័យ; អ្នកពាក់ក្រោះមានជ័យ។

ជយវរ្ម័ន

២). ន. ព្រះបរមនាមឬគោរមនៃព្រះបរមនាមរបស់ព្រះមហាក្សត្រិយ៍ក្នុងកម្ពុជរដ្ឋសម័យមហានគរ (សម័យនគរធំ) : ព្រះបាទជយវរ្ម័នទី៧ ...។

# ពាក្យផ្តើមដោយព្យញ្ជនៈ

# ញ

ខន សាំងហោ -៩១

ញញ្ញឹម ☒ ញញ្ញិម ☑

ញញ្ញឹម

[ញ-ញ្ញឹម]

កិ. សើចបិទមាត់មិនចេញសំឡេង : គាត់គ្រាន់តែញញ្ញឹម។

គុ. ដែលសើចបិទមាត់មិនចេញសំឡេង : មុខញញ្ញឹម, ស្រស់ញញ្ញឹម។

ញ៉ុម ☒ ខ្ញុំ ☑

ខ្ញុំ

[ខ្ញុំ] (សំ.បា. តាមលំអាន សំ.បា.ជាឧត្តមបុរិសៈ)

សព្វ. សម្ដីដែលសាមីខ្លួនហៅខ្លួនឯង : ខ្ញុំសុំអញ្ជើញបងទៅក្រុងព្រះសីហនុ ជាមួយនឹងខ្ញុំ បាន៣ថ្ងៃ។ (ម.ព. ទូលព្រះបង្គំ, ទូលព្រះបង្គំជាខ្ញុំ)។

ញាតសន្តាន ☒ ញាតិសន្តាន ☑

ញាតិសន្តាន

[ញាត-សន់-ដាន] (ជើង ត អានជា ដ) (បា. ញាតិ + សន្តាន; សំ. ជ្ញាតិ + សន្តាន)

ន. តំណឬវង្សនៃញាតិ,ញាតិវង្ស, តំណវង្សញាតិ; ត្រកូលដែលជាប់ជាញាតិ។ (ម.ព. ញាតិនិងសន្តាន ផង)។

# ពាក្យផ្ដើមដោយព្យញ្ជនៈ

# ជ

ដង្ហែរ ☒ ដង្ហែ ☑

ដង្ហែ

[ដង់-ហែ]

កិ., គុ.កិ. រៀបរៀងគ្នាជាជួរតាមមុនក្រោយមើលទៅឃើញមានរបៀបហូរហែ : ដើរដង្ហែគ្នារជយ។

ដុល្លា ☒ ដុល្លារ ☑

ដុល្លារ

[ដុល-ឡា] (អ. dollar)

ន. ឈ្មោះរូបិយវត្ថុរបស់សហរដ្ឋអាម៉េរិក។

ដុះខាត់ ☒ ដុសខាត់ ☑

ដុសខាត់

[ដុស-ខាត់]

កិ. ខាត់ជម្រះឱ្យស្អាត, ឱ្យរលីង, ឱ្យជ្រះអស់មន្ទិល។

ដូចច្នេះ ☒ ដូច្នេះ ☑

ដូច្នេះ

[ដូច-ច្នេះ]

គុ.កិ. ដូចនេះ, យ៉ាងនេះ ។

| | |
|---|---|
| ដើមទន់ ☒ | ដើមទុន ☑ |

ដើមទុន

[ដើម-ទុន]

ន. ប្រាក់ដើម សម្រាប់ប្រកបការងារយកចំណេញ : ក្រុមហ៊ុនត្រូវចំណាយដើមទុន ទិញវត្ថុធាតុដើម ឈ្នួល និងទិញសម្ភារៈវេចខ្ចប់។

| | |
|---|---|
| ដើមពោធិ ☒ | ដើមពោធិ៍ ☑ |

ពោធិ៍

[ពោ] (សំ.បា. ពោធិ)

ន. ឈើដែលព្រះមហាសត្វគង់អាស្រ័យក្នុងម្លប់ ទ្រង់ក៏បានត្រាស់ជាព្រះពុទ្ធ។ ឈើដែលហៅថា ពោធិ៍ៗ សព្វថ្ងៃនេះ តាមឈ្មោះដើមហៅថា អស្សត្ថឬអស្សត្ថព្រឹក្ស តែដោយហេតុដែលព្រះសក្យមុនីគោតមទ្រង់បានត្រាស់ជាព្រះពុទ្ធក្នុងម្លប់នោះ ក៏ក្លាយ

ឈ្មោះថា ពោធិ៍ឬពោធិទ្រុម, ពោធិព្រឹក្ស រៀងមក។ (ម.ព. ពោធិ៍បាយ ផង)។

| | |
|---|---|
| ដៀលត្មេះ ☒ | ដៀលត្មះ ☑ |

ដៀលត្មះ

[ដៀល-ត្មះ]

កិ. ដៀលឱ្យអាម៉ាស់មុខ, ឱ្យអាប់ឱនកេរ្តិ៍ឈ្មោះ, ឱ្យអាប់កិត្តិយស។

| | |
|---|---|
| ដេ ☒ | ដេរ ☑ |

ដេរ

[ដេ]

កិ. ភ្ជាប់អ្វីៗដោយម្ជុលនិងចេស : ដេរខោ, ដេរអាវ, ដេរផ្ទេរដៃ។

ដោយសា ☒ ដោយសារ ☑

ដោយសារ

[ដោយ-សា]

កិ. អាស្រ័យផង : ដោយសារទូកគេ, ដោយសាររទេះគេ។

ឈ. ព្រោះតែ, អាស្រ័យនឹង : រស់ដោយសារគេចិញ្ចឹម។

ដោះសា ☒ ដោះសារ ☑

ដោះសា

[ដោះ-សា]

កិ . រ៉ាយរ៉ាប់, រៀបរាប់, បូរបាច់, សាដំណើរ, សាទុក្ខ, សាទោស : វាបានមកដោះសារួចហើយ, និយាយដោះសា។

ដំកល់ ☒ តម្កល់ ☑

តម្កល់១

[តំ-កល់]

កិ. ទ្រឱ្យខ្ពស់ផុតពីទីប្រក្រតី, ថ្កល់លើអ្វីៗ, តាំង : តម្កល់គ្រឿងសក្ការបូជា។

តម្កល់២

[តំ-កល់]

កិ. រក្សាទុក, ដាក់ប្រាក់ឬវត្ថុមានតម្លៃអ្វីមួយជារបស់ធានា : តម្កល់ឯកសារជាតិ, តម្កល់ប្រាក់កក់។

ដំនឹង ☒ ដំណឹង ☑

ដំណឹង

[ដំ-ណឹង]

ន. សេចក្ដីដែលឱ្យដឹង, សេចក្ដីដែលដឹង, ការដឹង : ឮដំណឹង, មានដំណឹង។

| | |
|---|---|
| ដំបូមាន ☒ | ដំបូន្មាន ☑ |

ដំបូន្មាន

[ដំ-បូន-មាន]

ន. សេចក្ដីទូន្មាន, ឱវាទ, ពាក្យប្រដៅ : ឱ្យដំបូន្មាន, ស្ដាប់ដំបូន្មាន។

| | |
|---|---|
| ដំលើង ☒ | ដំឡើង ☑ |

ដំឡើង១

[ដំ-ឡើង]

កិ. ធ្វើឱ្យឡើង, ធ្វើឱ្យខ្ពស់ជាងមុន, ធ្វើឱ្យមានកម្លាំង, ធ្វើឱ្យឃើញសម្បើម : ដំឡើងពន្ធដារ, ដំឡើងថ្លៃអីវ៉ាន់, ដំឡើងស្នា, ដំឡើងគ្រូ, ដំឡើងឫក, ដំឡើងឫទ្ធិ។

ដំឡើង២

[ដំ-ឡើង]

កិ. លើកផ្គុំរៀបចំតាមលំនាំស្រាប់ : ដំឡើងរទេះ, ដំឡើងរថយន្ត។

ដំឡើង៣

[ដំ-ឡើង]

គុ., ន. ឈ្មោះរដូវដែលទឹកឡើង : រដូវដំឡើង, ខែដំឡើង។

| | |
|---|---|
| ដ៏ទៃ ☒ | ដទៃ ☑ |

ដទៃ

[ដ-ទៃ]

គុ. សព្វ, ឯទៀត, ក្រៅអំពី : អ្នកដទៃ, មនុស្សដទៃ, ជនដទៃ, រឿងដទៃ។ល។

ដង្កៀបក្ដាម ☒ តង្កៀបក្ដាម ☑

តង្កៀបក្ដាម១

[តង់-កៀប-ក្ដាម]

ន. ជើងធំរបស់ក្ដាមមានតង្កៀបកៀបបាន។

តង្កៀបក្ដាម២

[តង់-កៀប-ក្ដាម]

ន. ឈ្មោះឈើមួយប្រភេទ មានផ្លែល្អិតៗ ជាចង្កោមៗ ប្រើជាម្ជូរ។

# ពាក្យផ្ដើមដោយព្យញ្ជនៈ

# ប

ឋានន្តរស័ក្តិ ☒ ឋានន្តរសក្តិ ☑

ឋានន្តរសក្តិ

[ឋា-ណន់-តៈ-រ៉ៈ-ស័ក] (សំ.បា.; សំ. ស្ថានន្តរ + សក្តិ)

ន. អំណាចតាមមុខងារ, បណ្តា ស័ក្តិ ធំ តូចតាមមុខងារ : អង្គុយតាមឋានន្តរស័ក្តិ។ (ម.ព. សក្តិឬស័ក្តិ ផង)។

# ពាក្យផ្តើមដោយព្យញ្ជនៈ

# ត

តិរិច្ឆាន ☒ តិរច្ឆាន ☑

តិរច្ឆាន

[តិ-រ៉ាច់-ឆាន] ឬ [ដិ-រ៉ាច់-ឆាន] (បា.; សំ. តិរគ្ចីន)

ន. សត្វដែលមានរាងកាយចម្រើនដោយទទឹង ទីទៃពីសត្វដែលមានរាងកាយចម្រើនដោយត្រង់ដោយបញ្ឈរ, បានខាងចំពួកសត្វនានាដែលកើតក្នុងមនុស្សលោក មានរាងកាយជាក់ស្តែងទៅមកដោយទ្រេត, ដោយផ្តេក ដូចយ៉ាង គោ, ក្របី, ដំរី, សេះ។ល។ ជាសត្វផ្សេងទីទៃពីមនុស្សដែលហៅដោយរួបរួមថា សត្វ ដែរ ព្រោះមានចិត្តជំពាក់ក្នុងអារម្មណ៍ផ្សេងៗ ប៉ុន្តែមានរាងកាយទៅមកដោយត្រង់ដោយបញ្ឈរ។

តុកែ ☒ តុកកែ ☑

តុកកែ១

[តុក-កែ]

ន. (ម.ព. តឹកកែ)។

តុកកែ២

[តុក-កែ]

ន. ឈ្មោះពស់មួយប្រភេទមាឌតូចវៀវ សម្បុរបៃតង ជួនកាលលូនឡើងនៅក្រោមដំបូលផ្ទះ, កាលបើតុកកែឃើញ តែងតែហាមាត់ធំ បើកឱកាសឱ្យពស់នេះចូលស៊ីថ្លើម, តុកកែក៏នៅតែរស់ ប៉ុន្តែឈប់លែងយំអស់កាលយូរ, លុះថ្លើមដុះធំឡើងវិញទើបយំ ពស់នេះក៏ចូលស៊ីថ្លើមទៀត (ពាក្យតំណាល): ពស់តុកកែ។

តុកកែ៣

[តុក-កែ]

ន. ត្រីសមុទ្រមួយប្រភេទរាងសំប៉ែត មាត់ធំ ភាគច្រើនមានសម្បុរបៃតងឬត្នោត ខ្លះមានក្រឡាស្រដៀងសត្វតុកកែឬប្តូរពណ៌តាមកាលវេលា: គេអាចនេសាទត្រីតុកកែបានដោយប្រើឧបករណ៍មុជទឹកឬក៏មានការចិញ្ចឹមវាដាក់ក្នុងបែផងដែរ។

| | |
|---|---|
| តេះដៀល ☒ | តិះដៀល ☑ |

តិះដៀល

[តិះ-ដៀល]

កិ. មើលអត្ថន័យរបស់ពាក្យ តិះនិងតំណិះ, ដំណៀល ផង។

| | |
|---|---|
| ត្រជាក់ត្រជុំ ☒ | ត្រជាក់ត្រជំ ☑ |

ត្រជាក់ត្រជំ

[ត្រ-ជាក់-ត្រ-ជុំ]

គុ. (ព.ប្រ.) ដែលប្រកបដោយសេចក្តីសុខសេចក្តីចម្រើន, កើតកាលវាលគុម្ព, ធូរដៃ, ធូរជើង, កបកើតកូនចៅ : រកស៊ីត្រជាក់ត្រជំសមតាមបំណង។

| | |
|---|---|
| គ្រប់លំញង ☒ | គ្រប់ពុតលំញង ☑ |

ពុតលំញង

[ពុត-លំ-ញង]

ន. ឈ្មោះគ្រប់មួយប្រភេទ គឺគ្រប់ដែលអ្នកស្រុកខ្លះហៅគ្រប់លំញង នុះឯង : គ្រប់ពុតលំញង។ (ម.ព. លំញង២ ផង)។

ត្រយ៉ង ☒ ត្រយង ☑

ត្រយង

[ត្រ-យ៉ង]

ន. ឈ្មោះបក្សីមួយប្រភេទពួកកុក, មានសម្បុរខ្មៅប្រផេះ ចំពុះខុបស្រួច, ស្រែកយំថ្ងូរមានសូរសព្ទតូចគ្រលួចស្រួយស្រួចគួរ ឱ្យស្រណោះស្រងេះស្រងោច។

តំរង់ ☒ តម្រង់ ☑

តម្រង់

[តំ-រ៉ង់]

កិ., គុ.កិ. ធ្វើឱ្យត្រង់, ដាក់សំដៅឱ្យចំ; ដែលកាត់យកត្រង់, ដែលសំដៅចំពោះ : តម្រង់ផ្លូវ, តម្រង់បង្គោល; ដើរតម្រង់; ដើរកាត់ តម្រង់។

តំរូវ ☒ តម្រូវ ☑

តម្រូវ

[តំ-រ៉ូវ]

កិ., គុ.កិ. ធ្វើឱ្យត្រូវ, ចែកមុខ, ទុកដាក់មុខងារ : តម្រូវការឱ្យធ្វើ; កែតម្រូវ។

តំលៃ ☒ តម្លៃ ☑

តម្លៃ

[តំ-ឡៃ]

ន. អ្វីៗដែលថ្លៃ, ប្រាក់ដែលត្រូវសងដល់អ្នកដទៃដោយខ្លួនបានទិញវត្ថុអ្វីៗពីគេ : របស់មានតម្លៃ, អស់តម្លៃ, ចុះតម្លៃ, សងតម្លៃ។

# ពាក្យផ្ដើមដោយព្យញ្ជនៈ

# ថ

ថវិការ ☒ ថវិកា ☑

ថវិកា

[ថៈវិ-កា] (បា.)

១). ន. ថង់; យាម; ថៃ។

២). សព្វថ្ងៃពាក្យនេះប្រើសំដៅយកបញ្ជីដែលគ្រោងឬកត់ត្រាទុកនូវប្រាក់ចំណូលនិងចំណាយរៀងរាល់ឆ្នាំ ប្រៀបដូចជាថង់សម្រាប់ដាក់ប្រាក់ : គ្រោងថវិកា, ចាយវាយប្រាក់កុំឱ្យហួសលើសពីថវិការបស់ខ្លួន។

៣). ចំនួនទឹកប្រាក់ដែលមានសម្រាប់ចំណាយលើអ្វីមួយ។

ថ្មើនថ្កាន ☒ ថ្មើងថ្កាន ☑

ថ្មើង

[ថ្មើង]

គុ. ឧត្តុង្គ, ឧត្តម, ខ្ពង់ខ្ពស់, មានយសបរិពារ, មានគេចុះចូលរាប់អានច្រើន : ប្រទេសថ្កើង, ជាតិថ្កើង។

| | |
|---|---|
| ថ្មីស្រឡាង ☒ | ថ្មីសន្លាង ☑ |

សន្លាង

[សន់-ឡាង]

១). គុ. សជ្រះស្អាត : សសន្លាង។

២). ថ្មីទែង, ថ្មីស្អាត : ថ្មីសន្លាង។

៣). ដែលល្អសមរម្យមិនឆ្គង : ល្អសន្លាង, រូបល្អសន្លាង។

| | |
|---|---|
| ថ្មើជើង ☒ | ថ្មើរជើង ☑ |

ថ្មើរជើង

[ថ្មើ-ជើង]

ន. ទាហានអ្នកដើរដោយជើង : ទាហានថ្មើរជើង, ពលថ្មើរជើង។

# ពាក្យផ្ដើមដោយព្យញ្ជនៈ

# ទ

ទងហ្វង ☒ ទងវង ☑

ទងវង

[ទង-វង]

គុ. ទ្រទេសទ្រទន់, ល្វាសល្វន់, ល្វតល្វៃសមរម្យ (ប្រើតែក្នុងកាព្យ) : ឱមាសមិត្រទងវង ម្ដេចមករងទុក្ខខ្លាំងក្រៃ ព្រោះស្រីថ្លៃហុចផ្ដល់ឱ្យនាងទេដឹង។

ទណ្ឌឃាត ☒ ទណ្ឌឃាដ ☑

ទណ្ឌឃាដ

[ទ័ន-ឌ:-ឃាត] (បា.)

១). ន. ការពិឃាតដោយអាជ្ញា, ដោយដំបង, កំណាត់ឈើជាគ្រឿងពិឃាត។

២). ខ្មែរយើងប្រើពាក្យនេះជាឈ្មោះវណ្ណយុត្តម្យ៉ាងមានសណ្ឋានលំនាំកន្ទុយកំប្រុក (៍) សម្រាប់ដាក់ឃាត់អក្សរមិនឱ្យមានសំឡេងដូចជា ប្រយោជន៍, យោជន៍, ខ្លឹមចន្ទន៍ ជាដើម; វណ្ណយុត្តនេះ បើហៅថា បដិសេធ ក៏បាន ចំពោះភាសាសំស្ក្រឹតដែលសរសេរជាអក្សរទេវនាគរី, ទណ្ឌឃាតនេះ ហៅថា វិរាម មានរូបដូច្នេះ (^) សម្រាប់ប្រើដាក់ពីក្រោមតួអក្សរក្រោយបង្អស់ ដែលទុកគ្រាន់តែជាតួប្រកបប៉ុណ្ណោះ មិនឱ្យចេញសំឡេង ដូចជាពាក្យថា កម៌ន^, តបស^, តេជស^, អាត្មន^, ជាដើម។ ប៉ុន្តែចំពោះភាសាសំស្ក្រឹតដែលសរសេរជាអក្សរខ្មែរ, យើងសន្មតសញ្ញាទណ្ឌឃាតនេះដូច្នេះវិញ (៑) សម្រាប់ដាក់ពីលើតួអក្សរក្រោយបង្អស់នោះៗ ដែលគ្រាន់តែជាតួប្រកបមិនឱ្យចេញសំឡេងដូចគ្នាដែរដូចជា កម៌ន៑, តបស៑, តេជស៑, អាត្មន៑ (អ.ថ. ក័ន្ម, ត:ប៉ុស, តេជ័ស, អាត្ម័ន) ជាដើម។

ទណ្ឌបណ្ឌិត ☒ ទន្តបណ្ឌិត ☑

ទន្តបណ្ឌិត

[ទ័ន-តៈ-បន់-ឌិត]

ន. វេជ្ជបណ្ឌិតដែលមានជំនាញខាងធ្មេញ : ទន្តបណ្ឌិតស្ម័គ្រចិត្តព្យាបាលមាត់ធ្មេញជូនប្រជាជនដោយឥតគិតថ្លៃ។

| | |
|---|---|
| ទន់ទោ ☒ | ទន់ទោរ ☑ |

ទន់ទោរ

[ទន់-ទោ]

គុ. (ម.ព. ទោរទន់)។

| | |
|---|---|
| ទសពិតរាជធម៌ ☒ | ទសពិធរាជធម៌ ☑ |

ទសពិធរាជធម៌

[ទៈ-សៈ-ពិ-ធៈ-រា-ជៈ-ធ័រ] ឬ [ទស់-សៈ-ពិត-រា-ជៈ-ធ័រ] (បា. ទសវិធ + រាជធម្ម)

ន.រាជធម៌១០យ៉ាង គឺធម៌១០ប្រការ សម្រាប់ព្រះរាជាទ្រង់ប្រព្រឹត្ត ព្រមទាំងណែនាំពួកសេនាបតីមន្ត្រីធំតូចនិងពួករាស្ត្រប្រជាឱ្យប្រព្រឹត្តផង។ ទសពិធរាជធម៌នោះ គឺ ១-ទានៈ ការធ្វើអំណោយ; ២-សីលៈ ការរក្សាសីល៥ជានិច្ចឬរក្សាសីល១០មួយដងមួយកាល; ៣-បរិច្ចាគៈ ការចំណាយព្រះរាជទ្រព្យទំនុកបម្រុងប្រទេសជាតិ; ៤-អាជ្ជវៈ មានសេចក្តីត្រង់; ៥-មទ្ទវៈ មានសេចក្តីទន់ភ្លន់ស្លូតសុភាពរាបសា; ៦-តបៈ ការកាន់ឧបោសថសីលតាមកាលកំណត់ម្តងៗ; ៧-អក្កោធនៈ មិនកម្តៅក្រហាយអ្នកដទៃ; ៨-អវិហឹសា មិនបៀតបៀនអ្នកដទៃ; ៩-ខន្តិ មានសេចក្តីអត់ធន់; ១០-អវិរោធនៈ មិនបំពានលើធម៌លើច្បាប់។ ច្រើនប្រើកាត់ខ្លីត្រឹមតែទសពិធឬទសពិធធម៌។

ទាញព្រាត់ ☒ ទាញព្រ័ត្រ ☑

ទាញព្រ័ត្រ

[ទាញ-ព្រាត់]

ន. ឈ្មោះល្បែងមួយប្រភេទមានមនុស្សពីរពួក ច្រើនតែពួកប្រុសម្ខាងពួកស្រីម្ខាង ទាញកន្ទុយព្រ័ត្រឬពួរទាំងពីរខាងដោយប្រឹងពេញទំហឹង ល្បងកម្លាំងគ្នា យកឈ្នះ, ខាងណាខ្សោយជាងខាងនោះចាញ់ : លេងទាញព្រ័ត្រ (ជាល្បែងហាត់ប្រាណ)។

| ទាយក់ ☒ | ទាយក ☑ |
|---|---|

ទាយក១

[ទា-យក់] (សំ.បា.)

ន. បុរសអ្នកឱ្យទាន។

ទាយក២

[ទា-យក់]

ន. (ច្ប.) ភាគីម្ខាងនៃកិច្ចសន្យាប្រទានកម្មដែលបង្ហាញឆន្ទៈផ្ដល់ទៅឱ្យភាគីម្ខាងទៀតនូវទ្រព្យសម្បត្តិដោយមិនយកថ្លៃ។

| ទាយាទ ☒ | ទាយាទ ☑ |
|---|---|

ទាយាទ

[ទា-យាត] (សំ.បា.)

១). ន. បុត្រ, បុត្រី; ញាតិ។

២). អ្នកដែលត្រូវទទួលទ្រព្យសម្បាច់, ដែលត្រូវទទួលមរតក។ អ្នកដែលបន្តវង្សត្រកូល។

ទាល់ច្រក ☒ ទ័លច្រក ☑

ទ័ល

[ទាល់] (សំ.បា. ទល កិ."កាត់, ពុះ, ចោះ, ចាក់, ចែក, ទើស, ទាក់, ក្រីក្រ ..."; ន."ស្លឹកឈើ, ចំណែក")

កិ. ទើសផ្លូវ, ទើសដំណើរ : ទ័លផ្លូវ, ទ័លគំនិត, ទ័លទ្រព្យ។

គុ. ដែលក្រីក្រទ្រព្យ, ខ្សត់ទ្រព្យ : មនុស្សទ័ល, អ្នកទ័ល។ (ច្រើនសរសេរក្លាយជា ទាល់ ដូច្នេះយូរហើយចំពោះការក្រីក្រគួរសរសេរ ទ័លវិញ)។

| | |
|---|---|
| ទាហ៊ាន ☒ | ទាហាន ☑ |

ទាហាន

[ទា-ហ៊ាន]

១). កិ. ហ៊ាន, ហានក្លា, មិនខ្លាច : មាណពនោះទាហានណាស់។

២). គុ. ដែលហ៊ាន, ដែលហានក្លា : មនុស្សទាហាន, ក្មេងទាហាន។

៣). ន. អ្នកហានក្លា, អ្នកមិនខ្លាច, អ្នកច្បាំង, យោធា, សេនាក្នុងក្រុមយុទ្ធនា : ទាហានជើងគោក, ទាហានជើងទឹក, ទាហានជើងអាកាស។

| | |
|---|---|
| ទិដ្ឋការ ☒ | ទិដ្ឋាការ ☑ |

ទិដ្ឋាការ

[ទិត-ឋា-កា] (បា. ទិដ្ឋ + អាការ)

១). ន. អាការៈដែលបានឃើញ, បានចួបប្រទះមកហើយ។

២). ហត្ថលេខាជាចាំបាច់ នៃអ្នករាជការមានសមត្ថកិច្ចដែលត្រូវចុះលើលិខិតផ្សេងៗ មានលិខិតឆ្លងដែននិងអាណត្តិបើកប្រាក់ជាដើម ជាការបញ្ជាក់ថាខ្លួនបានពិនិត្យឃើញត្រឹមត្រូវហើយ : លិខិតនេះ មានទិដ្ឋាការពីក្រុមសន្តិសុខជាតិហើយឬនៅ?; អាណត្តិបើកប្រាក់នេះ ក្រុមអភិបាលប្រាក់ចំណាយមិនទាន់ចុះទិដ្ឋាការនៅឡើយទេ ព្រោះមានការទាស់ខុស ...។

៣). សេចក្ដីអនុញ្ញាតបិទភ្ជាប់លើលិខិតឆ្លងដែនដែលបញ្ជាក់ឱ្យដឹងថាអ្នកកាន់លិខិតឆ្លងដែននោះអាចចូល ស្នាក់នៅ និងចាកចេញពីប្រទេសដែលផ្ដល់ការអនុញ្ញាតនោះក្នុងកាលកំណត់ណាមួយ : រៀបចំឯកសារដើម្បីស្នើសុំទិដ្ឋាការទៅកាន់ប្រទេសក្រៅ។

ទីផ្សា ☒ ទីផ្សារ ☑

ទីផ្សារ

[ទី-ផ្សា]

១). ន. (ម.ព. ផ្សារ១)។

២). ការងារដែលពាក់ព័ន្ធក្នុងការជំរុញឱ្យមនុស្សទិញផលិតផលឬសេវាកម្មផ្សេងៗ : ការកាត់ចំណែកទីផ្សារត្រូវបានគេអនុវត្តតាមរយៈការកំណត់អថេរនិងការបែងចែកតម្លៃអថេរតាមប្រភេទ។

ទឹកអូ ☒ ទឹកអូរ ☑

អូរ

[អូ]

ន. ជ្រលងជាផ្លូវទឹកដែល, ក្នុងរដូវភ្លៀង, មានទឹកហូរចូលមកក្នុងនទីឬក្នុងបឹង, ក្នុងសមុទ្រ : ទឹកអូរតូចធំហូរប្រជុំចុះមកក្នុងនទី។

ទុកធុរៈ ☒ ទុក្ខធុរៈ ☑

ទុក្ខធុរៈ

[ទុក-ធុ-រៈ]

ន. ការមានទុក្ខកង្វល់, មានទុក្ខព្រួយនាំឱ្យរវល់ខ្វល់ខ្វាយក្នុងចិត្ត : តាំងពីឪពុកខ្ញុំអនិច្ចធម្មទៅ ខ្ញុំត្រូវរងនូវទុក្ខធុរៈច្រើនបែបយ៉ាង។

ទុចរិត ☒ ទុច្ចរិត ☑

ទុច្ចរិត

[ទុច-ចៈ-រិត] (បា.; សំ. ទុឝ្ចរិត)

ន. ដំណើរប្រព្រឹត្តអាក្រក់ដោយកាយ, វាចា, ចិត្ត, (អកុសល) : គប្បីវៀរចាកទុច្ចរិត, ទុច្ចរិតជាអំពើដែលបណ្ឌិតត្រូវតែចៀសវាង។ (ព.ផ្ទ. សុចរិត)។

ទុរគត់ ☒ ទុរគត/ទុរគ៌ត ☑

ទុរគត

[ទុ-រៈ-គត់]

គុ. (ម.ព. ទុគ្គត)។

ទុរយស់ ☒ ទុរយស/ ទុរយ៏ស ☑

ទុរយស

[ទុ-រៈ-យស់]

គុ., ន. (ម.ព. ទុយ៏ស)។

ទេពកោសល ☒ ទេពកោសល្យ ☑

ទេពកោសល្យ

[ទេប-កោ-សល់]

ន. ភាពជាអ្នកវាងវៃយ៉ាងឆ្នើមពីធម្មជាតិ, ភាពប៉ិនប្រសប់យ៉ាងខ្ពស់ : អ្នកមានទេពកោសល្យ, ទេពកោសល្យស៊ីវិល។

ទេព្ដារ ☒ ទេព្ដា ☑

ទេព្ដា

[ទេ-ប្ដ៉ា]

ន.(ម.ព. ទេពតា)។

ទ្រុតទ្រោម ☒ ទ្រុឌទ្រោម ☑

ទ្រុឌទ្រោម

[ទ្រុឌ-ទ្រោម]

គុ.ទ្រុឌផងទ្រោមផង។

| | |
|---|---|
| ទ្វេរ ☒ | ទ្វេ ☑ |

ទ្វេ

[ទ្វេ] (បា. ទ្វិ > ទ្វេ)

គុ. ពីរ : កាន់តែទ្វេឡើង គឺកាន់តែថែមឡើងឬចម្រើនឡើងមួយជាពីរ។

| | |
|---|---|
| ទំលាក់ ☒ | ទម្លាក់ ☑ |

ទម្លាក់

[ទុំ-លាក់]

កិ. ធ្វើឱ្យធ្លាក់; លែងចោលឱ្យរបូតជ្រុះធ្លាក់ : ទម្លាក់ផ្លែឈើ។

ទំលាយ ☒ ទម្លាយ ☑

ទម្លាយ

[ទុំ-លាយ]

កិ. ធ្វើឱ្យធ្លាយ : ទម្លាយទំនប់; បិទថ្នាំទម្លាយបូស។

# ពាក្យផ្ដើមដោយព្យញ្ជនៈ

# ផ

ធរមៀន ☒ ធរមាន ☑

ធរមាន

[ធៈ-រៈ-មាន] (បា.; សំ. ធរមាណ)

គុ. ដែលកំពុងទ្រទ្រង់នៅ, ដែលមានជីវិតរស់នៅ : កាលព្រះសម្មាសម្ពុទ្ធទ្រង់ធរមាននៅឡើយ ...។

ធ្វូក ☒ ធូប ☑

ធូប

[ធូប] (សំ.បា.)

ន. គ្រឿងក្រអូបធ្វើដោយលម្អិតសំបកឈើ, ខ្លឹមឈើឬជ័រឈើមានក្លិនក្រអូបប្រហើរ, លញ់សូនដោយបន្ទោះជាស្នូលឬឥត

ស្នូលក៏មានខ្លះ សម្រាប់អុជបង្ហុយផ្សេងជាគ្រឿងបូជា (ជាគូគ្នានឹងទៀន)។

ផ្នើរ ☒ ផ្នើ ☑

ផ្នើរ

[ផ្នើ]

ន. ថ្នាក់ខ្ពស់សម្រាប់បន្ទើរវត្ថុផ្សេងៗ : ដាក់កន្ទេលលើផ្នើរ, នៅលើផ្នើរ។

# ពាក្យផ្ដើមដោយព្យញ្ជនៈ

# ន

នគរាជ ☒ នគររាជ ☑

នគររាជ

[ន-គ-រាច]

ន. ឈ្មោះបទភ្លេងខ្មែរបុរាណមួយមេ : បទភ្លេងនគររាជជាអនុស្សរណៈដល់ខេត្តចាស់របស់ប្រទេសកម្ពុជា ក្នុងសម័យបុរាណព្រេងនាយដែលឃ្លាតចេញពីប្រទេសខ្មែរទៅដោយខ្មែរបែកសាមគ្គី ...។

នណា ☒ នរណា ☑

នរណា

[ន-ណា]

ន. ប្រើជាបុច្ឆាសព្វនាមថា មនុស្សណា? អ្នកណា?; នរណាដើរនុ៎ះ?; ឯងទៅជាមួយនឹងនរណា? (ប្រើបានចំពោះតែជាមួយនឹង

ណា ប៉ុណ្ណោះឯង, ពុំដែលប្រើជាមួយនឹងពាក្យ នុះឬនោះ ថា នរនុះ ឬនរនោះ ផងទេ, បើ នរៈឬអ្នក ប្រើបាន : នរៈនុះ, អ្នកនោះ)។ (ម.ព. នរៈនិងនរូ ផង)។

| | |
|---|---|
| និគមន៍ ☒ | និគម ☑ |

និគម

[និ-គុំ] (សំ.បា.)

១). ន. ប្រជុំភូមិច្រើន គឺតំបន់ដែលមានមេភូមិម្នាក់ជាអ្នកត្រួតត្រា។

២). ទីផ្សារនីមួយៗក្នុងខេត្តក្រៅ (ពាក្យនេះមានប្រើតែពីក្នុងសម័យបុរាណ)។

| | |
|---|---|
| នឹងន ☒ | នឹងនរ ☑ |

នឹងនរ

[នឹង-ន]

គុ. ដែលមិនកែប្រែឬមិនតក់ស្លុត, នឹងធឹង; ដែលធម្មតា (មិនខុសប្រក្រតី) : ចរិតនឹងនរ, ស្មារតីនឹងនរ, ប្រកាន់ចិត្តនឹងនរ; មនុស្សមានសតិមិននឹងនរ, ស្ថានការណ៍មិននឹងនរ។

និតិ ☒ នីតិ ☑

នីតិ

[នី-តិ] (បា. សំ.)

ន. ច្បាប់; ឧបាយជាគ្រឿងណែនាំ; បែបផែន; ទំនឹមទំនៀម, ប្រពៃណី។

និព្វាន្ត ☒ និព្វាន ☑

និព្វាន

[និប-ពាន] (មកពី សំ. ថា និស៑ "ចេញ, ចេញផុត, ចេញផុតស្រឡះ; អស់, ឥត" + វាន "ជាឈ្មោះតណ្ហាដែលចាក់ស្រេះ, ទាក់ឆ្វាក់, រួបរឹតក្នុងសន្ដានចិត្តសត្វ", និស៑ > និរ៑ + វាន > វាណ = និរ្វាណ; បា. និ + វាន, ដោយអនុលោមតាម សំ. គឺឱ្យមានសំឡេងធ្ងន់ដូច សំ. ដែរ និ + វាន, វ > ព តម្រួត ព > ព្វ = និព្វាន

ន. មានអត្ថន័យដូច សំ. ដែរ គឺជាឈ្មោះធម្មជាតឬចិត្តដែលចេញផុតស្រឡះចាកវានៈ គឺឥតមានតណ្ហាដែលចាក់ស្រេះទាក់ឆ្វាក់រួបរឹត, ដោយបរិយាយថា អស់មានកម្មដដែលៗ តទៅទៀតហើយ សំដៅចំពោះ ខន្ធនិព្វាន របស់ព្រះពុទ្ធ, ព្រះបច្ចេកពុទ្ធ, ព្រះអរហន្តខីណាស្រព, ប៉ុន្តែពាក្យ និព្វានឬនិរ្វាណ នេះមានមគ្គ៤ផល៤ជាសមុទ័យឬជាប្រភពឱ្យកើតបានជា កិលេសនិព្វានឬក្លេសនិរ្វាណ ក៏ពុំទាន់ចេញផុតស្រឡះចាកកម្មដដែលៗ នៅឡើយ លុះដល់បញ្ចក្ខន្ធរលត់ហើយ ទើបមានឈ្មោះថា ខន្ធនិព្វានឬស្កន្ធនិរ្វាណ អស់មានកម្មដដែលៗតទៅទៀត នៅមានសុទ្ធតែ បរមសុខ ហៅថាឯកន្តបរមសុខ តែមួយយ៉ាងប៉ុណ្ណោះឯង : និព្វានជាបរមត្ថធម៌ មានអត្ថន័យសុខុមល្អិតហួសវិស័យនៃសាធារណសត្វបុថុជ្ជន បើលុះ

តែបុថុជ្ជនអ្នកធុញទ្រាន់នឿយណាយរសាយចិត្ត ឃ្លាតចាកបុនប្បុនក្កម្ម គឺកម្មដដែលៗ ទើបយល់ឃើញព្រឹលៗ ថាមាននិព្វានពិតមែន ...(ព.និ.)។

និស្សយ ☒ និស្ស័យ ☑

និស្ស័យ

[និស-សៃ] (បា. និស្សយ)

១). ន. ការនៅអាស្រ័យក្រោមឱវាទនិងក្រោមការគ្រប់គ្រងនៃអ្នកដទៃ។

២). ជនជាពំនាក់, ជាអ្នកទំនុកបម្រុង : ខ្ញុំប្រកបជំនួញធំពុំកើត ព្រោះគ្មាននិស្ស័យ គឺគ្មានអ្នកទំនុកបម្រុង។

ហ្នឹងថ្កល់ ☒ នឹងថ្កល់ ☑

នឹង២

[នឹង]

១). គុ., គុ.កិ. ស្ងៀម, ជើយ, មិនកម្រើក : អង្គុយនឹងថ្កល់ គឺអង្គុយនឹងដូចគេថ្កល់។
២). មិនប្រែប្រួល, មិនឡើងមិនចុះ, នៅដូចដែល : ជំងឺនុំះនៅនឹង។ ទឹកនឹង គឺទឹកដែលមិនឡើងមិនស្រកឬមិនហូរ។

# ពាក្យផ្ដើមដោយព្យញ្ជនៈ

# ប

បង្ករ ☒ បង្ក ☑

បង្ក

[បង់-ក]

កិ. ធ្វើឱ្យកកើតឡើង : បង្កហេតុ, បង្កជម្លោះ, បង្កក្ដី។

បង្កា ☒ បង្ការ ☑

បង្ការ១

[បង់-កា]

កិ. រារាំង, ប្រុងប្រយ័ត្ន ការពារសេចក្ដីអន្តរាយ ឬការខ្វះខាតក្រែងនឹងមានទៅខាងមុខ : ដាក់ថ្នាំសង្កូវខ្លះបង្ការផង, ដាក់បាយបង្ការតាមផ្លូវ។

បង្ការ២

[បង់-កា]

ប. ពាក្យបរិវាររបស់ពាក្យ បន្លែ : បន្លែបង្ការ គឺបន្លែនិង បន្លែរាយរងដែលត្រូវឱ្យមានទុកបម្រុងការខ្វះខាតឬបន្លែច្រើនមុខ នេះខ្លះនោះខ្លះ។

| | |
|---|---|
| បញ្ញាវ័ន្ត ☒ | បញ្ញវន្ត ☑ |

បញ្ញវន្ត

[ប៉ុញ-ញ៉ៈ-វាន់] (បា. បញ្ញវន្តុ > វន្ត)

ន. អ្នកមានប្រាជ្ញា, អ្នកប្រាជ្ញ, អ្នកយកចិត្តទុកដាក់ប្រើ គំនិតត្រិះរិះក្នុងកិច្ចការគ្រប់ចំពូក។ (បើស្ត្រីជា បញ្ញាវតី ឬបញ្ញាវន្តី)។

បទពិសោធន៍ ☒ បទពិសោធ ☑

បទពិសោធ

[បត់-ពិ-សោត]

ន. ចំណេះដឹង, ហេតុ ដែលបានមកពីការឆ្លងកាត់ឬការចូលប្រឡូកក្នុងព្រឹត្តិការណ៍ដោយផ្ទាល់ : សៀវភៅនេះបង្ហាញអំពីបទពិសោធជំនួញរបស់ខ្ញុំ។

បន្ទិចបន្ទួច ☒ បន្តិចបន្តួច ☑

បន្តិចបន្តួច

[បន់-តិច-បន់-តួច]

ដែលតិចតួច, យ៉ាងតិចតួច : របស់បន្តិចបន្តួច។

| ☒ | ☑ |
|---|---|
| បន្ទោបង់ ☒ | បន្ទោរបង់ ☑ |

បន្ទោរបង់

[បន់-ទោ-បង់]

កិ. នាំបង់, បន្ថយចេញ : បន្ទោរបង់ឧច្ចារៈ, បន្ទោរបង់សេចក្ដីព្រួយ។

| ☒ | ☑ |
|---|---|
| បរទេះ ☒ | បរទេស ☑ |

បរទេស

[ប-រ៉ៈ-ទេស] ឬ [ប៉-រៈ-ទេស] (បា.)

ន. ប្រទេសដទៃឬអ្នកប្រទេសដទៃ : ជនបរទេស, គេទើបនឹងមកពីបរទេស។

| | |
|---|---|
| បរិញ្ញាប័ត្រ ☒ | បរិញ្ញាបត្រ ☑ |

បរិញ្ញាបត្រ

[ប៉ៈ-រ៉ិញ-ញ៉ា-ប័ត] (បា. បរិញ្ញា + សំ. បត្រ)

ន. ឈ្មោះសញ្ញាបត្រជាន់ខ្ពស់ ដែលតម្រូវឱ្យនិស្សិតសិក្សារយៈពេលជាទូទៅ៤ឆ្នាំ : ប្រឡងជាប់បរិញ្ញាបត្រ។

| | |
|---|---|
| បរិបូ ☒ | បរិបូណ៌ ☑ |

បរិបូណ៌១

[បរ៉ិ-បូ] ឬ [ប-បូ] (សំ.; បា. បរិបុណ្ណ)

គុ., កិ. ដូចគ្នានឹង បរិបូរ : ភោជនាហារបរិបូណ៌; អ្នកអញ្ជើញពិសាចុះ ខ្ញុំបរិបូណ៌ហើយ។

បរិបូណ៌២

[ប-រិ-បូ] ឬ [ប-បូ]

ន. ឈ្មោះខេត្តមួយក្នុងកម្ពុជរដ្ឋ, សព្វថ្ងៃនេះ ដាក់ទៅជាស្រុក ហៅថា ស្រុកបរិបូណ៌ រួមចូលក្នុងខេត្តកំពង់ឆ្នាំង។ (ម.ព. បរិបូរនិងបរិបូណ៌១ ផង)។

បរិវេន ☒ បរិវេណ ☑

បរិវេណ

[ប-រិ-វេន] (បា.)

ន. ទីជិតខាងដែលព័ទ្ធជុំវិញ, រោងថែវដែលព័ទ្ធជុំវិញប្រាសាទឬគ្រឹហាជាដើម : បរិវេណវត្ត, បរិវេណសាលារៀន។

បស្ចឹម ☒ បស្ចិម ☑

បស្ចិម

[ប័ស-ចិម] (សំ. បឝ្ចិម; បា. បច្ឆិម)

គុ., ន. ដែលជាទីបំផុត, ខាងក្រោយ; ទិសខាងក្រោយ គឺ ទិសខាងលិច : ទិសបស្ចិម។

ប៉ុស្តិ ☒ ប៉ុស្តិ៍ ☑

ប៉ុស្តិ៍

[ប៉ុស] (បារ. poste)

១). ន. ប្រៃសណីយ៍ គឺមុខក្រសួងរាជការមួយផ្នែកទទួលភារៈខាងការបញ្ជូនសំបុត្រស្នាមផ្សេងៗ ... : យកសំបុត្រទៅដាក់ប៉ុស្តិ៍, ផ្ញើសំបុត្រតាមប៉ុស្តិ៍។

២). ទីកន្លែងទាហានចាំយាម : ប៉ុស្ដិ៍ទាហាន, ទាហានចាំបុស្ដិ៍។

៣). កន្លែងធ្វើការរាជការផ្សេងៗ : ប៉ុស្ដិ៍ប៉ូលិស, ប៉ុស្ដិ៍រាជការតំបន់រដ្ឋបាល។ល។

| | |
|---|---|
| បាតុភូធ ☒ | បាតុភូត ☑ |

បាតុភូត

[ប៉ា-តុ-ភូត] (បា. បាតុ + ភូត)

១). ន. ហេតុដែលកើតមានឡើងយ៉ាងប្រាកដជាក់ស្ដែង។

២). ហេតុដែលបណ្ដាលឡើងឯងៗដោយធម្មជាតិ ហើយដែលគួរឱ្យចង់មើលចង់ត្រិះរិះពិចារណាមើល ដូចជាការកក្រើកផែនដីជាដើម; សត្វ, មនុស្សឬវត្ថុផ្សេងៗដែលមានអាការៈណាមួយចម្លែកអស្ចារ្យខុសពីធម្មតា : ផ្កាយដុះកន្ទុយជាបាតុភូតមួយក្នុងសកលលោក។

បាលាត់ ☒ បាឡាត់ ☑

បាឡាត់

[បា-ឡាត់]

១). ន. ឋានន្តរនៃមន្ត្រីសង្ឃ ថ្នាក់ឋានានុក្រមថ្នាក់ខ្ពស់ជាងសមុហ៍ ជាសហការីនៃព្រះរាជាគណៈគ្រប់ថ្នាក់ទាំង៤ គឺ ឯក, ទោ, ត្រី, ចត្វា មានឋានន្តរគឺងារជាភាសាបាលីផ្សេងៗគ្នា; សម្រាប់មេគណគ្រប់ខេត្ត ក៏មានឋានានុក្រមទី បាឡាត់ ដែរ។

២). សម្រាប់សម្តេចព្រះសង្ឃរាជនិងសម្តេចព្រះសង្ឃនាយក មានឋានានុក្រមទី បាឡាត់ ពីរៗរូប ស្តាំ១រូប ឆ្វេង១រូប; ក្នុងសម័យពីដើមហៅ បាឡាត់ទូលឆ្លង មាននាទីជាអ្នកទទួលភារកិច្ចផ្សេងៗ ជាជំនួសឬជាជំនួយសម្តេចព្រះសង្ឃរាជឬសម្តេចព្រះសង្ឃនាយក ក្នុងការទទួលភ្ញៀវនិងការពិតទូលអំពីកិច្ចការនានារបស់ភ្ញៀវសាធារណៈ ដែលមានការប្រាស្រ័យទាក់ទងជាការចាំបាច់។

៣). ខាងមន្ត្រីគ្រហស្ថសម្រាប់ខេត្តនិងស្រុកក៏មាន បាឡាត់ដែរ ហៅថា បាឡាត់ខេត្ត, បាឡាត់ស្រុក ...។ ខ្មែរបុរាណសរសេរ បាល័ដ្ឋ ប្រហែលជាសំដៅអត្ថន័យថា “អ្នកមាននាទីខាងការថែរក្សា” ទេដឹង? (សៀមសរសេរ ប៉ល័ត អ.ថ. ប្ល័ត, មានអត្ថន័យថាអ្នកផ្លាស់មុខការនាទីជាជំនួយឬជាជំនួសរងពីអធិបតីរបស់ខ្លួនមក ...)។

| | |
|---|---|
| បិណ្ឌបាត្រ ☒ | បិណ្ឌបាត ☑ |

បិណ្ឌបាត

[បិន-ឌ:-បាត] ឬ [បិន-បាត] (បា.)

ន. អាហារដែលប្រមូលឱ្យជាដុំដាក់ក្នុងបាត្រ គឺចង្ហាន់ដាក់បាត្រឬចង្ហាន់រាប់បាត្រ (សម្រាប់បព្វជិតក្នុងព្រះពុទ្ធសាសនា) : ចង្ហាន់បិណ្ឌបាត, អាហារបិណ្ឌបាត។

កិ. ប្រើតាមទម្លាប់ជា កិ. ក៏បាន : លោកនិមន្តបិណ្ឌបាត, បិណ្ឌបាតមិនសូវបាន។ (ចួនកាលប្រើកាត់ខ្លីតែត្រឹម បិណ្ឌ ក៏មានលោកនិមន្តទៅបិណ្ឌ)។

បិតទ្វា ☒ បិទទ្វារ ☑

បិទទ្វារ

[បិត-ទ្វា]

កិ. (ព.ប្រ.) ផ្អាកឬបញ្ឈប់សកម្មភាព ការធ្វើពាណិជ្ជកម្ម ស្ថាប័ន ក្រុមហ៊ុន ជាដើម : ក្រុមហ៊ុននេះបានបិទទ្វារតាំងពីបីខែមុន។

បិទស្រា ☒ បិតស្រា ☑

បិត២

[បិត]

កិ. ចំហុយយកញើសឱ្យស្រក់ចុះក្នុងតម្រងឱ្យកើតបានជាសុរា : បិតស្រា។

| | |
|---|---|
| បីតា ☒ | បិតា ☑ |

បិតា

[បិ-ដា] (បា. បិតុ > បិតា; សំ. បិត្ឫ > បិតារ)

ន. បុរសអ្នកបីបាច់រក្សាកូន (ឪពុក)។

| | |
|---|---|
| បឹងបួរ ☒ | បឹងបួ ☑ |

បឹងបួ

[បឹង-បួ]

ន. បឹងតូចៗឬបឹងរាយរង (ស. បឹង អ.ថ. បឹ៊ង "បឹង", បួ័ អ.ថ. បួ "ឈូក"; គួរយល់ថា បឹងបួ គឺបឹងឈូក។

| | |
|---|---|
| បុថុជ្ជន ☒ | បុថុច្ចជន ☑ |

បុថុជ្ជន

[ប៉ុ-ថុច-ជន់] (បា. បុថុ "ក្រាស់, ក្រាស់ក្រៃ; ច្រើន" + ជន "សត្វដែលកើត, សត្វលោក"; សំ. ប្ឫថគ្ជន)

ន. ជនមានកិលេសក្រាស់, ជនអ្នកមានសេចក្ដីសៅហ្មង, សត្វលោកក្រៅអំពីអរិយបុគ្គលទាំង៨ពួក : បុថុជ្ជនមានច្រើនប្រភេទ មានកល្យាណបុថុជ្ជន, បាបបុថុជ្ជន; បណ្ឌិតបុថុជ្ជន, ពាលបុថុជ្ជន ជាដើម។ (ម.ព. ប្រថុជ្ជន២ ផង)។

| | |
|---|---|
| បុពការី ☒ | បុព្វការី ☑ |

បុព្វការី

[បុប-ពៈ-កា-រ៊ី] (បា.; សំ. បូវ៌ការិន៑)

ន. អ្នកដែលបានធ្វើឧបការៈមុន គឺអ្នកដែលបានធ្វើសេចក្ដីទំនុកបម្រុងផ្គុងផ្គើមរួចមកហើយ : មាតាបិតា ជាបុព្វការីរបស់កូន; គ្រូជាបុព្វការីរបស់សិស្ស; ព្រះសម្មាសម្ពុទ្ធ ជាបុព្វការីរបស់ពុទ្ធសាសនិកជន; ព្រះមហាក្សត្រជាបុព្វការីរបស់ប្រជាជន ព្រោះទ្រង់បានចាត់កិច្ចការគ្រប់គ្រងរក្សាប្រទេសរបស់ព្រះអង្គ ឱ្យអស់ប្រជាជនបានសេចក្ដីសុខស្រួល។ល។ (បើស្ត្រីជា បុព្វការិនី)។

| | |
|---|---|
| បូរមី ☒ | បូណ៌មី ☑ |

បូណ៌មី

[បូ-រ្នៈ-ណៈ-ម៊ី] ឬ [បូ-រ៉ៈ-ម៊ី] (សំ.; បា. បុណ្ណមី)

ន. តិថីឬថ្ងៃដែលមានព្រះចន្ទពេញវង់, ថ្ងៃ ១៥កើត : ថ្ងៃពេញបូណ៌មីខែកត្តិក ជាថ្ងៃធ្វើពិធីសំពះព្រះខែ តាមប្រពៃណីពីបុរាណកាលរៀងមក។

បើសិនជា ☒ ប្រសិនបើ ☑

ប្រសិនបើ

[ប្រ-សិន-បើ]

ឈ. ពាក្យប្រាប់សេចក្តីស្មាន មានសេចក្តីថា បើ, កាលបើ : ប្រសិនបើគេមិនព្រមទេសឹមយើងនឹងលៃលកទៅទៀត។ (កុំប្រើ បើសិនជាឬប្រសិនជា ដែលជាវិកតិកត្តាឡើយ)។

បៀវត្ត ☒ បៀវត្ស ☑

បៀវត្ស

[បៀ-វ័ត] (សំ. វត្ស ឬ វត្សរ "ឆ្នាំ")

ន. បៀរង្វាន់ឆ្នាំ (ប្រាក់រង្វាន់ឆ្នាំ) គឺប្រាក់ដែលព្រះរាជាទ្រង់ប្រោសព្រះរាជទានក្នុង១ឆ្នាំម្តង។ (ម.ព. បៀ ផង)។

បេតិកភ័ណ្ឌ ☒ បេតិកភណ្ឌ ☑

បេតិកភណ្ឌ

[ប៉េ-តិ-កៈ-ភ័ន] (បា. បេតិក + ភណ្ឌ)

ន. ទ្រព្យសម្បត្តិឬកេរមត៌កដែលមានជាប់តមកពីខាងឪពុក : ស្រែទាំងអស់នេះជាបេតិកភណ្ឌរបស់ខ្ញុំ។ (ម.ព. មត្តិកាភណ្ឌ ក្នុង មត្តិកា)។

បេះបិត ☒ បេះបិទ ☑

បេះបិទ

[បេះ-បិត]

គុ. (ព.ប្រ.) ដូចណាស់, ដូចគេបេះពីម្ខាងយកមកបិទភ្ជាប់ម្ខាង : ក្មេងទាំងពីរនាក់នេះដូចគ្នាបេះបិទ។

| | |
|---|---|
| បែកគុំ ☒ | បែកគុម្ព ☑ |

បែកគុម្ព

[បែក-គុំ]

កិ. ដុះចេញកូនថ្មីៗបង្កើតបានជាគុម្ព : ស្រូវទើបបែកគុម្ព, ទំពាំងទូលដី ឬស្សីបែកគុម្ព។

| | |
|---|---|
| ប្រគុំតន្ត្រី ☒ | ប្រគំតន្ត្រី ☑ |

ប្រគំ

[ប្រ-គុំ]

កិ. លេងភ្លេងរងំនាំឱ្យស្រណោះ, លេងភ្លេងកំដរឱ្យក្សាន្តចិត្ត ... : ប្រគំតន្ត្រីមួយវង់។

ប្រគួត ☒ ប្រកួត ☑

ប្រកួត

[ប្រ-កួត]

កិ. ប្រឡូងគ្នា ដោយគំនុំ, ដោយកំហឹងឬដោយចង់បានជម្នះ : ប្រកួតកីឡាបាល់ទាត់។

ប្រងើយ ☒ ព្រងើយ ☑

ព្រងើយ

[ព្រ-ងើយ]

គុ.កិ., គុ. ដែលជើយ, កន្តើយ : ឈរព្រងើយ, ធ្វើព្រងើយ; ចិត្តព្រងើយ។

ប្រញ៉ាប់ប្រញ៉ាល់ ☒ ប្រញាប់ប្រញាល់ ☑

ប្រញាប់ប្រញាល់

[ប្រ-ញ៉ាប់-ប្រ-ញ៉ាល់]

កិ., គុ.កិ., គុ. ប្រញាប់ដោយរហ័ស, ប្រញាប់ណាស់។

ប្រដឹសស្ដាន ☒ ប្រតិស្ឋស្ដាន ☑

ប្រតិស្ឋ

[ប្រ-ដឹស] (សំ. ប្រតិឞ្ឋ; បា. បតិដ្ឋ)

កិ. ខ្មែរយើងច្រើនតែប្រើពាក្យ ប្រតិស្ឋ នេះផ្សំភ្ជាប់ពីខាងដើមពាក្យ អធិស្ឋាន ថា ប្រតិស្ឋអធិស្ឋាន គឺបញ្ចេញវាចាឮៗឬខ្សឹបៗ តាំងសេចក្ដីប្រាថ្នាក៏មាន, ឧទ្ទិសភាគផលកុសលជូនឆ្ពោះទៅ

បុព្វបុរសដែលចែកឋានទៅហើយក៏មាន, បន់ស្រន់សូមឱ្យបាន សម្រេចផលតាមបំណងក៏មាន, លាបំណន់ក៏មាន, តាំង សច្ចាធិដ្ឋានសំបូងសង្រួងក៏មាន : ហ៏ យើងនាំគ្នាប្រតិស្ឋអធិស្ឋាន ទៅ!; ខ្ញុំបានអុជទៀនធូប ប្រតិស្ឋអធិស្ឋានរួចសព្វគ្រប់ហើ យ។ (និយាយថា ប្រតិស្ឋអធិដ្ឋាន ក៏បាន។ ម.ព. ប្រតិដ្ឋ)។

ប្រឌិត ☒ ប្រតិដ្ឋ ☑

ប្រតិដ្ឋ

[ប្រ-ដិត] (បា. បតិដ្ឋ; សំ. ប្រតិឞ្ឋ "ឋិតនៅនឹង, តាំងនៅស៊ប់, តាំងនៅជាប់លាប់; ឈរស៊ប់, ...")

១). កិ. បង្កើតឱ្យមានឡើងតាមយោបល់របស់ខ្លួន ដោយ ប្រដូចទៅនឹងនេះនឹងនោះខុសសោះក៏មាន ត្រូវដែរក៏មាន : កុំ អាលជឿពេក ព្រោះអ្នកនិយាយចេះតែប្រតិដ្ឋថាៗទៅទេ។

គុ. ដែលបង្កើតឱ្យមានឡើងតាមគំនិត យោបល់របស់ខ្លួន : រឿងប្រតិដ្ឋ, ពាក្យប្រតិដ្ឋ។

២). ន. រឿងឬពាក្យដែលគេប្រតិដ្ឋឱ្យមានឡើង : សាស្ត្រាល្បែង ថ្លែងរឿងក្រៅពីជាតកមែនទែន, ដូចជារឿងលក្ខណវង្ស, រឿងសង្ខសិល្ប៍ជ័យ, រឿងសព្វសិទ្ធ, រឿងជិនវង្ស ...សុទ្ធតែជារឿងប្រតិដ្ឋ ដូចគ្នានឹងរឿងប្រលោមលោកដទៃទៀត ដែលជារឿងប្រតិដ្ឋនោះដែរ។ ពាក្យថា រូបយាយចាស់រវៃអំបោះនៅក្នុងវង់ព្រះចន្ទ្រ ជាសម្តីប្រតិដ្ឋប្រាប់ក្មេងតូចៗដែលវាសួរ, ឯតាមការណ៍ពិត គឺជារូបទន្សាយ (ពោធិសត្វ) ដែលមានចែងក្នុងគម្ពីរជាតក (ខាងពុទ្ធនិយម) ។ល។ តាមទម្លាប់និយាយថា ប្រឌិត ឬធ្លាប់សរសេរ ប្រឌិដ្ឋ។ ក៏មាន, គួរសរសេរ ប្រតិដ្ឋ ប្រដិត, វិញត្រឹមត្រង់តាម សំ.និងបា. លាយចម្រុះគ្នា, ត្រូវការអាន ឬថា ប្រឌិត។ តាមទម្លាប់ក៏សឹងតែបាន, ដូចជាសរសេរ អតិតឬអតីត ធ្លាប់អានថា អឌិតនោះដែរ ដ្បិតការអានខុសពីសរសេរនេះរាប់ថាជា អញ្ញត្រសព្ទ។ ក្នុងអក្សរសាស្ត្រ ដូចជា អញ, អ្នក, នេះ, នោះ អានថា អាញ់, នាក់, និះ, នុះ ...ដូច្នោះដែរ។ ល។

ប្រតិស្ថាន ☒ ប្រតិស្ថាន ☑

ប្រតិស្ឋាន

[ប្រ-ដឺស-ស្ឋាន] (សំ. ប្រតិម្ឋាន; បា. បតិដ្ឋាន)

ន. ការស្ថិត, ការតាំង, ការតាំងនៅ, ការសាង។

កិ. ស្ថិតនៅ; តាំងនៅ, តម្កល់; កសាង។

ន., កិ., គុ. ដែលស្ថិតនៅ; ដែលតាំងនៅ, ដែលតម្កល់។

ប្រទីត ☒ ប្រទីប ☑

ប្រទីប

[ប្រ-ទីប] (សំ.; បា. បទីប)

១). ន. គោម, ចង្កៀង។ ខ្មែរយើងហៅតែចង្កៀងតូចៗ ដែលឥតកែវលំផ្លូង : អុជប្រទីប, ពន្លឺប្រទីបប្លុងៗ។

២). ប្រដាប់ធ្វើជាគ្រោង ឬជារូបផ្សេងៗ ដាក់លើទូកលាតឬលើក្បូន អុជបំភ្លឺព្រោងព្រាតបណ្ដែតលើទឹក : បណ្ដែតប្រទីប។

ប្រពៃនី ☒ ប្រពៃណី ☑

ប្រពៃណី

[ប្រ-ពៃ-នី]

ន. (ម.ព. បវេណី)។

ប្រព្រិត្ត ☒ ប្រព្រឹត្ត ☑

ប្រព្រឹត្ត

[ប្រ-ព្រឹត] (សំ. ប្រវ្ឫត្ត; បា. បវត្ត)

កិ. ធ្វើ, ធ្វើតាម, ប្រតិបត្តិតាម, កាន់វត្តប្រតិបត្តិ : កុំប្រព្រឹត្តទុច្ចរិត។

គុ. ដែលធ្វើ, ដែលធ្វើតាម, ដែលកាន់វត្តប្រតិបត្តិ : ឈ្មោះនេះជាមនុស្សប្រព្រឹត្តសុចរិតត្រឹមត្រូវ។

ប្រយោច ☒ ប្រយោជន៍ ☑

ប្រយោជន៍

[ប្រ-យ៉ោច] (សំ.ប្រយោជន; បា. បយោជន)

ន. ដំណើរដែលគួរប្រកប, អ្វីៗដែលគេត្រូវការ, ដែលគេប្រកបទៅកើតការ, ផលដែលសម្រេចអំពីការប្រកប : ប្រយោជន៍ក្នុងលោកនេះ, ប្រយោជន៍ក្នុងបរលោក; បុគ្គលគួរកុំធ្វើអំពើឥតប្រយោជន៍ គួរធ្វើតែអំពើណាដែលមានប្រយោជន៍។

ប្រលាក់ ☒ ប្រឡាក់ ☑

ប្រឡាក់

[ប្រ-ឡាក់]

កិ. ធ្វើឱ្យជិត, ឱ្យជាម, ឱ្យជ្រាបចូលក្នុងសាច់, ព្រលាំងអំបិល ឱ្យជ្រាបចូលក្នុងសាច់ : ប្រឡាក់ត្រី, ប្រឡាក់សាច់។

គុ. ដែលជិត, ជាម; ដែលគេធ្វើឱ្យជ្រាបអំបិលចូលក្នុងសាច់ហើយ : ក្រដាសប្រឡាក់ទឹកខ្មៅ, ជើងប្រឡាក់ភក់ស្រមក, មុខប្រឡាក់ធ្យូង; ត្រីប្រឡាក់, សាច់ប្រឡាក់។

| | |
|---|---|
| ប្រសាទអង្គរវត្ត ☒ | ប្រាសាទអង្គរវត្ត ☑ |

ប្រាសាទ

[ប្រា-សាត] (សំ.; បា. បាសាទ)

១). ន. គ្រឹហាជាទីនាំចិត្តឱ្យជ្រះថ្លាឬជាទីស្រឡះភ្នែក គឺផ្ទះមានថ្នាក់ខ្ពស់ស្រឡះ។

២). ខ្មែរយើងប្រើតាមទម្លាប់ ហៅចំពោះតែព្រះរាជដំណាក់ ឬគ្រឹហាដែលមានកំពូល សូម្បីសង់តែមួយជាន់ក៏ហៅ ប្រាសាទ

ដែរ; តែបើវិហារឬសាលា ទោះបីមានកំពូលក៏ពុំហៅ ប្រាសាទ ឡើយ។

| | |
|---|---|
| ប្រសាសនិ៍ ☒ | ប្រសាសន៍ ☑ |

ប្រសាសន៍

[ប្រ-សាស] (សំ. ប្រ + ឝាសន)

ន. ពាក្យបង្គាប់, ពាក្យផ្ដាំផ្ញើ, បណ្ដាំ។ ខ្មែរយើងប្រើចំពោះតែ ពាក្យ, សម្ដី របស់ឥស្សរជនក្រៅពីក្សត្រិយ៍ : ទទួលប្រសាសន៍លោក គឺទទួលពាក្យលោក; លោកមានប្រសាសន៍ គឺលោកនិយាយ (សម្រាប់ឥស្សរជនជាគ្រហស្ថ)។

| | |
|---|---|
| ប្រសូត្រ ☒ | ប្រសូត ☑ |

ប្រសូត

[ប្រ-សូត] (សំ.; បា. បសូត)

កិ. សម្រាលកូន។ (ខ្មែរប្រើជា រ.ស. សម្រាប់ហៅស្ត្រីជាតិក្សត្រិយ៍សម្រាលកូន)។

ប្រាក់កាក់ ☒ ប្រាក់កាស ☑

ប្រាក់កាស

[ប្រាក់-កាស]

ន. លុយកាក់, សាច់ប្រាក់ សម្រាប់ ចាយវាយ : ពេលនេះយើងមានប្រាក់កាសគ្រប់គ្រាន់ហើយ។

ប្រឹមប្រិយ ☒ ប្រិមប្រិយ ☑

ប្រិមប្រិយ

[ប្រិម-ប្រី] (សំ. ប្រេមន៑ ន."មនុស្ស ឬ អ្វីៗដែលជាទីស្រឡាញ់" + ប្រិយ គុ."ដែលគួរឱ្យស្រឡាញ់, ដែលជាទីស្រឡាញ់"; បា.បេម + បិយ សេចក្ដីដូច សំ.ដែរ)

គុ. ដែលស្រស់ប៉ប្រៃគួរឱ្យស្រឡាញ់, ដែលគួរឱ្យស្រឡាញ់ក្រៃពេក (ច្រើនប្រើប្រិមប្រិយ ជាង) : មុខមាត់ប្រិមប្រិយ។ (ច្រើនប្រើចំពោះតែមុខមាត់; ប៉ុន្តែខាងកាព្យ អាចប្រើលាយចម្រុះគ្នាបានទាំងពីរ ដូចជា មើលមាត់ក៏ប្រិមប្រិយ ហាមាត់ស្ដីឥតទាស់ឆ្គង មើលមុខស្រស់បំព្រង ទាំងដងខ្លួនក៏ប្រេមប្រិយ)។

ប្រែត ☒ ប្រេត ☑

ប្រេត

[ប្រែត] (សំ.; បា. បេត)

១). ន. សត្វកើតក្នុងអបាយភូមិពួកមួយ : ពួកប្រេត។
២). អ្នកដែលធ្វើមរណកាលទៅកាន់បរលោកហើយ។

| | |
|---|---|
| ប្រៃសនីយ៍ ☒ | ប្រៃសណីយ៍ ☑ |

ប្រៃសណីយ៍

[ប្រៃ-សៈ-នី] (សំ.; បា. បេសនីយ)

ន. ក្រុមរាជការទទួលបន្ទុកខាងការបញ្ជូននិងការដឹកនាំសំបុត្រស្នាមផ្សេងៗជាដើម : ផ្ញើសំបុត្រតាមប្រៃសណីយ៍, ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

| | |
|---|---|
| បំពេរ ☒ | បំ ☑ |

បំពេ

[បំពេ]

១). កិ. ពោលពាក្យថ្នាក់ថ្នមល្បួងលោមមានបទ មានទំនុក ដើម្បីឱ្យដេកលក់ : បំពេកូន។

២). ន. ឈ្មោះទំនុក, បទ ឬឈ្មោះភ្លេងមួយមេ : ទំនុកបំពេ, ភ្លេងបំពេ។

| | |
|---|---|
| បំភ្លើស ☒ | បំផ្លើស ☑ |

បំផ្លើស

[បំ-ផ្លើស]

កិ. ធ្វើឱ្យលើស គឺធ្វើឱ្យកើនឱ្យជ្រុលហួស : បំផ្លើសពាក្យ, បំផ្លើសសេចក្តី។

គុ.កិ., គុ. ដែលលើស, ដែលជ្រុលហួស : និយាយបំផ្លើស; សម្តីបំផ្លើស។

បំរាម ☒ បម្រាម ☑

បម្រាម

[បំ-រ៉ាម]

ន. សំបុត្រហាមប្រាម, សេចក្ដីហាមប្រាម : មានបម្រាមបិទនៅជិតមាត់ទ្វារប្រាប់ថាកុំឱ្យអ្នកក្រៅចូល ...។

# ពាក្យផ្ដើមដោយព្យញ្ជនៈ

# ផ

ផល្លានិសង្ឃ ☒ ផល្លានិសង្ស ☑

ផលានិសង្ស

[ផៈ-ឡា-និ-សង់] (បា. > ផល + អានិសំស)

ន. អានិសង្សនៃផល, ការហូរមកនៃផល គឺសេចក្ដីសុខ សេចក្ដីចម្រើនដែលកើតអំពីផលនៃអំពើល្អ។

ផែនការណ៍ ☒ ផែនការ ☑

ផែនការ

[ផែន-កា]

ន. គម្រោងការ, គោលការណ៍ដែលត្រូវធ្វើ : ធ្វើតាមផែនការ, ផែនការ៥ឆ្នាំ។

ផ្កាច័ន្ទ ☒ ផ្កាចន្ទន៍ ☑

ផ្កាចន្ទន៍១

[ផ្កា-ច័ន]

ន.រូបភាពឬក្បាច់ចម្លាក់មានសណ្ឋានដូចផ្កាចន្ទន៍។

ផ្កាចន្ទន៍២

[ផ្កា-ច័ន]

ន. ឈ្មោះបន្លែក្រៀមមួយប្រភេទមកពីប្រទេសចិន; ប្រើធ្វើជាថ្នាំក្តៅក៏បាន។

ផ្កាឈូករដ្ឋ ☒ ផ្កាឈូករត្ន ☑

ឈ្យូករ័ត្ន

[ឈ្យូក-រ័ត]

ន. រុក្ខជាតិមួយប្រភេទ សម្បូរជាតិប្រេងមានផ្កាធំរាងមូលគ្របកខាងក្រៅពណ៌លឿង។ គ្រាប់វាត្រូវបានគេចម្រាញ់យកប្រេងប្រើជា អាហារ ឱសថ និងគ្រឿងសម្អាង : ចម្ការផ្កា ឈ្យូករ័ត្ន, ប្រេងឈ្យូករ័ត្ន។

| | |
|---|---|
| ផ្ទួរផ្គង ☒ | ផ្ទូផ្គង ☑ |

ផ្ទូផ្គង

[ផ្ទូ-ផ្គង]

កិ. ផ្គងឱ្យបានជាគូ; ប្រុងប្រៀប; ផ្គត់ផ្គង់, ផ្ដុងផ្ដើម; លើកតម្កើង។

ផ្ទង់ផ្ដើម ផ្ទុងផ្ដើម

ផ្ទុងផ្ដើម

[ផ្ទុង-ផ្ដើម]

កិ. ទំនុកបម្រុងឱ្យឃើញចុងឃើញដើម គឺប្រដុងប្រដាដោយសព្វគ្រប់ឱ្យដុះដាលចម្រើន : មាតាបិតាផ្ទុងផ្ដើមកូនឱ្យរៀនសូត្រឬឱ្យធ្វើការរកស៊ី។

ផ្ញើរ ផ្ញើ

ផ្ញើ

[ផ្ញើ]

១). កិ. បញ្ជូនបញ្ញើពីទីមួយទៅកាន់ទីមួយទៀត : ផ្ញើសំបុត្រទៅបងប្អូននៅកំពង់ចាម, ផ្ញើអីវ៉ាន់តាមកប៉ាល់។

២). ដាក់ទុកឱ្យគេទទួលបញ្ញើដោយមានពាក្យផ្ដាំឬសន្យាយ៉ាងណាៗ : ខ្ញុំសុំផ្ញើហិបនេះនៅផ្ទះអ្នកសិន ដល់ថ្ងៃស្អែកខ្ញុំនឹងមកយក។

ផ្ញៀវ ☒ ភ្ញៀវ ☑

ភ្ញៀវ

[ភ្ញៀវ]

ន. អ្នកទីទៃក្រៅពីគ្នាឯងក្នុងផ្ទះឬក្នុងបន្ទុកជាមួយដែលគេមករក, មកសួរនាំ, មកលេងឬអ្នកដែលម្ចាស់ផ្ទះឬម្ចាស់បន្ទុកជាមួយ, ម្ចាស់ការ, ម្ចាស់ពិធីអញ្ជើញ, ហៅរកឱ្យគេមក : ហៅភ្ញៀវ, អញ្ជើញភ្ញៀវ, ជប់លៀងភ្ញៀវ។

ផ្តន្ទារ ☒ ផ្តន្ទា ☑

ផ្តន្ទា

[ផ្តន់-ទា]

កិ. ផ្ចាល, ធ្វើទោសផ្ចាល; បន់ឱ្យគេវិនាស : ត្រូវផ្តន្ទាវាតាមច្បាប់។

ផ្ដាច់ញ៉ា ☒ ប្ដេជ្ញា ☑

ប្ដេជ្ញា

[ប្ដ័ច-ញ៉ា] (ក្លាយមកពី សំ. ប្រតិជ្ញា)

ន. (ម.ព. បដិញ្ញា)។

កិ. មត់គ្នា, សន្យាគ្នា : បានប្ដេជ្ញាគ្នាថានឹងឈប់ប្រព្រឹត្តអំពើពាលនោះតទៅទៀត, បានប្ដេជ្ញាចិត្តជាស្រេចថា ...។

ផ្ដាស់សាយ ☒ ផ្ដាសាយ ☑

ផ្ដាសាយ

[ផ្ដា-សាយ]

ន. ឈ្មោះរោគមួយប្រភេទមានអាការៈបណ្ដាលឱ្យកណ្ដាស់ ឱ្យហូរហៀរទឹកសំបោរ។

កិ. មានអាការៈបណ្ដាលឱ្យកណ្ដាស់ ឱ្យហូរហៀរទឹកសំបោរដោយរោគ : ខ្ញុំផ្ដាសាយពីរបីថ្ងៃហើយ។

ផ្ដេសផ្ដាស់ ☒ ផ្ដេសផ្ដាស ☑

ផ្ដេសផ្ដាស

[ផ្ដេស-ផ្ដាស]

គុ., គុ.កិ. ដែលខ្ជីខ្ជា, ឥតសណ្ដាប់ធ្នាប់, ខុសផ្លូវខុសគន្លង, ខុសរបៀប, ខុសច្បាប់, តាមតែប្រទះ : សម្ដីផ្ដេសផ្ដាស, ការផ្ដេសផ្ដាស; និយាយផ្ដេសផ្ដាស, ធ្វើផ្ដេសផ្ដាស។

ផ្លាកលេខ ☒ ស្លាកលេខ ☑

ផ្លាក

[ផ្លាក]

ន. សន្លឹកធ្វើអំពីលោហៈ ឈើ ឬរបស់ផ្សេងៗទៀត ដែលមានលក្ខណៈរឹង សំប៉ែត ស្ដើង តូចជាងផ្ទាំង និងមានរាងផ្សេងៗ ប៉ុន្តែជាទូទៅ ច្រើនមានរាងចតុកោណ សម្រាប់ប្រើសម្គាល់លេខរថយន្ត ទោចក្រយានយន្ត ត្រីចក្រយានយន្ត គេហដ្ឋាន តួនាទី កន្លែងធ្វើការ។ល។

ផ្លូវចំណោទ ☒ ផ្លូវចំណោត ☑

ចំណោត

[ចំ-ណោត]

ន. ទី, កន្លែងដែលចោត : ចំណោតច្រាំង, ចំណោតភ្នំ។

ផ្លែត្រលឹងឃឹង ☒ ផ្លែទ្រលឹងទឹង ☑

ទ្រលឹងទឹង

[ទ្រ-លឹង-ទឹង]

ន. ឈ្មោះឈើមួយប្រភេទ ពួកកន្ទួតស្រុក ផ្លែប្រើជាម្ជូរឬជ្រក់ក៏បាន។

| | |
|---|---|
| ផ្សិតកញ្ជូ ☒ | ផ្សិតកញ្ជូរ ☑ |

កញ្ជូ

[កញ់-ចូ]

ន. ឈ្មោះផ្សិតមួយប្រភេទ ប្រើជាអាហារ មានឱជារសឆ្ងាញ់ ពិសា : ផ្សិតកញ្ជូ។ (ជួនគេហៅ ផ្សិតកញ្ជោ)។

| | |
|---|---|
| ពង្សាវតា ☒ | ពង្សាវតារ ☑ |

ពង្សាវតារ

[ពង់-សា-វ៉ៈ-ដា] (បា. វំស; សំ. វំគ + អវតារ "ដំណើរឆ្លងចុះ, ការឃ្លាតនៃវង្សត្រកូល")

ន. រឿងរ៉ាវតាមលំដាប់នៃវង្សត្រកូល, ប្រវត្តិដែលឆ្លងពីសង្កាត់មួយមកសង្កាត់មួយ, ដំណើរសេចក្តីសម្តែងអំពីតំណនៃវង្សត្រកូល : ពង្សាវតារកម្ពុជរដ្ឋ; ពង្សាវតារលោក។ (ព.សា. លុប ពង់ ចេញនៅត្រឹមតែ សាវតារ និយាយក្លាយមកទៀតជា សៅវតារ)។

# ពាក្យផ្ដើមដោយព្យញ្ជនៈ

# ៣

ពត៌មាន ☒ ព័ត៌មាន ☑

ព័ត៌មាន

[ព័រ-ដ-មាន] (សំ. ក្ល.; សំ. វត៌មាន; បា. វត្តមាន "កាល ឬ សម័យដែលកំពុងប្រព្រឹត្តទៅ")

ន. (តាមសំឡេងអក្សរថា ព័រ-តៈ-ម៉ាន) ប្រព្រឹត្តិការណ៍, ដំណឹងផ្សេងៗក្នុងបច្ចុប្បន្ន, បច្ចុប្បន្នកាល : គេបានឱ្យព័ត៌មានមកថា ...; ស្ដាប់ព័ត៌មានប្រចាំថ្ងៃនៃវិទ្យុជាតិ។

ពន្យា ☒ ពន្យារ ☑

ពន្យារ

[ពន់-យា]

កិ. ធ្វើឱ្យយារ, ទាញទម្លាក់ឱ្យយារចុះ : ពន្យារខ្សែ, ពន្យារពេល។

ពព្រិចភ្នែក ☒ ប៉ប្រិចភ្នែក ☑

ប៉ប្រិច២

[ប៉-ប្រិច]

កិ. កម្រើកត្របកភ្នែកបើកបិទៗយ៉ាងរហ័ស : ប៉ប្រិចភ្នែក។

ពាក្យពេជ្រ ☒ ពាក្យពេចន៍ ☑

ពេចន៍

[ពេច] (សំ.បា. វចន)

១). ន. ពាក្យ, សម្តី។

២). ប. ពាក្យសម្រាប់និយាយផ្សំនឹងពាក្យ ពាក្យ ថា ពាក្យពេចន៍ គឺពាក្យសម្ដីផ្សេងៗ, ពាក្យសម្ដីដែលមានបែបមានយ៉ាងឬសម្ដីថ្វីមាត់ : អ្នកចេះពាក្យពេចន៍។ (ឱ្យជិតប្រភពដើមជាងជា ព័ចន៍ សម្រាប់ប្រើក្នុងកាព្យ។ ម.ព. ព័ចន៍ ផង)។

ពាក់ពាន់ ☒ ពាក់ព័ន្ធ ☑

ពាក់ព័ន្ធ

[ពាក់-ព័ន]

កិ. ព័ន្ធពាក់លើគ្នា។

ពិកា ☒ ពិការ ☑

ពិការ

[ពិ-កា] (សំ.បា. វិការ ប្រើជា ន."ការធ្វើប្លែក; ការប្រែចាកភាពប្រក្រតី ...")

គុ. ដែលខូចអវយវៈណាមួយប្រើការមិនកើត ដូចបាក់ដៃ, បាក់ជើង ជាដើម : មនុស្សពិការ។ (ម.ព. វិការ ផង)។

ពិរោះ ☒ ពីរោះ ☑

ពីរោះ

[ពី-រោះ]

គុ. ដែលស្រួលស្ដាប់, ល្អស្ដាប់, ឆ្ងាញ់ត្រចៀក, ដែលមានទំនងសូរសព្ទគួរឱ្យចង់ស្ដាប់ : សំឡេងពីរោះ, សម្ដីពីរោះ, ពាក្យពីរោះ។

គុ.កិ. ដែលស្រួលស្ដាប់, ដែលស្ដាប់ឆ្ងាញ់ត្រចៀក, ដែលមានទំនងសូរសព្ទគួរឱ្យចង់ស្ដាប់ : និយាយពីរោះ, ច្រៀងពីរោះ។

ពិសារ ☒ ពិសា ☑

ពិសា

[ពិ-សា]

កិ. បរិភោគ (ស៊ី); ពាក្យគួរសមសម្រាប់គ្រហស្ថឬបព្វជិតនិយាយទៅរកគ្រហស្ថដែលគួរគោរព : អ្នកពិសាហើយឬនៅ?; អញ្ជើញលោកពិសា!, អញ្ជើញពិសាឱ្យបរិបូណ៌!; (ដោយសំដៅសេចក្ដីថា បរិភោគឆ្ងាញ់)។ (ព.កា.) ពិសាផ្លែប្រាំ ពិសារសធម្ម ពិសាសត្យា ពិសាសីលទាន ទ្រើសទ្រង់ករុណា ពិសារសវា- ចាចេញមធូរ។ (សាស្ត្រាច្បាប់ រាជនេតិ ជាព្រះនិពន្ធនៃព្រះរាជសម្ភារ)។ (ម.ព. ស៊ី ផង)។

គុ. ដែលមានឱជារស, ឆ្ងាញ់, ចាប់មាត់ : ចំណីពិសា, ឆ្ងាញ់ពិសា។

ពុទ្ធបរិស័ទ្ធ ☒ ពុទ្ធបរិស័ទ ☑

ពុទ្ធបរិស័ទ

[ពុត-ធៈ-ប-រិ-ស័ត]

ន. បរិស័ទនៃព្រះពុទ្ធ។ (ម.ព. ពុទ្ធនិងបរិស័ទ ផង)។

| | |
|---|---|
| ពុម្ភ ☒ | ពុម្ព ☑ |

ពុម្ព១

[ពុំ]

ន. (ម.ព. ពិម្ព)។

ពុម្ព២

[ពុំ]

ន. ឈ្មោះនំមួយប្រភេទធ្វើអំពី ម្សៅខ្សាយ លាយមេ ស្ករ ដូង ល្ងជាដើម ដាក់ដុតក្នុងពុម្ពដែក។

| | |
|---|---|
| ពុំនោល ☒ | ពំនោល ☑ |

ពំនោល១

[ពុំ-នោល]

ន. ដំណើរដែលពោល, ពាក្យពោល; បទពោលល្ខោន។

ពំនោល២

[ពុំ-នោល]

ន. ឈ្មោះកាព្យមួយយ៉ាង មានជើងបី គឺក្នុងមួយរបះមាន ឃ្លាបី, មានចួនបី, ឃ្លាទី១, និងទី៣មាន៦ពាក្យ, ឃ្លាទី២មាន៤ ពាក្យ : បទពំនោល, ដូចជា : យក្សក្រោធច្រឡោតខ្លាំងក្រៃ ស្ទុះហោះចៀវព្រៃ ពួតដៃកំញ្ញើញ្ញគួរស្ញែង។ ស្រែកហ៊ោសន្ធាប់ឥតក្រែង ថារ៉ឺយប្រស្តែង ម្ដេចឯងពុំកោតចេស្ដា។

| | |
|---|---|
| ពៀ ☒ | ពៀរ ☑ |

ពៀរ

[ពៀ] (សំ. វៃរ; បា. វេរ)

ន. ចំណងចិត្តក្រោធដែលចងដោយព្យាបាទបម្រុងនឹងសងសឹកវិញ, ចំណងចិត្តជាសត្រូវ : ចងពៀរ, ស្រាយពៀរ, មនុស្សមានពៀរ។ រួចចាកពៀរ ព្រោះស្រាយពៀរ កាលបើបានជាចងពៀររួចទៅហើយ ដែលបានរួចរដោះចាកពៀរលែងមានតទៅទៀត ព្រោះស្រាយចំណងពៀរនោះឱ្យជ្រះស្រឡះចេញ បើមិនស្រាយចេញទេ ពៀរក៏ចេះតែមានតៗទៅទៀត (ព.ពុ.); (ព.កា.) ទីឃាវុកុមារ មានវិចារណ៍ចៀសពៀរបាន ទើបមានសុខក្សេមក្សាន្ត បានសោយរាជ្យគ្រងរដ្ឋពីរ។ (រឿងទីឃាវុកុមារនិងព្រះបាទព្រហ្មទត្ត ក្នុងទីឃាវុកុមារជាតក ជាពុទ្ធភាសិត)។

ពេញប្រៀប ☒ ពេញព្រៀប ☑

ព្រៀប

[ព្រៀប]

គុ., គុ.កិ. ដែលពេញកំពុងរកកល់ហៀរ : ពេញព្រៀប; ទឹកជន់ព្រៀបច្រាំង។

ពេលព្រឹក្ស ☒ ពេលព្រឹក ☑

ព្រឹក

[ព្រឹក]

ន. វេលាចាប់តាំងពីព្រះអាទិត្យបំព្រាងដល់ថ្ងៃពេញពន្លឺធំឬ ដរាបដល់ថ្ងៃត្រង់ក៏នៅហៅ ព្រឹក បានដែរ : ព្រឹកល្ងាច, ទាំងព្រឹកទាំងល្ងាច។

ពោធិសាត់ ☒ ពោធិ៍សាត់ ☑

ពោធិ៍សាត់១

[ពោ-សាត់]

ន. ឈ្មោះខេត្តមួយក្នុងកម្ពុជរដ្ឋ, នៅជាខាងកើតខេត្តបាត់ដំបង។ តាមពាក្យបរម្បរាពីព្រេងនាយតំណាលថា មានដើមពោធិ៍តូចមួយ រសាត់ច្រាសទឹកមកជាអស្ចារ្យប្លែក, គេបានស្រង់យកទៅដាំនៅទីមួយ, ដោយហេតុនេះ ទើបឱ្យឈ្មោះភូមិប្រទេសនុះថា ពោធិ៍រសាត់ ព្រោះពាក្យថា រសាត់និងសាត់ នេះជាពាក្យតែមួយប្រើជួសគ្នាបាន។ លុះចំណេរកាលយូរអង្វែងមក ក្លាយជា ពោធិ៍សាត់; សព្វថ្ងៃនេះ តាំងជាទីរួមខេត្តហៅថា ខេត្តពោធិ៍សាត់។

ពោធិ៍សាត់២

[ពោ-សាត់]

ន. ឈ្មោះក្រូចមួយប្រភេទ ព្រោះក្រូចប្រភេទនេះកើតមាននៅខេត្តពោធិ៍សាត់ជាដំបូងបង្អស់។ (គួរកុំហៅថា ខេត្តពោធិសត្វ, ក្រូចពោធិសត្វ ព្រោះ ពោធិ៍សាត់និងពោធិសត្វ ទាំងពីរនេះមានអត្ថន័យផ្សេងគ្នាឆ្ងាយណាស់) : ក្រូចពោធិ៍សាត់។

ពោពេញ ☒ ពោរពេញ ☑

ពោរពេញ

[ពោ-ពេញ]

គុ., គុ.កិ. ពេញព្រៀបកំពុង។

ព្យូរស្រែ ☒ ភ្ជួរស្រែ ☑

ភ្ជួរ

[ភ្ជួ]

កិ. រម្លើងដីដោយនង្គ័លឱ្យរបើកជាអាចម៍បំណះ : ភ្ជួរស្រែ, ភ្ជួរដីចម្ការ។

ថ្ងៃព្រហស្បត្តិ៍ ☒ ថ្ងៃព្រហស្បតិ៍ ☑

ព្រហស្បតិ៍១

[ព្រ-ហ៊ាស់] (សំ.វ្ឫហស្បតិ សំ. ក្ល.វ > ព, ឫ > រឹ = ព្រឹហស្បតិ)

ន. ឈ្មោះថ្ងៃទី៥នៃសប្តាហ៍ : ថ្ងៃព្រហស្បតិ៍។

ព្រឹក្សាយោបល់ ☒ ប្រឹក្សាយោបល់ ☑

ប្រឹក្សា

[ប្រឹក-សា] (សំ. បរីក្សា)

ន. ការពិចារណា, ដំណើរស្ទង់ការ, ការល្បងមើលឱ្យឃើញពិត; ការពិគ្រោះគ្នា។

កិ. ពិគ្រោះគ្នា, ជជែកពិគ្រោះគ្នាឱ្យឃើញហេតុឃើញដំណើរ : ចាំប្រឹក្សាគ្នាសិន, បានប្រឹក្សាយល់ព្រមគ្នាហើយ; គណៈកម្មការបានប្រឹក្សាគ្នាអស់រយៈកាលដ៏យូរ ...។

| | |
|---|---|
| ព្រៀបធៀប ☒ | ប្រៀបធៀប ☑ |

[ប្រៀប-ធៀប]

កិ. ធៀបប្រដូច, ប្រដូចដោយធៀបគ្នា។

| | |
|---|---|
| ព្រេងកូឡា ☒ | ប្រេងកូឡា ☑ |

ប្រេងកូឡា

[ប្រេង-កូ-ឡា]

ន. ឱសថម្យ៉ាងមានលក្ខណៈជាក្រមួនប្រើសម្រាប់លាបរឹតបំបាត់ការឈឺចាប់ ថ្លោះគ្រេច សត្វទិចឬខាំ។

ព្រៃរបស់ ☒ ព្រៃរបោះ ☑

ព្រៃរបោះ

[ព្រៃ-រ-បោះ]

ន. ប្រភេទព្រៃដុះរង្វើលៗ ដាច់ៗពីគ្នា ឬដុះដោយដុំៗ ដែលជាព្រៃធម្មជាតិ ឬជាព្រៃដែលនៅសេសសល់ពីការកាប់ឆ្ការដើម្បីតាំងទីលំនៅនិងដាំដំណាំ។

ព្រ័ត្រប្រាស់ ☒ ព្រាត់ប្រាស់ ☑

ព្រាត់ប្រាស

[ព្រាត់-ប្រាស]

កិ. (ម.ព. ប្រាស)។

ពំងា ☒ ពុំងា ☑

ពុំងា

[ពុំ-ងា]

គុ. ស្ងួនភ្ងា; ប្រសើរ, ថ្លៃថ្លា, ឆើតឆាយ (ច្រើនហៅស្ត្រីជាទីស្រឡាញ់ដោយថ្នមចិត្ត) : កែវពុំងា, ប្អូនពុំងា, ពៅពុំងា, មាសពុំងា ... (ព.កា.) ហៃប្អូនមាសពុំងា បងសូមលាកែវពិសី ត្រឡប់ទៅបុរី សូមប្អូនស្រីនាងកុំឃាត់។ (ម.ព. ភ្ងាប្រិយ ផង)។

ភ័ន្តច្រឡំ ☒ ភាន់ច្រឡំ ☑

ភាន់ច្រឡំ

[ភាន់-ច្រ-ឡំ]

កិ. ច្រឡំដោយភាន់។

# ពាក្យផ្ដើមដោយព្យញ្ជនៈ

# ភ

| | |
|---|---|
| ភាសារ ☒ | ភាសា ☑ |

ភាសា

[ភា-សា] (បា.; សំ.)

ន. សម្ដី, ពាក្យ : ភាសាសំស្រ្កឹត, ភាសាបាលី, ភាសាជាតិ, ភាសាបរទេស។ល។

| | |
|---|---|
| ភូតភ | ☒ | ភូតភរ ☑ |

ភរ

[ភ]

កិ. ពោលពាក្យមិនពិត, កុហក។

គុ.កិ., គុ. ដែលមិនពិត, កុហក : មនុស្សភរ, សម្ដីភរ; និយាយភរ។

ភ្ជួរលើជញ្ជាំង ☒ ព្យួរលើជញ្ជាំង ☑

ព្យួរ

[ព្យួ]

កិ. ពាក់, ថ្ពក់, ចងបន្តោក, បន្តោង : ព្យួរសម្លៀតនឹងនាគទណ្ឌ, ព្យួរសម្ពាយនឹងមែកឈើ។

ភ្ញៀវទេសចរ ☒ ភ្ញៀវទេសចរណ៍ ☑

ទេសចរ

[ទេ-សៈ-ច] (បា.)

ន. ជនអ្នកធ្វើដំណើរលម្ហែកម្សាន្ត : ប្រាសាទនគរវត្ត ជាទីចាប់អារម្មណ៍យ៉ាងក្រៃលែងនៃពួកទេសចរបរទេស។

ភ្អែកបន្ទោរ ☒ ផ្លេកបន្ទោរ ☑

ផ្លេកបន្ទោរ

[ផ្លេក-បន់-ទោ]

ន. ពន្លឺផ្លេកដែលចេញជាខ្សែភ្លែតៗឬដាលច្រវាត់ឯអាកាស។ (ម.ព. មហារីក២និងស្វាញញាក់ចិញ្ចើម ផង)។

# ពាក្យផ្តើមដោយព្យញ្ជនៈ

# ម

មន្ទី ☒ មន្ទីរ ☑

មន្ទីរ

[មន់-ទី] (បា.សំ. មន្ទីរ)

ន. គ្រឹះហា, ផ្ទះ, វិហារ ...។ ខ្មែរច្រើនហៅគ្រឹះហាធំៗ ដូចយ៉ាង ធម្មមន្ទីរ, សារមន្ទីរ ជាដើម។

មហិច្ឈតា ☒ មហិច្ឆតា ☑

មហិច្ឆតា

[មៈ-ហិច-ឆៈ-តា] (បា. មហា + ឥច្ឆតា)

ន. សេចក្តីប្រាថ្នាធំ, ការចង់បានច្រើន, សេចក្តីលោភលន់ : មហិច្ឆតា ជាធម្មជាតិនាំឱ្យមានការច្រណែនឈ្នានីសចំពោះគ្នីគ្នា។ (ព.ផ្ទ. អប្បិច្ឆតា)។

| | |
|---|---|
| មហិមារ ☒ | មហិមា ☑ |

មហិមា

[មៈ-ហិ-មា] (សំ. មហិមន៑, មហិមន្ត៑ ឬ មហិមា; បា. មហិមន្តុ > មហិមា)

ន. ភាវៈធំ, ទូលាយ។

គុ. ដែលមានច្រើន, ច្រើនក្រៃ, ក្រៃកន្លង; ធំសម្បើម, ដែលគួរស្បើម : ច្រើនមហិមា, ខ្លាំងមហិមា។

គុ.កិ. ដែលច្រើនក្រៃ, ដែលគួរស្បើម : ខឹងមហិមាឬខឹងមហិមន្ត។ (ព.កា.) កងពលច្រើនក្រៃមហិមា ឥតមានរួញរា គឃារុកចូលឥតក្រែង។ ក្រអឺតក្រទឺតឃើញស្តែង សន្ធាប់គ្នាឯង ឱ្យខ្លាចស្ងប់ស្ងែងរាល់ប្រាណ។ សត្រូវពុំអាចរុញច្រាន តទប់ពុំបាន ក៏រត់ប្រញាប់ថយក្រោយ។ (ច្រើននិយាយក្លាយថា មោះហិមា គួរលែងប្រើ)។

ម៉ដ្ឋចត់ ☒ ហ្មត់ចត់ ☑

ហ្មត់ចត់

[ម៉ត់-ចត់] (ស. ហ្មតចត អ.ថ. ហ្មុតចុត)

គុ.កិ., គុ. ស្អាត, បរិសុទ្ធ, ប្រពៃ, ឥតមន្ទិល; ត្រឹមត្រូវ; គ្រប់គ្រាន់; ដែលគួរដល់ការ : មនុស្សហ្មត់ចត់, ចិត្តហ្មត់ចត់, គំនិតហ្មត់ចត់; ធ្វើការហ្មត់ចត់, ចេះហ្មត់ចត់ (សរសេរជា ម៉ត់ចត់ ក៏មានតែ ម.ប្រ. ច្រើនតែប្រើតាមប្រភពដើមថា ហ្មត់ចត់ នេះឯង)។

ម៉ាក់ងាយ ☒ មាក់ងាយ ☑

មាក់ងាយ

[មាក់-ងាយ]

កិ. មើលងាយ។

ន. សេចក្ដីមើលងាយ។

| | |
|---|---|
| ម៉ាក់ប្រាង ☒ | មាក់ប្រាង ☑ |

មាក់ប្រាង

[មាក់-ប្រាង] (ស. មះប្រាង អ.ថ. ម៉ៈប្រាង)

ន. ឈ្មោះឈើមួយប្រភេទ ស្លឹកស្រដៀងនឹងស្វាយ តែតូចៗជាងចុងស្រួចៗផ្លែខ្ចីមានរសជូរ លុះដល់ទុំមានសម្បុរលឿង, ប្រើបរិភោគជាអាហារ; ខ្លះមានរសផ្អែម (ច្រើនមានសម្បូណ៌នៅខេត្តបាត់ដំបង គេដាំជាដំណាំស្រុក), ខ្លះមានរសផ្អែមលាយជូរ (ច្រើនមានសម្បូណ៌នៅព្រៃភ្នំខ្លះដោយអន្លើ ក្នុងខេត្តកំពត)។

| | |
|---|---|
| ម៉ាក់ប្រេង ☒ | មាក់ប្រេង ☑ |

មាក់ប្រេង

[មាក់-ប្រេង] (ស. មះប្រិង អ.ថ. ម៉ៈព្រិង)

ន. ឈ្មោះឈើមួយប្រភេទសន្ដានមាក់ប្រាង តែស្លឹកធំៗជាងបន្ដិចផ្លែតូចៗជាងមាក់ប្រាង។ (ច្រើនមានសម្បូណ៌នៅព្រៃភ្នំខ្លះដោយអន្លើក្នុងខេត្តកំពត, អ្នកស្រុកកំពតច្រើនហៅ មាក់ប្រិង)។

| | |
|---|---|
| ម៉ាស៊ិន ☒ | ម៉ាស៊ីន ☑ |

ម៉ាស៊ីន

[ម៉ា-ស៊ីន] (បារ. machine)

ន. គ្រឿងចក្រ, គ្រឿងយន្ត, យន្ត : ម៉ាស៊ីនកប៉ាល់, ម៉ាស៊ីនកិនស្រូវ, ម៉ាស៊ីនទឹក, ម៉ាស៊ីនភ្លើង, ម៉ាស៊ីនបោះកប្បាស, ម៉ាស៊ីនរថយន្ត។ល។ (ច្រើនហៅក្លាយថា ម៉ាស៊ិនឬម៉ាស៊ឹន)។

ម៉េស ☒ ម្ល៉េះ ☑

ម្ល៉េះ

[ម្ល៉េះ]

គុ.កិ. យ៉ាងនេះ, ដូច្នេះ : ម្ល៉េះតើ; ម្ល៉េះម៉ឹងឬ?; ម្ល៉េះសមលំបាកណាស់ដឹង?; លំបាកអ្វីម្ល៉េះ!; យូរម្ល៉េះ?; ឱម្ល៉េះៗអ៊ិចា:!

ម៉ែត ☒ ម៉ែត្រ ☑

ម៉ែត្រ

[ម៉ែត] ឬ [ម៉ិត] (បារ. mètre)

ន. ឈ្មោះរង្វាស់បារាំងសែស ប្រវែងដប់ដេស៊ីម៉ែត្រឬមួយរយសង់ទីម៉ែត្រ ឬក៏មួយពាន់មិល្លីម៉ែត្រ, ជារង្វាស់ដែលក្នុងសម័យសព្វថ្ងៃនេះ ខ្មែរចេះប្រើពេញទាំងកម្ពុជរដ្ឋ, បើធៀបនឹងរង្វាស់របស់ខ្មែរពីដើមត្រូវគ្នានឹងប្រវែងពីរហត្ថជាងឈើ ដែលហៅ

ថា ហត្ថខ្នាត (ពីរហត្ថខ្នាត), ធៀបនឹងហត្ថមនុស្សប្រក្រតីសព្វថ្ងៃនេះ ច្រើនតែពីរហត្ថមួយទះឬលើសខ្វះពីនោះបន្តិចបន្តួច (ម៉ែត្រសរសេរកាត់ថា ម.)។

| | |
|---|---|
| ម៉្សៅ ☒ | ម្សៅ ☑ |

ម្សៅ

[ម្សៅ]

ន. ផង់ដែលធ្វើពីអង្ករ, ពោត, សណ្តែក, មើមដំឡូងជាដើម : ម្សៅខ្សាយ, ម្សៅដំណើប, ម្សៅជ្រៃ, ម្សៅឈូក, ម្សៅដំឡូង, ម្សៅពោត, ម្សៅសណ្តែក, ម្សៅល្មៀត។ល។

| | |
|---|---|
| មានវិប្បដិសារី ☒ | មានវិប្បដិសារៈ ☑ |

វិប្បដិសារៈ

[វិប-ប៉ៈ-ដិ-សា-រ៉ៈ] (បា. វិប្បដិសារ ឬ សំ. វិប្រតិសារ)

ន. សេចក្ដី ក្ដៅ ក្រហាយចិត្ត, សេចក្ដី នឹកស្ដា យក្រោយ, សេចក្ដីនឹកតូចចិត្ត ព្រោះដឹងខ្លួនជាខុស : មានវិប្បដិសារៈ។

| | |
|---|---|
| មាយាទ ☒ | មារយាទ ☑ |

មារយាទ១

[មា-រ:-យាត] ឬ [មា-យាត] (បា. មរិយាទា; សំ. មយ៌ាទា)

ន. ខេត្ត, ដែន; ព្រំដែន; ភ្លឺ (ភ្លឺស្រែជាដើម); ...។

មារយាទ២

[មា-រ:-យាត] ឬ [មា-យាត]

ន. អាចារៈ, សណ្ដាប់ធ្នាប់, របៀប, របប, ឫក, ឫកពា : មារយាទថោក, មារយាទថ្លៃ, មានមារយាទ, ឥតមារយាទ ...។

| | |
|---|---|
| មិត្តភ័ក្តិ ☒ | មិត្តភក្តិ ☑ |

មិត្តភក្តិ

[មិត-ភ័ក]

ន. (ម.ព. មិត្រភក្តិ)។

| | |
|---|---|
| មិនា ☒ | មីនា ☑ |

មីនា

[មី-នា]

ន. ឈ្មោះខែទី៣តាមសុរិយគតិ មានរាសីរូបត្រី។

| | |
|---|---|
| មួរម៉ៅ ☒ | មួម៉ៅ ☑ |

មួម៉ៅ

[មួ-ម៉ៅ] (ស. ម្វ័មៅ អ.ថ. មួម៉ៅ ប្រើជា កិ."ស្រវឹងជ្រប់, វង្វេងស្មារតី, ...")

គុ.កិ. ខឹងក្ដាញ់, ក្ដៅក្ដួល, ខឹងដាលវ៉ាល : ចេះតែមួម៉ៅឥតស្រាក, មួម៉ៅក្ដៅចិត្ត។

មេក្លោង ☒ មេខ្លោង ☑

មេខ្លោង

[មេ-ខ្លោង]

១). ន. មេដំរីដែលមានមាឌធំសម្បើមជាប្រធានលើហ្វូង។

មេខ្លោង

២). ន. (ព.ប្រ.) មនុស្សដែលមានរូបរាងធំខ្ពស់ជ្រងោ កាលបើដើរចេញទៅណាឃើញចង្គ្រោងជាងគេរាល់គ្នា។

មេខ្លោង

៣). ន. (ព.ប្រ.) មេគំនិត, មេនាំអាទិ៍ (ច្រើនប្រើក្នុងន័យអវិជ្ជមាន)។

មោទកៈភាព ☒ មោទកភាព ☑

មោទកភាព

[មោ-ទៈ-កៈ-ភាប] (សំ.បា. មោទក + ភាវ)

ន. ភាពឬភាវៈជាអ្នករីករាយ, ភាវៈនៃសេចក្តីត្រេកអរ, សេចក្តីអរគុណ : មានមោទកភាព។

| | |
|---|---|
| ម៉្សៅម៉ត់ ☒ | ម្សៅម៉ដ្ឋ ☑ |

ម៉ដ្ឋ

[ម៉ត់]

គុ. (ម.ព. ម៉ដ្ត)។

| | |
|---|---|
| ម៉ាក់ក្លឿ ☒ | មក្លឿ ☑ |

មក្លឿ

[មៈ-ក្លឿ] (ស. មះក្លើ អ.ថ. ម៉ៈក្លឿ)

ន. ឈ្មោះឈើដំណាំមួយប្រភេទ ផ្លែប្រើជាគ្រឿងជ្រលក់សំពត់ យកព័ណ៌ខ្មៅ; ខ្លឹមមានសម្បុរខ្មៅ សាច់រឹងប្រើធ្វើជាការឈើ វាយរងបាន : សំពត់ជ្រលក់មក្លឿ។ (សរសេរជា មាក់ក្លឿ ក៏មាន; ខ្មែរ ហៅ ខ្នួញ ជាគូគ្នានឹង ខ្នាញ់)។

# ពាក្យផ្ដើមដោយព្យញ្ជនៈ

# ឃ

យល់សប្តិ៍ ☒ យល់សប្តិ ☑

យល់សប្តិ

[យល់-សប់]

កិ. សុបិន, យល់សុបិន។

យ៉ូនយកកំណើត ☒ យោនយកកំណើត ☑

យោនយកកំណើត

[យោន-យក-កំ-ណើត] (ស. យោន អ.ថ. យ៉ូន "ពោះ, ពួយ...")

កិ. អន្ទោលចាប់កំណើត, ចាប់ជាតិ : កាលព្រះអង្គយោនយកកំណើតកើតជាព្រះមហាជនក។

យោទ្ធភូមិភាគ ☒ យោធភូមិភាគ ☑

យោធភូមិ

[យោ-ធៈ-ភូម]

ន. បន្ទាយយោធា, ទីតាំងនៃកងទ័ព។

# ពាក្យផ្ដើមដោយព្យញ្ជនៈ

# រ

ឫកពា ☒ ឫកពាក ☑

ឫកពា

[រឹក-ពា]

ន. (ម.ព. ឫក)។

រក្សារ ☒ រក្សា ☑

រក្សា

[រ័ក-សា] (សំ. រក្ស; បា. រក្ខ)

កិ. ថែ, ថែទាំ; បីបាច់, ចិញ្ចឹម; កាន់; កាន់កាប់; ការពារ;

ប្រយ័ត្ន : រក្សាទ្រព្យ, រក្សាខ្លួន, រក្សាមារយាទ, រក្សាសីល។

| | |
|---|---|
| រងចាំ ☒ | រង់ចាំ ☑ |

រង់

[រ៉ង់] (សំ. រង្គ "យូរ, យិតយូរ")

កិ. បង្អង់ចាំ, ឈប់បង្អង់ : រង់មួយស្របក់សិន, រង់ចាំបន្តិចសិន។ (ម.ព. រារង់ ផង)។

| | |
|---|---|
| រណៈសិរ្ស ☒ | រណសិរ្ស ☑ |

រណសិរ្ស

[រៈ-ណៈ-សេ]

ន. ក្បាលទ័ព, ខាងមុខនៃកងទ័ព; ជួរនៃកងទ័ពដែលរៀបចំត្រៀមខ្លួនចាំឈមមុខបម្រុងប្រយុទ្ធនឹងបច្ចាមិត្ត។

| | |
|---|---|
| រតន:គិរី ☒ | រតនគិរី ☑ |

រតនគិរី

[រ័ត-តៈ-ណាៈ-គិ-រី]

ន. ឈ្មោះខេត្តមួយនៃកម្ពុជរដ្ឋ, បំបែកចេញពីខេត្តស្ទឹងត្រែង ហើយតែងតាំងឡើងពីឆ្នាំ ១៩៥៩(ព្រះរាជក្រមលេខ ២៩៨ នស. ចុះថ្ងៃទី ១៧កុម្ភៈ ១៩៥៩)។

| | |
|---|---|
| រត់យន្ត ☒ | រថយន្ត ☑ |

រថយន្ត

[រត់-យន់]

ន. រថមួយប្រភេទដែលជាទូទៅមានកង់បួន មានទ្រង់ទ្រាយផ្សេងៗច្រើនបែប, មានចង្កូត, មានគ្រឿងទប់, ...បើកឱ្យ

លឿនទៅមុខឬឱ្យថយមកក្រោយក៏បានដោយកម្លាំងគ្រឿងយន្ត ប្រើថាមពលឥន្ធនៈឬថាមពលផ្សេងទៀត : បើករថយន្ត, ជិះរថយន្ត។ (ម.ព. យន្តឬយន្ត្រ ផង)។

| | |
|---|---|
| រថក្រុស ☒ | រថក្រោះ ☑ |

រថក្រោះ

[រត់-ក្រោះ]

ន. រថចម្បាំងយោធាដែលមានកង់ច្រវាក់ធំៗនិងបំពាក់ដោយកាំភ្លើងធំ។

| | |
|---|---|
| រិតបន្តឹង ☒ | រឹតបន្តឹង ☑ |

រឹត១

[រឹត]

គុ.កិ. កាន់តែ, ចេះតែ : រឹតខូច, រឹតល្អ, រឹតតែខ្លាំងឡើង។

| | |
|---|---|
| របល់យ ☒ | រំបល់យក៏ ☑ |

រំបល់

[រុំ-បល់]

១). ន. អាសន្នរោគគ្រប់យ៉ាង : ជំងឺរំបល់ (ព.គ.) ជំងឺអាសន្ន, អាសន្នរោគ, ជំងឺខ្យល់។

២). ពាក្យជេរដោយទ្រគោះ : រំបល់កាច់! រំបល់យក៏!, រំបល់បោស!

៣). ពាក្យសាមញ្ញជាឧទានឬជេរគ្នាលេងដោយស្និទ្ធស្នាល : រំបល់ កុំលេង!, រំបល់យក៏! យករបស់អញទៅណា? (ម.ព. រំលេះ ផង)។

| | |
|---|---|
| រមនីយដ្ឋាន ☒ | រមណីយដ្ឋាន ☑ |

រមណីយដ្ឋាន

[រៈ-មៈ-នី-យ័ត-ឋាន]

ន. ទី, តំបន់ដែលគួររីករាយ, ដែលសប្បាយ។

| | |
|---|---|
| រយះពេល ☒ | រយៈពេល ☑ |

រយៈ

[រ-យៈ] (សំ.បា. រយ "សន្ទុះ, ល្បឿន, ដំណើររួសរាន់, ឆាប់, រហ័ស")

ន. សង្កាត់, ថ្នាក់, ភាគ, កម្រិត : រយៈកាល, រយៈផ្លូវ, រយៈវេលា, រយៈពាក្យ។

| | |
|---|---|
| ឬស ☒ | ឫស ☑ |

ឫស១

[រឹស]

១). ន. អវយវៈចំណែកមួយរបស់រុក្ខជាតិ, តិណជាតិ, វល្លិជាតិ ដែលជាទូទៅដុះចាក់ចុះទៅក្នុងដី សម្រាប់ស្រូបយករសជាតិដី ដូចជាអាហារឬដែលដុះស្រោបដើមឈើជាដើម : ឫសឈើ, ឫសស្មៅ, ឫសវល្លិ, ឫសប្រទាលផ្ញើប្រាណ។

២). ចុងគល់ធ្មេញដែលដុះក្នុងសាច់អញ្ចាញធ្មេញ : ឫសធ្មេញ។

៣). កំណាត់ឈើឬសសរបេតុងជាដើមដែលបុកបង្កប់ក្នុងរណ្ដៅបញ្ចាល់ដីឱ្យណែនដើម្បីកុំឱ្យស្រុត : បុកឫសរណ្ដៅសសរសង់វិហារ, សង់គេហដ្ឋានធំៗ។

ឫស២

[រឹស]

ន. (ភាសា.) វចនតាមួយបែបដែលជាមូលដ្ឋានក្នុងការបង្កើតបានជាពាក្យផ្សេងទៀតតាមរយៈបម្រែបម្រួលសូរឬការបន្ថែមរូបសព្ទ ដូចជាការផ្សំ ការដាក់ផ្នត់ជាដើម : ពាក្យ racine ក្នុងភាសាបារាំងប្រែមកជាភាសាខ្មែរថា ឫស។

ឫស៣

[រឺស]

ន. រោគមួយប្រភេទដុះចេញពីសាច់ មានសណ្ឋានជាពកតូច មូលរឹង : កើតឫសនៅកែងដៃ។

ប្ញស្សី ☒ ឫស្សី ☑

ឫស្សី

[រឺស-សី]

ន. តចសារជាតិមួយប្រភេទ ដុះទំពាំងបែកចេញជាគុម្ព ដើមមានថ្នាំង, មានច្រើនប្រភេទ : ឫស្សីស្រុក, ឫស្សីព្រៃ, ឫស្សីរលៀក, ឫស្សីត្រាច់, ឫស្សីឃ្លៃ, ឫស្សីថ្ង, ឫស្សីទ្រនំមាន់, ...។ (និយាយថា រសី ក៏មានខ្លះ)។

| | |
|---|---|
| រស់ជាតិ ☒ | រសជាតិ ☑ |

រសជាតិ

[រស់-ជាតិ] (បា.)

ន. ជាតិរបស់រស, រសឆ្ងាញ់ពិសា ជាតិរបស់អាហារ ដែលមានជាតិ ផ្អែម, ប្រៃ, ល្វីង, ជូរ, ចត់ជាដើម : ផ្លែស្វាយមានរសជាតិជូរឆ្ងាញ់។

| | |
|---|---|
| រាគរុស ☒ | រាគរូស ☑ |

រាគរូស

[រាក-រូស]

ន.រាកឧច្ចារៈដូចជារូសចេញមក។

| | |
|---|---|
| រាងខ្លួន ☒ | រៀងខ្លួន ☑ |

រៀងខ្លួន

[រៀង-ខ្លួន]

រាល់ខ្លួន, សព្វខ្លួន។

| | |
|---|---|
| រាជបល្លង្គ ☒ | រាជបល្ល័ង្គ ☑ |

រាជបល្ល័ង្គ

[រាច-ប៉ុល-ឡ័ង]

ន. បល្ល័ង្ករាជ្យ (បល្ល័ង្កក្រោមស្វេតឆត្រ)។

រាបសារ ☒ រាបសា ☑

រាបសា

[រាប-សា]

គុ. ដែលមិនប្លែកពីគេ, យ៉ាងកណ្ដាល, សាមញ្ញ : មនុស្ស រាបសា, សម្ដីរាបសា, របស់រាបសា។

រឹងពឹង ☒ រឹងប៉ឹង ☑

រឹងប៉ឹង

[រឹង-ប៉ឹង]

គុ.កិ., គុ.រឹងមាំ, ម៉ឹងម៉ាត់, ពេញកម្លាំង : គំនិតរឹងប៉ឹង; ធ្វើការរឹងប៉ឹង។

រុញរា ☒ រួញរា ☑

រួញរា

[រួញ-រា]

កិ. រួញថយក្រោយ, ញញើតញញើម : ចិត្តរួញរា។ (ម.ព. រញ៉់ ផង)។

រួមរ័ក្ស ☒ រួមរក្ស ☑

រួមរក្ស

[រួម-រ័ក]

កិ. រួមគ្នារក្សា, ជួយរក្សាគ្នា។

| | |
|---|---|
| រើយៗ ☒ | រឿយៗ ☑ |

រឿយ

[រឿយ]

គុ.កិ. ត្រឿន; ស្មើៗ; ញយ, ញឹកញយ : អណ្ដែតរឿយ; ទៅមកតែរឿយ, តែងឃើញរឿយៗ, ពិចារណារឿយៗ។ (បា. ថា បុនប្បុនំ, ចាស់ៗពីដើមប្រើពាក្យនេះខ្លះដែរ ដូចជា ខ្ញុំធ្លាប់ទៅបុនប្បុនំ)។

| | |
|---|---|
| រៀងមូល ☒ | រាងមូល ☑ |

រាង១

[រាង]

ន. សណ្ឋាន, ទ្រង់, ទ្រង់ទ្រាយ : រាងក្រអាញ, រាងច្រឡោ, រាងរល, រាងស្តើង។ (ម.ព. រូប ផង)។

រោជ ☒ រោច ☑

រោច១

[រោច]

កិ. ចាប់ គើចទាញហូតយកចេញខ្លះឬយកចេញតែមួយៗ : រោចឧស, រោចឫស្សី, រោចផ្តៅ។

រោច២

[រោច]

ន. ថ្ងៃខាងរនោចនៃខែចន្ទគតិ តាំងពីថ្ងៃទី១ដល់ថ្ងៃទី១៤ឬទី១៥ គឺថ្ងៃដែលមានពន្លឺព្រះចន្ទ្រថយចុះដូចគេចាប់រោចចេញ : ថ្ងៃសុក្រ ២រោច ខែស្រាពណ៍ ឆ្នាំ ថោះ ឯកស័ក ព.ស.២៤៨២។ (បើប្រើលេខត្រូវសរសេរជា ថ្ងៃ ៦᧲៩ឆ្នាំ ...។ ព.ផ្ទ. កើត៣)។

| | |
|---|---|
| រំលឹក ☒ | រំឭក/រម្លឹក ☑ |

រម្លឹក

[រុំ-លឹក]

កិ. ធ្វើឱ្យរឭកឃើញ គឺឱ្យនឹកឃើញ, ឱ្យភ្ញាក់ស្មារតី, ឱ្យចាំឡើងវិញ : រម្លឹកស្មារតី, រំលឹកគ្នា, រំឭកមេទន្ទេញ។ (បុរាណសរសេររំលឹក ក៏បាន; សម័យឥឡូវក៏សរសេរ រំឭក រំលឹក ឬរម្លឹក នេះ ប្រើជាជំនួសគ្នាបានតាមត្រូវការ)។

# ពាក្យផ្ដើមដោយព្យញ្ជនៈ

# ល

ល័ក្ខខ័ណ្ឌ ☒ លក្ខខណ្ឌ ☑

លក្ខខណ្ឌ

[លាក់-ខាន់] (បា. លក្ខ + ខណ្ឌ)

ន. កម្រិត; សង្កាត់, ប៉ែកដោយឡែក; កំណត់គោល; ព្រំ : ទីមានលក្ខខណ្ឌ, សម្ដីមានលក្ខខណ្ឌ, ត្រូវធ្វើលក្ខខណ្ឌឱ្យទៀងទាត់។

លប់មុខ ☒ លុបមុខ ☑

លុប

[លុប] (សំ.បា.)

១). កិ. ធ្វើឱ្យបាត់ស្នាម, ឱ្យបាត់គំនូស, ឱ្យបាត់លំអាន, ឱ្យបាត់រូប, ឱ្យបាត់ឈ្មោះ; ធ្វើឱ្យវិនាស, ឱ្យសូន្យ; បំបាត់មិនឱ្យមាន : លុបអក្សរ, លុបដាន, លុបឈ្មោះ។

២). បំពេញក្រហូង, ជម្រៅ, រណ្ដៅ ឱ្យបាត់ : លុបអណ្ដូង, លុបរណ្ដៅ។

៣). លាង, ជម្រះស្រលាប ដោយទឹក : លុបមុខ, លុបខ្លួន។

៤). គ្របលើ, លើសជាង : សម្ដីលុបលើ, សំឡេងឮលុបគេទាំងអស់។

| | |
|---|---|
| លលាក្បាល ☒ | លលាដ៍ក្បាល ☑ |

លលាដ៍

[ល-លា]

ន. (ម.ព. លលាដ)។

| | |
|---|---|
| លិត ☒ | លិទ្ធ/ លិឍ ☑ |

លិឍ

[លិត] ឬ [លឹត] (សំ. ឬ បា. < លិហ, ហ > ឍ ឬ ទ្ធ)

កិ. កេវ, កាវ, កោយដោយអណ្ដាតឬផ្ដិតចុងអណ្ដាតលើអ្វីមួយ : លិឍបបូរមាត់, លិឍដៃ; លិទ្ធមើលឱ្យដឹងរស។

លិទ្ធិ ☒ លទ្ធិ ☑

លទ្ធិ

[ឡ័ត-ធិ] (បា.; សំ. លព្ធិ)

ន. ការឃើញ, សេចក្ដីយល់ឃើញ; សេចក្ដីប្រកាន់ជំនឿ, ជំនឿ (យ៉ាងដូចជឿសាសនាជាដើម); ការប្រកាន់តាមយោបល់របស់ខ្លួនឬតាមទម្លាប់; ពិធី, បែបបទ; ការនិយម : លទ្ធិពុទ្ធ, លទ្ធិព្រាហ្មណ៍, លទ្ធិនិគ្រន្ថ, លទ្ធិហោរ, មនុស្សមានលទ្ធិ ផ្សេងគ្នា។

លុបចោល ☒ លប់ចោល ☑

លុប

[លុប] (សំ.បា.)

១). កិ. ធ្វើឱ្យបាត់ស្នាម, ឱ្យបាត់គំនូស, ឱ្យបាត់លំអាន, ឱ្យបាត់រូប, ឱ្យបាត់ឈ្មោះ; ធ្វើឱ្យវិនាស, ឱ្យសូន្យ; បំបាត់មិនឱ្យមាន : លុបអក្សរ, លុបដាន, លុបឈ្មោះ។

២). បំពេញក្រហូង, ជម្រៅ, រណ្ដៅ ឱ្យបាត់ : លុបអណ្ដូង, លុបរណ្ដៅ។

៣). លាង, ជម្រះស្រលាប ដោយទឹក : លុបមុខ, លុបខ្លួន។

៤). គ្របលើ, លើសជាង : សម្ដីលុបលើ, សំឡេងឮលុបគេទាំងអស់។

លេចផ្លោរ ☒ លេចធ្លោ ☑

លេចធ្លោ

[លិច-ធ្លោ]

កិ., គុ. (ព.ប្រ.) លេចចេញច្បាស់ជាងគេ, មានប្រជាប្រិយភាពជាងគេ, លេចមុខលេចមាត់ខ្លាំងជាងគេ : ស្នាដៃលេចធ្លោ, ចំណុចលេចធ្លោជាងគេ។

លោកទេស ☒ លោកទេសន៍ ☑

ទេសន៍

[ទេស] (បា. ទេសនា)

ន. ដំណើរសម្ដែង, ការសម្ដែងធម៌ : ស្ដាប់ទេសន៍។

កិ., គុ. សម្ដែងធម៌, ដែលសម្ដែងធម៌ : និមន្តលោកទេសន៍; សាស្ត្រាទេសន៍។ (ខាង កិ.ឬគុ. គួរប្រើ ទេសវិញ។ ម.ព. ទេស២)។

លោះ ☒ លស់ ☑

លស់

[លស់]

១). កិ. ធ្វើឱ្យលស់ គឺបន្ថយចំនួនឬធ្វើឱ្យតិចចុះមិនឱ្យនៅតាមចំនួនដើម : ក្នុងចំនួន ១០ លស់៣ចេញ នៅសល់៧។

២). វំលេង : គ្រុនលស់ គ្រុនវំលេងថ្ងៃ គឺគ្រុនមួយថ្ងៃខានមួយថ្ងៃ។

លំនៅដ្ឋាន ☒ លំនៅឋាន ☑

លំនៅឋាន

[លំ-នៅ-ឋាន]

ន. (ម.ព. លំនៅ)។

លំហអាកាស ☒ លម្ហអាកាស ☑

លម្ហ

[លំ-ហ]

១). ន. ទីដែលវាលល្ហ : លម្ហសមុទ្រ។

២). ឋានក្រោមជើងហោជាងនៃប្រាសាទឬវិហារមុខដាច់ ដែលមើលពីដីទៅឃើញល្ហ ព្រោះមិនមានដំបូលបាំងសាច : លំហានាងច្រាលគឺលំហានិងនាងច្រាល។ (ម.ព. នាងច្រាល ផង សរសេរជា រម្ហឬរំហាក៏មាន)។

លំហែរ ☒ លំហែ ☑

លំហែ

[លំ-ហែ]

កិ. (ម.ព. លម្ហែ)។

លំអរ ☒ លម្អ ☑

លម្អ

[លំ-អរ]

ន. សេចក្តីល្អ, ភាវៈល្អ គឺបែបភាព, បែបបទ, លំនាំ, សណ្ឋាន , ទ្រង់, កិរិយា ...ដែលល្អ : លម្អរូប; ខន្តីជាលំអររបស់អ្នកប្រាជ្ញ។

# ពាក្យផ្ដើមដោយព្យញ្ជនៈ

# វ

ខន សំាងហោ -២៤៥

វណ្ណយុត្ត ☒ វណ្ណយុត្តិ ☑

វណ្ណយុត្ត

[វ័ន-ណៈ-យុត] (បា.; សំ. វណ៌យុក្ត ឬ វណ៌យុក្តិ)

ន. គ្រឿងប្រដាប់សម្រាប់ប្រើផ្សំជាមួយនឹងអក្សរ; វណ្ណយុត្ត សម្រាប់ប្រើក្នុងភាសាខ្មែរមាន១៨យ៉ាង គឺ ១-វិសជ៌នីឬវិសគ៌ៈ ឬក៏ រះមុខ (ះ); ២-មូសិកទន្តឬធ្មេញកណ្តុរ (៉); ៣-ត្រីសព្ទ (៊); ៤-ទណ្ឌឃាតឬបដិសេធ (៍); ៥-របាទឬរេផៈ (៌); ៦-រស្សសញ្ញាឬបន្តក់ (់); ៧-សំយោគសញ្ញា (័); ៨-លេខទោឬអាមេណ្ឌិតសញ្ញា (ៗ); ៩-លេខអស្តា (៏); ១០-កាកបាទឬជើងក្អែក (+); ១១-កុក្កុដនេត្រ ឬភ្នែកមាន់ (๏); ១២-របះ (។); ១៣-របះចប់ឬរបះបរិយោសាន (៕); ១៤-គោមូត្រ (๛-); ១៥-រ៉ាត់ឬគាប (}); ១៦-រជ្ជុសញ្ញា; ១៧-មច្ឆណ្ឌសញ្ញាឬពងត្រី (...) ១៨-បេយ្យាល (។ បេ។ឬ(។ល។); ជា១៩ យ៉ាងនឹង យុគលពិន្ទុ នេះ (ៈ) ដែលទើបនឹងបង្កើតថ្មី សម្រាប់ប្រើ ចុចសម្រួលពាក្យឱ្យងាយថា, ដូចជា ធុរៈ, ភារៈ, ព្យូហៈ, លក្ខណៈ ជា

ដើម។ ក្នុងវចនានុក្រមនេះ មានប្រើវណ្ណយុត្តរបស់អឺរ៉ុបផង គឺ . :?! = < > " " សម្រួលតាមសម័យនិយម (ដែលក្នុងសម័យបច្ចុប្បន្នបានឱ្យឈ្មោះជា សំ.បា. ឬជាខ្មែរអស់ហើយ)។

| | |
|---|---|
| វណ្ណះ ☒ | វណ្ណៈ ☑ |

វណ្ណៈ

[វ័ន-ណៈ]

ន. (ម.ព. វណ្ណ)។

| | |
|---|---|
| វណ្ណៈកម្ម ☒ | វណ្ណកម្ម ☑ |

វណ្ណកម្ម

[វ័ន-ណៈ-កាំ]

ន. ស្នាដៃតែងនិពន្ធឬវិចិត្រកម្ម : វណ្ណកម្មអក្សរសិល្ប៍, វណ្ណកម្មប្រលោមលោក។

វរសេនិយ ☒ វរសេនីយ៍ ☑

វរសេនិយ

[វៈ-រៈ-សេ-ណី]

ន. ឋានន្តរស័ក្តិនាយទាហានជាន់ខ្ពស់ ចាប់ពីសក្តិ៤ឡើងទៅ។

វល្លី៍ ☒ វល្លិ ☑

វល្លិ

[វ៉ល] (សំ.បា. វល្លី)

ន. លតា : បោចវល្លិធ្វើចំណង។

"វ៉ាលី ☒ "វ៉ាលិស ☑

"វ៉ាលិស

[វ៉ា-លិស] (បារ. valise អ៊ីតាលី valigia)

ន. ហិបតូចស្រាល ធ្វើដោយស្បែកសម្លាប់ឬធ្វើដោយសំពត់សាច់ក្រាស់ជាដើម មានដៃយួរបាន សម្រាប់ដាក់អីវ៉ាន់ស្រាលៗ មានសម្លៀកបំពាក់ជាដើម :"វ៉ាលិសស្បែក។

វ៉ៃ ☒ វ៉ាយ ☑

វ៉ាយ១

[វ៉ាយ]

១). កិ. (ព.សា.) (វៃ) ប្រហារដោយបហារណវត្ថុឥតមុខមុត មានរំពាត់, ដំបងជាដើម : វាយដោយរំពាត់, វាយមួយដំបង។

២). សំពងឱ្យមុតលិចចុះ : វាយដែកគោល។

៣). សំពងបញ្ចូលឱ្យណែនតឹង : វាយរនុកក្រោល។

៤). ទូង, គោះ ឬដំឱ្យលាន់ឮសូរសព្ទ : វាយស្គរធំ, វាយរគាំង, វាយគង។

៥). យកសេចក្តីឬលម្អិតសេចក្តីឱ្យជាក់ប្រាកដ : វាយសេចក្តីមិនបែក។

៦). តថ្លៃ : វាយថ្លៃទំនិញ។

៧). ច្បាំងគ្នា, ច្បាំងដណ្តើមយកស្រុក : វាយកងទ័ពបច្ចាមិត្ត, វាយយកស្រុក។

វាចារ ☒ វាចា ☑

វាចា

[វ៉ា-ចា] (បា.; សំ. វាចិ, វាចា)

ន. សម្ដី។

| | |
|---|---|
| វាលលំហ ☒ | វាលលម្ហ ☑ |

វាលលម្ហ

[វ៉ាល-លំ-ហ]

ន. តំបន់ស្ងួតហួតហែង មានកម្ពស់ទឹកភ្លៀងប្រចាំឆ្នាំមិនលើសពី១០០មិល្លីម៉ែត្រ មានដង់ស៊ីតេសព៌ាង្គកាយមានជីវិតទាប ហើយខ្សត់ពពួកសត្វនិងរុក្ខជាតិ : វាលលម្ហសាហារ៉ា។

| | |
|---|---|
| វិក្ក័យប័ត្រ ☒ | វិក្កយបត្រ ☑ |

វិក្កយបត្រ

[វិក-កៈ-យ៉ៈ-ប័ត] (បា. <វិក្កយ "ការលក់ទំនិញ" + សំ. បត្រ "ក្រដាស, សន្លឹកក្រដាស")

ន. សំបុត្រាយមុខទំនិញ ដែលបានលក់, តារាងរាយរាប់មុខអីវ៉ាន់ ដែលលក់ ព្រមទាំងតម្លៃអីវ៉ាន់នោះៗដែលអ្នកលក់ត្រូវទារយកពីអ្នកទិញ : សងថ្លៃទំនិញតាមចំនួនដែលចុះក្នុងវិក្កយបត្រ។ (ប្រើជា វិក្រយបត្រ ក៏បាន)។

| | |
|---|---|
| វិចនំ ☒ | វេចនំ ☑ |

វេច

[វេច]

១). កិ. ធ្វើឱ្យជាបង្វេច : វេចសម្ពាយ។

| | |
|---|---|
| វិញ្ញាណក្ខ័ន្ធ ☒ | វិញ្ញាណក្ខន្ធ ☑ |

វិញ្ញាណក្ខន្ធ

[វិញ-ញា-ណ័ក-ខ័ន]

ន. កងវិញ្ញាណ (ពួកចិត្ត) ដែលរាប់បញ្ចូលក្នុងខន្ធ៥។ (ម.ព. បញ្ចក្ខន្ធ ផង)។

| | |
|---|---|
| វិធានការ ☒ | វិធានការណ៍ ☑ |

វិធានការ

[វិ-ធា-នៈ-កា]

១). ន. ការមានរបៀបរៀបរយ, របៀបចាត់ការ។

២). វិធីឬមធ្យោបាយសម្រាប់ការពារប្រុងប្រយ័ត្ន : ចាត់វិធានការ, ធ្វើតាមវិធានការ។

| | |
|---|---|
| វិនិយោគទន់ ☒ | វិនិយោគទុន ☑ |

ទុន

[ទុន]

ន. ប្រាក់ដើម, របស់ដើម គឺប្រាក់ឬរបស់សម្រាប់ចាយ, សម្រាប់ប្រើប្រកបកិច្ចការ ឱ្យចម្រើនប្រយោជន៍ឡើង : ដើមទុន, ខាតទុន។

| វិបាស្សនា ☒ | វិបស្សនា ☑ |
|---|---|

វិបស្សនា

[វិ-ប៉ុស-សៈ-ណា] (បា.)

ន. ការពិចារណាឃើញច្បាស់តាមពិត; ប្រាជ្ញាពិចារណាឃើញច្បាស់នូវដំណើរសង្ខារធម៌តាមការណ៍ពិត (ព.ពុ.)។

| វិប្បដិសារី ☒ | វិប្បដិសារៈ ☑ |
|---|---|

វិប្បដិសារៈ

[វិប-ប៉ៈ-ដិ-សារ៉ៈ] (បា. វិប្បដិសារ ឬ សំ. វិប្រតិសារ)

ន. សេចក្ដីក្ដៅក្រហាយចិត្ត, សេចក្ដីនឹកស្ដាយក្រោយ, សេចក្ដីនឹកតូចចិត្ត ព្រោះដឹងខ្លួនជាខុស : មានវិប្បដិសារៈ។

| | |
|---|---|
| វិស័យ្យ ☒ | វិស័យ ☑ |

វិស័យ

[វិ-សៃ]

ន. (ម.ព. វិសយ)។

| | |
|---|---|
| វីរៈជន ☒ | វីរជន ☑ |

វីរជន

[វី-រៈ-ជន់]

ន. ជនអង់អាច; ...។ (បើស្ត្រីជា វីរនារី)។

វីរៈនារី ☒ វីរនារី ☑

វីរនារី

[វី-រៈ-នា-រី]

ន. (ម.ព. វីរជន)។

វឹកវ ☒ វឹកវរ ☑

វឹកវរ

[វឹក-វ]

កិ., គុ.កិ. វរវឹក, ធ្វើឱ្យច្រឡំបល់, ឱ្យទាស់ការ; ច្របូកច្របល់ : នាំវឹកវរ, ធ្វើវឹកវរ។ (ម.ព. វរ១ ផង)។

រៀងវៃ ☒ វាងវៃ ☑

វាងវៃ

[វាង-វ៉ៃ]

គុ. ដែលមានប្រាជ្ញាវាងកេលកុងទាំងរហ័សផងទៀត គឺដែលឈ្លាសវៃ, ដែលដឹងផ្លូវដឹងឧបាយ : ប្រាជ្ញាវាងវៃ, គំនិតវាងវៃ, មនុស្សវាងវៃ។ (គួរកុំច្រឡំប្រើជា រៀងវៃ ព្រោះខុសទេ)។

វេ ☒ វេរ ☑

វេរ១

[វេ]

កិ. ប្រគល់ឬប្រគេនអ្វីៗ ឱ្យដោយបញ្ចេញវាចាថាតាមគន្ថ (ព.ពុ.) : វេរភត្ត, វេរកុដិ, វេរសាលាប្រគេនជំនុំសង្ឃ។

សេរ២

[សេ]

កិ. ងាកបែរទ្រេតឬបញ្ឆៀង, ងាកបែរ : សសរសេរ, ដើមឫស្សីត្រូវខ្យល់ខ្លាំងសេរមកលើផ្លូវ, ទូកសេរ។

សេរ៣

[សេ]

ន. ដំណើរយកវេនគ្នា, ដំណើរធ្វើការឱ្យគ្នាទៅវិញទៅមកម្ដងម្នាក់ : យកសេរ, ជំពាក់សេរគេ, សងសេរគេ។ (និយាយតាមទម្លាប់ដោយស្រុក, អ្នកស្រុកខ្លះនិយាយថា យកដៃ, ជំពាក់ដៃគេ, សងដៃគេ)។

វេទិការ ☒ វេទិកា ☑

វេទិកា

[វេ-ទិ-កា] (សំ.បា.)

ន. ភ្ជាក់ដៃ; បង្កាន់ដៃ; ក្តារហ៊ិង; ជើងម៉ាសម្រាប់អង្គុយ; ថ្នាក់ខ្ពស់ គឺថ្នាក់ដែលគេលើកតម្កល់ឱ្យខ្ពស់ជាងទីម្ខាង (សម្រាប់អង្គុយមើលមហោស្រពជាដើម ឱ្យស្រឡះភ្នែក) ឬកន្លែងខ្ពស់ដាច់ដោយឡែកពីទីអង្គុយធម្មតាសម្រាប់វាគ្មិនថ្លែងសេចក្តីក្នុងសន្និបាតផ្សេងៗ ដូចយ៉ាងវេទិកានៅរដ្ឋសភាជាដើម។

| | |
|---|---|
| វេយ្យករណ៍ ☒ | វេយ្យាករណ៍ ☑ |

វេយ្យាករណ៍

[វៃ-យា-ក] (បា. វេយ្យាករណ; សំ. វៃយាករណ ឬ វ្យាករណ)

ន. ការធ្វើឱ្យជាក់ច្បាស់, ឱ្យប្រាកដ; ការពន្យល់; ពាក្យអធិប្បាយ; ពាក្យដោះស្រាយ; ពាក្យរាយ; ទំនាយ; ឈ្មោះអង្គនៃពុទ្ធភាសិត (បាលីភាសា) មួយយ៉ាងជាពាក្យរាយ (មិនមែនគាថា, បាលីជាពាក្យរាយនេះហៅ វេយ្យាករណបាឋ វិញក៏បាន); គម្ពីរប្រាប់គោលរបស់ភាសា, មូលរបស់ភាសា : រៀនវេយ្យាករណ៍, ចេះវេយ្យាករណ៍, អ្នកវេយ្យាករណ៍។ (ម.ព. ព្យាករណ៍ ផង)។

# ពាក្យផ្ដើមដោយព្យញ្ជនៈ

# ស

សក្តិសិទ្ធ ☒ ស័ក្តិសិទ្ធិ ☑

ស័ក្តិសិទ្ធិ

[ស័ក-សិត]

គុ. ដែលមានអំណាចឬដែលអាចឱ្យសម្រេចប្រយោជន៍បាន, ដែលវិសេសវិសាល; ដែលពូកែឆុតឆាប់, ដែលខ្លាំងពូកែ : របស់ស័ក្តិសិទ្ធិ, មន្តស័ក្តិសិទ្ធិ, ថ្នាំស័ក្តិសិទ្ធិ។

សង្ខា ☒ សង្ខារ ☑

សង្ខារ

[សង់-ខា] (បា.; សំ. សំស្ការ)

ន. ការតាក់តែង, គ្រឿងប្រកបឬតាក់តែង; គ្រឿងប្រុង; ភ្នំ, ប្រមូលផ្តុំ; សព៌ាង្គកាយ; ជីវិត; គំនិត; អ្វីៗទាំងពួងក្នុងលោក; ...។

សង្ក្រាន ☒ សង្ក្រាន្ត ☑

សង្ក្រាន្ត

[សង់-ក្រាន] (សំ. សង្ក្រាន្តិ)

ន. ដំណើរឃ្លាតចាកទី; ការឈានចូលដល់; ដំណើរដែលព្រះអាទិត្យចរចូលដល់ទីចួបមួយជុំរាសិចក្រ គឺដំណើរដែលដើមនិងចុងនៃរាសិចក្រចួបគ្នា ពេញគ្រប់ជាមួយឆ្នាំ (ដំណើរដាច់ឆ្នាំចាស់ផ្លាស់ឆ្នាំថ្មី), ពិធីចូលឆ្នាំថ្មី (សង្ក្រាន្តមានបីថ្ងៃគឺថ្ងៃទី១ជាថ្ងៃចូលឆ្នាំ, ថ្ងៃទី២ជា ពារកណ្ដាលឬហៅថាវ័នបត (ថ្ងៃខ្វាក់), ថ្ងៃទី៣ជាពារឡើងស័ក គឺផ្លាស់ស័កថ្មីនៅថ្ងៃនេះឯង): ថ្ងៃសង្ក្រាន្ត, ពិធីសង្ក្រាន្ត។

សង្សា ☒ សង្សារ ☑

សង្សារ

[សង់-សា] (សំ.បា. សំសារ)

១). ន. ដំណើរអន្ទោលទៅមក, ដំណើរអន្ទោលកើតស្លាប់មិនឈប់មិនស្រាក : សង្សាររបស់ពួកពាល វែងឆ្ងាយឥតអ្វីប្រៀប។

២). ស្ត្រីជាគូកំសត់; ស្ត្រីជាសហាយស្មន់ : ស្រីនុ៎ះជាសង្សាររបស់គេ។

សង្ហារ ☒ សង្ហា ☑

សង្ហា

[សង់-ហា]

គុ. ដែលរុងរឿង, មានរូបល្អអង់អាច, ឆើតឆាយ, ស្រស់, ស្រស់បស់ :រូបឆោមសង្ហា, តែងខ្លួនយ៉ាងសង្ហា។ (ម.ព. សង៉ា ផង)។

សញ្ញាប័ត្រ ☒ សញ្ញាបត្រ ☑

សញ្ញាបត្រ

[ស័ញ-ញ៉ា-ប័ត]

ន. ក្រដាសកំណត់ហេតុសម្គាល់ចំណេះវិជ្ជា ចេញជាត្រាតាំងឱ្យជាព័ស្តុតាង ដល់អ្នករៀនដែលប្រឡងជាប់ មានអំណាចត្រូវទទួលយក (តាមលក្ខណប្បញ្ញត្តិ) : សញ្ញាបត្រឧត្តមសិក្សា។

សត្វវា ☒ សត្វវារ ☑

វារ

[វ៉ា]

១). កិ. លូនដោយប្រវា : កូនតូចទើបចេះវារ, ស្រមោចវាររសាវ។

២). បោះទងចេញឬបោះទងតោងចាប់ : ល្ពៅវារ, ត្រឡាចវារឡើងទ្រើង, ម្លូវវារតាមជន្លង់។

សន្និសិត ☒ សន្និសីទ ☑

សន្និសីទ

[សន់-និ-សិត] (បា.)

ន. ពាក្យនេះតាមបាលីគឺមានន័យដូចគ្នានឹងសន្និស័ទដែរ ប៉ុន្តែសព្វថ្ងៃនេះខ្មែរយើងប្រើសំដៅយកការប្រជុំគ្នាជជែកពិភាក្សាអំពីបញ្ហាផ្សេងៗ ដែលឋិតនៅក្នុងសភាពស្មុគស្មាញ មិនទាន់ដាច់ស្រេច ដើម្បីរិះរកផ្លូវចេញឬដោះស្រាយឱ្យជ្រះស្រឡះ; ការថ្លែងសេចក្ដីពន្យល់អំពីបញ្ហាផ្សេងៗដល់សាធារណជន : ធ្វើសន្និសីទ, ស្ដាប់សន្និសីទ។

សន្ទត់ ☒ សន្ទត ☑

សន្មត

[សន់-ណ្មាត់] (សំ.បា. សម្មត)

កិ. ប្ដេជ្ញា; សន្យា; អនុម័ត; យល់ព្រមជាមួយ, ព្រមតាម; តាំង, តាំងឱ្យជា ...; កំណត់, កំណត់ជា ...; ទុកដាក់ជា ..., ទុកដាក់ឱ្យជា ...; បញ្ញត្តឱ្យដឹង។

គុ. ដែលបានប្ដេជ្ញា; ដែលបានសន្យា; ដែលអនុម័ត : ពាក្យសន្មត។

| | |
|---|---|
| សព្វសាធុកា ☒ | សព្វសាធុការ ☑ |

សាធុការ

[សា-ធុ-កា]

១). ន. ការបញ្ចេញវាចាថា សាធុ! : ឱ្យសាធុការឬឱ្យសព្វសាធុការ។

២). ឈ្មោះដំណើរភ្លេងពិណពាទ្យមួយបទ : ភ្លេងសាធុការ។

| | |
|---|---|
| សភាពការ ☒ | សភាពការណ៍ ☑ |

សភាពការណ៍

[សៈ-ភាប-កា]

ន. ស្ថានភាព, ស្ថានការណ៍ : សភាពការណ៍សន្តិសុខក្នុងប្រទេស, សភាពការណ៍នយោបាយអន្តរជាតិថ្មីៗ, សម្រេចឱ្យបានរហ័សទាន់សភាពការណ៍

| | |
|---|---|
| សមរុំ ☒ | សមរម្យ ☑ |

សមរម្យ

[សំ-រុំ]

គុ.កិ., គុ. ដែលត្រូវបែបត្រូវយ៉ាង, មិនទាស់ភ្នែក : ស្លៀកពាក់សមរម្យ, រូបឆោមសមរម្យ!

សម៉រភូមិ ☒ សមរភូមិ ☑

សមរភូមិ

[សៈ-ម៉-រ៉ៈ-ភូម]

ន. ទីបោះទ័ព, ទីចម្បាំង។

សមាគមន៍ ☒ សមាគម ☑

សមាគម

[សៈ-ម៉ា-គុំ] (សំ.បា. < សំ "ព្រម", > ម + អាគម "ការមក")

១). ន. ការមកចួបជុំ, ការប្រជុំ; ការរួមគំនិតគ្នា, ដំណើររួបរួមកិច្ចការជាមួយគ្នា។

២). ការចូលហ៊ុនគ្នា, ក្រុមហ៊ុន។

សមិទ្ធិផល ☒ សមិទ្ធផល ☑

សមិទ្ធផល

[សៈ-មិត-ធៈ-ផល់]

ន. ផល, ប្រយោជន៍ ដែលបានសម្រេចហើយ។

សមុទ្យ ☒ សមុទ្ទ/ សមុទ្រ ☑

សមុទ្ទ

[សៈ-ម៉ុត] (បា. ឬ សំ.)

ន. អន្លង់ទឹកធំធេងជ្រាលជ្រៅល្ហល្ហេវលន្លឹមបាត់ត្រើយ ដែលមានអំបិលឬរសជាតិប្រៃស្មើភាគគ្នានឹងទឹក, សាគរ : ឆ្នេរសមុទ្ទ, មាត់សមុទ្រ។ (ច្រើនសរសេរជា សមុទ្រ)។

សម្ដី ☒ សំដី ☑

សំដី១

[សំ-ដី]

ន. (ម.ព. សម្តី)។

| | |
|---|---|
| សម្តៅ ☒ | សំដៅ ☑ |

សំដៅ

[សំ-ដៅ]

១). កិ., គុ.កិ. ចំពោះត្រង់, ឆ្ពោះត្រង់, តម្រង់ចំ : សំដៅសេចក្តីថា ...; ចោលសំដៅ; សំដៅចំ, សំដៅដាក់, សំដៅត្រង់, សំដៅយក, សំដៅលើ។ល។

សំដៅ

[សំ-ដៅ]

២). ប. ពាក្យសម្រាប់និយាយផ្សំនឹង សម្តី ថា សម្តីសំដៅ :អ្នកហ្នឹងចេះសម្តីសំដៅគ្រាន់បើ។

សម្ផស ☒ សម្ផស្ស ☑

សម្ផស្ស១

[ស័ម-ផ័ស-សៈ] ឬ [សំ-ផស់] (បា.; សំ. សំស្បត៌)

ន. ការប៉ះពាល់ត្រូវព្រម ឬការប៉ះពាល់ត្រូវពេញ គឺការប៉ះប្រសព្វចួបគ្នានៃអាយតនៈខាងក្នុងនិងអាយតនៈខាងក្រៅក៏កើតសេចក្ដីដឹងឡើង ដូចយ៉ាងភ្នែក (ជាអាយតនៈខាងក្នុង) ឃើញរូប (ដែលជាអាយតនៈខាងក្រៅ) ក៏កើតចក្ខុវិញ្ញាណគឺសេចក្ដីដឹងតាមភ្នែក ថារូបនេះរូបនោះជាដើម; សម្ផស្សមាន៦យ៉ាងគឺ ចក្ខុសម្ផស្ស, សោតសម្ផស្ស, ឃានសម្ផស្ស, ជិវ្ហាសម្ផស្ស, កាយសម្ផស្ស, មនោសម្ផស្ស (ព.ពុ.)។

សម្ផស្ស២

[ស័ម-ផ័ស-សៈ] ឬ [សំ-ផស់]

ន. ខ្មែរហៅពាក្យចួនក្នុងពាក្យដែលទទួលគ្នាឬដែលមានសូរសព្ទធ្ងន់ស្រាល តាមកំណត់មាត្រាកាព្យថា សម្ផស្ស ដែរ : កាព្យមានពាក្យខុសសម្ផស្សគ្នា, សម្ផស្សពាក្យចួន។

សម្ផស្ស៣

[ស័ម-ផ័ស-ស:] ឬ [សំ-ផស់]

ន. សម្រស់, សោភណភាព : កែសម្ផស្ស, សម្ផស្សនារីខ្មែរ។

| | |
|---|---|
| សម្ព័ន្ធ ☒ | សម្ពន្ធ ☑ |

សម្ពន្ធ១

[សំ-ព័ន] (សំ.បា.)

១). ន. ការចងភ្ជាប់គ្នា, ការតភ្ជាប់គ្នា; ដំណើរទាក់ទងរកគ្នា : ចង់ធ្វើសម្ពន្ធនឹងគ្នា។

២). ការចងពន្ធ គឺការចងមេត្រីជាដន្លងនឹងគ្នា ឬការដណ្ដឹងកូនស្រីឱ្យកូនប្រុស : មានសម្ពន្ធនឹងគ្នា គឺមានដំណើរទាក់ទងនឹងគ្នា។

សម្ពន្ធ២

[សំ-ព័ន]

ន. (ព.វ.) ចំណងបទ ឬចំណងប្រយោគ គឺការចងបទក្នុងសង្កាត់មួយៗឬក្នុងប្រយោគមួយៗ ឲ្យដឹងថាបទណាចូលទៅរកបទណា, បទណាជាប្រធាន, ណាជាកិរិយា, ណាជាអំពើ ជាដើម; ដូចជា ខ្ញុំ ទៅ ធ្វើ ការ ឯសាលាស្រុក, សម្ពន្ធថា : ខ្ញុំ ជាប្រធានរបស់ ទៅ, ទៅ ជាកិរិយារបស់ ខ្ញុំ, ធ្វើ ជាកិរិយាប្រាប់បំណងរបស់ ទៅ (ទៅដើម្បីធ្វើ); ការ ជាអំពើរបស់ ធ្វើ, ឯសាលាស្រុក ជាអាយតនិបាតប្រាប់ទី (ដែលត្រូវធ្វើការ)។ល។

កិ. ពិនិត្យសេចក្ដីក្នុងប្រយោគមួយៗ ឱ្យដឹងថាត្រឹមត្រូវឬខុសទេ : ត្រូវសម្ពន្ធមើលសិនទើបអាចដឹងបាន ។

សម្ភារ:  សម្ភារ 

សម្ភារ

[សំ-ភា] (សំ.បា.)

ន. ការសន្សំ, ការសាងសន្សំកុសល; ការសាងសន្សំបន្ទុំបារមី (របស់ពោធិសត្វ); តេជះ, អំណាច; សេចក្ដីទំនុកបម្រុង; ការស្រោចស្រង់, សេចក្ដីសង្គ្រោះ; ការរួបរួម; របស់ដែលត្រូវរួបរួម, ដែលត្រូវផ្សំជាមួយគ្នា; គ្រឿងផ្សំ; គ្រឿងផ្គុំ; អង្គ; ចំណែក; ពួក; ទ្រព្យ; របស់ដែលត្រូវតែមានខានពុំបាន, គ្រឿងប្រើប្រាស់។

| | |
|---|---|
| សម្ភោធ ☒ | សម្ពោធ ☑ |

សម្ពោធ

[សំ-ពោត] ឬ [សំ-ភោត] (បា.សំ. សម្ពោធ ឬ សម្ពោធន)

ន. ការរំឭក; ការថ្លែងសេចក្ដីដោយច្បាស់លាស់; ការពោលពាក្យប្រាស្រ័យរកគ្នា; ការហៅគ្នាចំពោះមុខ; ...។

កិ. ថ្លែងសេចក្ដីរៀបរាប់ឬរាយការណ៍ក្នុងទីប្រជុំឆ្លងឬឡើងមន្ទីរថ្មីជាដើម : សម្ពោធសាលារៀន។ (ម.ព. សម្ភោជនិងសម្ភោទ្យផង)។

សម្រាប់ ☒ សម្រេច ☑

សម្រេច

[សំ-រ៉ាច់]

១). កិ . ធ្វើ ឱ្យស្រេច, ឱ្យហើយស្រេច, ឱ្យដាច់ស្រេច : សម្រេចការ, សម្រេចសេចក្ដី។

២). ធ្វើឱ្យកើតការ, ឱ្យបានការ, ឱ្យសមប្រកប; បានសមតាមបំណង : សម្រេចប្រយោជន៍។

៣). បានលុះ, បានដល់ : សម្រេចគុណវិសេស, សម្រេចមគ្គផល។

សម្រាម ☒ សំរាម ☑

សំរាម

[សំ-រ៉ាម]

ន. គ្រឿងខ្ជាំ : បោសសំរាម, គំនរសំរាម។

សម្លសំឡក់ ☒ សម្លស្រឡក់ ☑

ស្រឡក់

[ស្រ-ឡក់]

ន. ឈ្មោះសម្លមួយប្រភេទ ប្រើបន្លែស្លឹកខ្ចី, ទងខ្ចី, ត្រួយឬផ្លែខ្ចីស្រស់ មានផ្សំស្លឹកគ្រៃនិងមើលខ្ជាយជាគ្រឿងគ្រាន់តែបង់បន្លែភ្លាម កូរពីរបីត្រឡប់ហើយដាក់មកភ្លាម : ស្រឡក់ត្រួយបាស, សម្លស្រឡក់។

សម្លេង ☒ សំឡេង ☑

សំឡេង

[សំ-ឡេង]

ន. សទ្ទជាតិដែលមកប៉ះសោតប្បសាទឱ្យឮ, សូរសព្ទឬសម្ដី ដែលលាន់ឮ : សំឡេងក្រអួន សំឡេងណែនធ្ងន់រំពង។

សរសៃប្រាសាទ ☒ សរសៃប្រសាទ ☑

សរសៃប្រសាទ

[ស-សៃ-ប្រ-សាទ]

ន. ធម្មជាតិទទួលសម្ផស្សដឹងអារម្មណ៍របស់មនុស្សសត្វ តាមរយៈសរីរាង្គឥន្ទ្រិយ សម្រាប់ដឹងព័ត៌មាននិងបញ្ជូនសកម្មភាព ទាំងឡាយទៅខួរក្បាល។

សហគម ☒ សហគមន៍ ☑

សហគមន៍

[សៈ-ហៈ-គុំ]

១). ន. ការទៅជាមួយ, ដំណើរជាមួយគ្នា។

២). ប្រជុំភូមិឬតំបន់អ្នកស្រុកប្រកបមុខរបរចូលគ្នា, ... : បង្កើតឱ្យមានសហគមន៍។

៣). ក្រុមមនុស្សដែលរស់នៅកន្លែងណាមួយក្នុងប្រទេសឬតំបន់ ហើយមានផលប្រយោជន៍រួមគ្នាលើផ្នែកសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ ជាដើម : សហគមន៍ព្រៃឈើ សហគមន៍នេសាទ សហគមន៍កសិកម្ម សហគមន៍អាស៊ាន សហគមន៍អឺរ៉ុប។

ស៊ីជំពៅ ☒ ស៊ីជម្រៅ ☑

ស៊ីជម្រៅ

[ស៊ី-ជុំ-រៅ]

១). គុ. ដែលមានបាតជ្រៅ (ចំពោះតែនាវា) : ទូកស៊ីជម្រៅ។ (ព.ផ្ទ. ស៊ីរាក់ឬស៊ីទឹករាក់)។

២). គុ.កិ. ដែលទាក់ទងនឹងផ្លូវភេទ : និយាយស៊ីជម្រៅ។

ស៊ីម៉ង់ ☒ ស៊ីម៉ងត៍ ☑

ស៊ីម៉ងត៍

[ស៊ី-ម៉ង់] (បារ. ciment)

ន. កំបោរពិសេស កាលណាសើមឬទទឹកឆាប់រឹង មានអាការៈជាថ្មសាច់រឹង។ (សព្វថ្ងៃច្រើនសរសេរក្លាយជា ស៊ីម៉ង់)។

សាកសប់ ☒ សាកសព ☑

សាកសព

[សាក-សប់]

ន.រូបរាងបុគ្គលស្លាប់,រូបរាងសព។

សាក្ខីភាព ☒ សក្ខីភាព ☑

សក្ខីភាព

[ស័ក-ខី-ភាប]

ន. ដំណើរជាសាក្សី។

| | |
|---|---|
| សាច់ញ្ញាត ☒ | សាច់ញ្ញាតិ ☑ |

សាច់ញ្ញាតិ

[សាច់-ញ្ញាត]

ន. អ្នកដែលជាប់ជាញ្ញាតិនឹងគ្នា, ក្រសែញ្ញាតិ។

| | |
|---|---|
| សាធារណៈរដ្ឋ ☒ | សាធារណរដ្ឋ ☑ |

សាធារណរដ្ឋ

[សា-ធា-រៈ-ណៈ-រ័ត]

ន. រដ្ឋដែលបណ្ដារាស្ត្រជ្រើសរើសប្រធានាធិបតីជាតំណាងរបស់ខ្លួន ហើយចាត់តាំងឱ្យកាន់កាប់ការផែនដីដោយមិនមានព្រះមហាក្សត្រ ដូចជាប្រទេសបារាំងជាដើម : សាធារណរដ្ឋបារាំង។

សាយ័ណ្ហ ☒ សាយណ្ហ ☑

សាយណ្ហៈ

[សា-យ័ន-ហៈ] (បា. សាយណ្ហ; សំ. សាយាហ្ន)

ន. វេលារសៀល, ពេលល្ងាច : វេលាសាយ័ណ្ហ; ហៅសាយណ្ហកាលឬសាយណ្ហសម័យ ក៏បាន។ (ព.ផ្ទ. បុព្វណ្ហៈ, បុព្វ័ណ្ហឬបុព្វណ្ហកាល, បុព្វណ្ហសម័យ)។

សារស័ព្ទ ☒ សារសព្ទ ☑

សារសព្ទ

[សា-រៈ-ស័ប]

ន. ពាក្យពិត; ពាក្យមានប្រយោជន៍, មានតម្លៃ។ (ម.ព. សាសព្ទ ផង។

សារាចរ ☒ សារាចរណ៍ ☑

សារាចរ

[សា-រ៉ា-ច]

ន. លិខិតមានកម្មវត្ថុដូចគ្នាតែមួយដែលប្រាស្រ័យចំពោះបុគ្គលច្រើនគ្នា ដូចយ៉ាងលិខិតរបស់នាយករដ្ឋមន្ត្រី ដែលប្រាស្រ័យកិច្ចការជាមួយនឹងក្រសួងរដ្ឋមន្ត្រីនានាជាដើម : ប្រតិបត្តិតាមសារាចរ, ធ្វើសារាចរបង្គាប់ទៅគ្រប់ក្រុមក្រោមឱវាទ។

សារៈប្រយោជន៍ ☒ សារប្រយោជន៍ ☑

សារប្រយោជន៍

[សា-រ៉ះ-ប្រ-យ៉ោច]

ន. ប្រយោជន៍យ៉ាងសំខាន់ ប្រយោជន៍ដ៏មានខ្លឹមសារ : សារប្រយោជន៍នៃអំណាន។

| សាវ៉ា ☒ | សាវា ☑ |
|---|---|

សាវា

[សា-វ៉ា] (សំ. គាវ "ដែលជាប់ទាក់ទងដោយសាកសព; ដែលមានក្លិនស្អុយអាក្រក់; ថោកទាប, ឥតតម្លៃ")

គុ. ដែលឆាប់វើរុះ, ដែលមិននឹង, មិនប្រាកដ, ដែលរាយមាយ ចាប់នេះចាប់នោះមិនឆ្ពោះត្រង់ណា : គំនិតសាវា, ចិត្តសាវា, មនុស្សសាវា។

| សិក្សារ ☒ | សិក្សា ☑ |
|---|---|

សិក្សា

[សិក-សា] (សំ. ឝិក្សា; បា. សិក្ខា)

ន. សិក្ខា គឺការរៀន, ការរៀនទន្ទេញ, ការសូត្ររៀន; ការហ្វឹក, ការហ្វឹកហាត់; ការប្រុងប្រយ័ត្នរក្សាមារយាទឱ្យល្អ; ឧប្រតិបត្តិ; វិជ្ជា; ការស្ទាត់ជំនាញ, ...។

កិ. រៀន, រៀនទន្ទេញ, សូត្ររៀន : មាតាបិតាទំនុកបម្រុងបុត្រឱ្យសិក្សា។

| | |
|---|---|
| សិទ្ធ ☒ | សិទ្ធិ ☑ |

សិទ្ធិ

[ស៊ិត] (សំ.បា.)

១). ន. សេចក្ដីសម្រេច; សេចក្ដីសម្រេចផល ឬផលសម្រេច, ការសម្រេចប្រយោជន៍; ការដាច់ស្រេច; ការសមប្រកប, ការសមតាមបំណង; សេចក្ដីសុខ; សេចក្ដីចម្រើន; សេចក្ដីស័ក្តិសិទ្ធិ; សេចក្ដីខ្លាំងពូកែ; សេចក្ដីសម្បូណ៌; សេចក្ដីសម្រេចតាមអំណាចច្បាប់; អំណាច, សេចក្ដីអង់អាច; មុខការដែលត្រូវសម្រេចលើខ្លួន។ (ម.ព. សិទ្ធ ផង)។

២). លទ្ធភាពទទួលស្គាល់តាមផ្លូវច្បាប់ដែលអាចទទួលបានតាមការការពារឬទាមទារនូវផលប្រយោជន៍ណាមួយ។

សិប្បនិមិត្ត ☒ សិប្បនិម្មិត ☑

សិប្បនិម្មិត

[សិប-ប៉ៈ-និម-មិត]

គុ. ដែលមិនមែនកើតឡើងតាមធម្មជាតិ ដែលកែច្នៃឬចម្លងយកតាមលំនាំធម្មជាតិ : ត្បូងសិប្បនិម្មិត ធ្មេញសិប្បនិម្មិត។

ន. ការបង្កើតឡើងមិនតាមធម្មជាតិ, របស់ឬអ្វីៗដែលមិនមែនជាធម្មជាតិពិត។

សិល ☒ សីល ☑

សីល

[សិល] (បា.; សំ. ឝីល)

ន. វិរតិចេតនាដែលវៀរចាកអំពើអាក្រក់, ការកាន់ឬប្រព្រឹត្តល្អដោយកាយវាចា, ការមិនប្រព្រឹត្តកន្លងសិក្ខាបទឬវិនយប្បញ្ញត្តិ (ព.ពុ.)។ ការកាន់ចរិយាល្អ; ការសង្រួម; អង្គនៃចរិយា; ចរិត, ចរិយា; មារយាទល្អ; សេចក្ដីល្អ; គតិ; លក្ខណៈ; និស្ស័យ; អធ្យាស្រ័យ; សភាព; ប្រក្រតី; ទម្លាប់; សណ្ដាប់ធ្នាប់; ធម្មជាតិ; ធម្មតា។

សិលាចារិក ☒ សិលាចារឹក ☑

សិលាចារឹក

[សិ-ឡា-ចា-រឹក]

ន. អក្សរថ្ម។

| | |
|---|---|
| សឹង្ហបុរី ☒ | សិង្ហបុរី ☑ |

សិង្ហ

[សឹង] (សំ. សឹហ; បា. សីហ)

ន. សីហៈឬតោ។ អ្នកខ្លះយល់ថា សិង្ហ ដោយខ្លួន តោដោយខ្លួន, ជួនកាលហៅរួមថា សិង្ហតោ យល់ថា សិង្ហនិងតោ; តាមសេចក្ដីពិត សិង្ហឬសីហៈ ប្រែថា តោ មិនមែនទីទៃពីគ្នាទេ, ប៉ុន្តែជាងរាល់ប្រទេសច្រើនធ្វើរូបក្លាយផ្សេងៗពីគ្នា ក៏នាំឱ្យមានអ្នកយល់ថា សិង្ហឬសីហៈ ទីទៃពី តោ។ (ម.ព. សីហៈឬសីហ៍ ផង)។

| | |
|---|---|
| សុច្ចរិត ☒ | សុចរិត ☑ |

សុចរិត

[សុ-ចៈរិត] (សំ.បា.)

ន. ការប្រព្រឹត្តល្អ : កាន់សុចរិត, មានសុចរិត។ (ហៅ សុចរិតធម៌ ក៏បាន, មាន៣យ៉ាង គឺ ការប្រព្រឹត្តល្អដោយកាយ ហៅ កាយសុចរិត; ការប្រព្រឹត្តល្អដោយវាចា ហៅ វចីសុចរិត; ការប្រព្រឹត្តល្អដោយចិត្តសុទ្ធ ហៅ មនោសុចរិត ព.ផ្ទ. ទុច្ចរិត)។

សុឆន្ទៈ: ☒ សុច្ឆន្ទៈ: ☑

សុច្ឆន្ទៈ

[សុច-ឆ័ន-ទៈ] (សំ.បា. សុ "ល្អ, ប្រពៃ; ត្រឹមត្រូវ" + ឆន្ទ "បំណង" > សុច្ឆន្ទ)

ន. ឆន្ទៈល្អ, បំណងប្រពៃ; បំណងត្រឹមត្រង់, បំណងត្រឹមត្រូវ គឺបំណងដែលត្រឹមត្រង់តាមគតិធម៌និងគតិច្បាប់ អាចញ៉ាំងសេចក្ដីសុខ ចម្រើនឱ្យកើតមាន : សុច្ឆន្ទៈរបស់វីរបុរស។ (ព.ផ្ទ. ទុច្ឆន្ទៈ "បំណងអាក្រក់")។

សុជាតិ ☒ សុជាត ☑

សុជាត

[សុ-ជាត]

គុ. ដែលកើតល្អ; ដែលដុះល្អ; ដែលលូតលាស់ល្អ។

សុដ្ឋិនិយម ☒ សុទិដ្ឋិនិយម ☑

សុទិដ្ឋិនិយម

[សុ-ទិត-ឋិ-និ-យំ] (បា.)

ន. ការនិយមចំពោះសុទិដ្ឋិ, ការនិយមដោយទិដ្ឋិត្រូវ; ការចូលចិត្ត ឬការយល់ឃើញថារបស់អ្វីក្នុងលោកសុទ្ធតែល្អ, សុទ្ធតែប្រសើរសុខស្រួល, ... : បុគ្គលប្រកបដោយសុទិដ្ឋិនិយម។ (ព.ផ្ទ. ទុទ្ទិដ្ឋិនិយម)។

សុបិន្ត ☒ សុបិន ☑

សុបិន

[សុ-បិន] (បា.; សំ. ស្វប្ន)

១). ន. ការដេកលក់។ ប្រើសំដៅសេចក្ដីថា "ការយល់សប្តិឃើញ" : យប់មិញ ខ្ញុំមានសុបិនមិនល្អ។

២). (ទស្សនៈ.) ស៊េរី (ដំណើរបន្តគ្នា) នៃរូបភាព គំនិត វេទនារម្មណ៍ និងឥន្ទ្រិយារម្មណ៍ ដែលជាធម្មតាកើតឡើងដោយអចេតនានៅក្នុងចិត្តក្នុងរយៈពេលនៃដំណាក់កាលណាមួយនៃដំណេក

: ការសិក្សាបែបវិទ្យាសាស្ត្រអំពីសុបិនត្រូវបានគេហៅថាសុបិនវិទ្យា។

សុភវិនិច្ឆ័យ ☒ សុភនិច្ឆ័យ ☑

សុភនិច្ឆ័យ

[សុ-ភៈ-និច-ឆ៉ៃ]

ន. ការចាប់អារម្មណ៍ល្អ, ការរិះគិតល្អ, គំនិតត្រឹមត្រូវ : មានសុភនិច្ឆ័យ។

សុវត្ថិភាព ☒ សុវត្ថិភាព ☑

សុវត្ថិភាព

[សុ-វ៉ុត-ថិ-ភាប]

ន. ការមានសួស្តី, ការប្រកបដោយសេចក្តីសុខ : បានត្រឡប់មកដល់ស្រុកវិញ ដោយសុវត្ថិភាព។

| | |
|---|---|
| សួរស្តី ☒ | សួស្តី ☑ |

សួស្តី

[សួស-ស្តី] ឬ[សួ-ស្តី] (សំ. ក្ល.; ស្វស្តិ, ខ្មែរប្រើផ្លាស់ វ ជាស្រៈ , > ; បា. សុវត្ថិ, សោត្ថិ)

ន. សេចក្តីសុខស្រួល; ការប្រព្រឹត្តទៅស្រួល; សេចក្តីចម្រើនដោយសុខ; សេចក្តីសុខចម្រើន, គ្រោះល្អ; ដំណើរមានជោគ : មានសួស្តី, ទៅមកដោយសួស្តី។

| | |
|---|---|
| សេបគប់ ☒ | សេពគប់ ☑ |

សេពគប់

[សែប-គប់]

កិ. គប់រកយកជាគ្នា។

សេរីសួស្តី ☒ សិរីសួស្តី ☑

សិរី

[សិ-រ៉ី] (បា.; សំ. ឝ្រី)

ន. លម្អដែលគួរឱ្យស្រឡាញ់; សួស្តី, ស្រីសួស្តី, មង្គល; ជោគ; សេចក្តីសុខ, សេចក្តីចម្រើន; បុណ្យ, បុណ្យភ័ព្វ, ភ័ព្វព្រេង, សំណាងល្អ; ព្រេងសំណាងល្អ; ទ្រព្យ; ការមានបាន, លាភ; ឥស្សរភាព, តេជះ អំណាច; រាជសម្បត្តិ; ទិព្វសម្បត្តិ; ភគវតី; លក្ខ្មី។ល។ : មានសិរី, ឡើងសិរី; សិរីជាលំនៅនៃភោគៈ។ (ម.ព. ស្រី២ ផង)។

សោភ័ណ្ឌភាព ☒ សោភ័ណភាព ☑

សោភណភាព

[សោ-ភៈ-ណៈ-ភាប] ឬ [សោ-ភ័ន-ណៈ-ភាប] (បា.; សំ < សោភណ + ភាវ)

ន. ភាពស្រស់ស្អាត លម្អ សម្រស់ : សោភណភាពនៃចម្លាក់ក្នុងប្រាសាទបន្ទាយស្រី។

សោរឡាន ☒ សោឡាន ☑

សោ១ [សោ]

ន. ប្រដាប់ធ្វើដោយដែកឬស្ពាន់ មានមេមានកូនសម្រាប់ចាក់បិទត្រង់កន្លែងសម្រាប់បើកបិទ (មានទ្វារជាដើម) មិនឱ្យបើកបាន : មេសោ, កូនសោ, ចាក់សោ។

ស្តុកស្តម ☒ ស្តុកស្តម្ភ ☑

ស្តុកស្តម្ភ

[ស្តុក-ស្តំ]

គុ. រឹងជំហរ; មាំមួន (ដោយទ្រព្យសម្បត្តិ) : មនុស្សស្តុកស្តម្ភ, មានទ្រព្យស្តុកស្តម្ភ។

ស្ថានីយ៍ ☒ ស្ថានីយ ☑

ស្ថានីយ

[ស្ថា-នី] (សំ.; បា. ឋានីយ ជា គុ. "ដែលគួរជាទីតាំង; ដែលគួរឈប់, គួរសំចត; ...")

ន. ទីសម្រាប់សម្នាក់, សម្រាប់ឈប់; ទីចត, ទីសំចត; ដំណាក់សម្រាប់ឈប់សម្រាក, សម្រាប់ដាក់រទេះជាដើម; ស្រុក, ភូមិ, លំនៅ។ (ម.ព. ឋានីយ)។

ស្ទាក់ស្ទើ ☒ ស្ទាក់ស្ទើរ ☑

ស្ទាក់ស្ទើរ

[ស្ទាក់-ស្ទើ]

កិ. ទើសទាក់ស្ទើរដំណើរ : នាំឱ្យស្ទាក់ស្ទើរដំណើរ។

គុ. ដែលស្ទើរនៅស្ទើរទៅ, ដែលរារែក, ដែលអល់អែក : ចិត្តស្ទាក់ស្ទើរ, ដំណើរស្ទាក់ស្ទើរ។

ស្ទុះស្ទារ ☒ ស្ទុះស្ទា ☑

ស្ទុះស្ទា

[ស្ទុះ-ស្ទា]

១). កិ. ស្ទុះឆ្លាចុះឆ្លាឡើង, ប្រញាប់ រួសរាន់ រូតរះ : ស្ទុះស្ទាដូចមេមាន់រកពង, ស្ទុះស្ទារត់ចេញពីគំនរបាក់បែក។

២). (ព.ប្រ.) ខំប្រឹងធ្វើការពេញកម្លាំង : ស្ទុះស្ទាបំពេញកិច្ចការ, ស្ទុះស្ទាបញ្ចប់គម្រោងសាងសង់។

ស្ថិតស្ថាល ☒ ស្ថិទ្ធស្ថាល ☑

ស្ថិទ្ធស្ថាល

[ស្ថិត-ស្ថាល]

គុ. (ម.ព. ស្ថាល)។

ស្ទើរ ☒ ស្ទើ ☑

ស្ទើ១

[ស្ទើ]

១). កិ. សួរឱ្យដឹងសិន, ពិគ្រោះឬប្រឹក្សាមុនសិន (ចំពោះតែជាមួយនឹងឥស្សរជន គឺក្រាបបង្គំទូល, ក្រាបទូល, ទូល, ពិត, ជម្រាប, ឱ្យដឹងការមុនសិន) : ទូលស្ទើ, ស្ទើការ។

២). កំហែងយក, រឹបអូស, សុំ (ប្រើសម័យខ្មែរក្រហម) : អង្គការស្ទើនាឡិកា។

ស្ទើ២

[ស្ទើ]

ន. ស្រទាប់, សង្កាត់ ដែលសើរើឡើងបានដោយងាយ : ស្ទើក្រដាស, រើយកតាមស្ទើ។ (ធ្លាប់សរសេរមកថា ស្ទើរ ប៉ុន្តែដោយពិនិត្យឃើញថាពាក្យនេះចេញមកពី សើ ទើបសរសេរថា ស្ទើ វិញ)។

ស្ទើ៣

[ស្មើ]

ន. ចំនួនពីរគួបគ្នា (ចំពោះតែសន្លឹក ដូចយ៉ាងម្លូជាដើម) : ម្លូប្រាំស្មើ ម្លូដប់សន្លឹក។

ស្ពានប្រតិស្ឋ ☒ ស្ពានប្រជីស ☑

ប្រជីស

[ប្រ-ជីស]

ន. រនាបដែលត្បាញខ្ទាស់នឹងចម្រឹងញឹក : ខ្ទាស់ប្រជីស, ត្បាញប្រជីស។

ស្មើរ ☒ ស្មើ ☑

ស្មើ

[ស្មើ]

គុ., គុ.កិ. ដែលប៉ុនគ្នា, ត្រូវគ្នា, មិនលើសមិនខ្វះពីគ្នា; រាបដូចគ្នា (យ៉ាងផ្ទៃស្គរ); ដែលជាកណ្ដាលមិនលម្អៀងទៅរកខាងណា : ទម្ងន់ស្មើគ្នា, កម្លាំងស្មើគ្នា; តាំងចិត្តស្មើ, រាប់អានស្មើ។

ស្មោគគ្រោក ☒ ស្មោកគ្រោក ☑

ស្មោកគ្រោក

[ស្មោក-គ្រោក]

គុ. គគ្រក់, កខ្វក់, ប្រឡាក់ប្រឡូសគួរខ្ពើម (សោកគ្រោក) : ទីស្មោកគ្រោក។ (និយាយថា ស្មោ៊កគ្រោក ក៏មាន, តាមទម្លាប់ប្រើ)។

គុ.កិ. ដែលខ្ជិលសម្អាតឬមិនចេះសម្អាត បណ្ដោយឱ្យកខ្វក់ : មនុស្សស្មោកគ្រោក។

ស្នោះស ☒ ស្នោះសរ ☑

ស្នោះសរ

[ស្នោះ-ស] (បា. សមោសរ "ប្រជុំ ឬ ជួបជុំគ្នាដោយរីករាយ")

ន. សេចក្ដីរីករាយរាក់ទាក់, សេចក្ដីរួសរាយ, សាទរ : ទទួលភ្ញៀវដោយស្នោះសរ។

ស្នោះស្នាក់ ☒ ស្នោះស្ម័គ្រ ☑

ស្នោះស្ម័គ្រ

[ស្នោះ-ស្នាក់]

គុ., កិ. (ម.ព. ស្ម័គ្រស្នោះ)។

ស្រម៉ៃ ☒ ស្រមៃ ☑

ស្រមៃ

[ស្រ-ម៉ៃ]

កិ. ភ្នកដល់ឬផ្អូកដល់ហាក់ដូចជាឮឬឃើញឬថានឹងបានតាមបំណង : ខ្ញុំស្រមៃហាក់ដូចជាកូនខ្ញុំស្រែកហៅ; ចិញ្ចៀនបាត់រកមិនឃើញ ខ្ញុំចេះតែស្រមៃថាដូចជានៅត្រង់ណោះត្រង់ណោះ។

ស្រម៉ោច ☒ ស្រមោច ☑

ស្រមោច

[ស្រ-ម៉ោច]

ន. សុខុមសត្វច្រើនពួក មានប្រភេទផ្សេងៗគ្នា ជាសត្វមានសាមគ្គីស្រុះគ្នា ច្រើនរកស៊ីជាពួកៗមូលគ្នា : ស្រុះគ្នាដូចស្រមោច។

| | |
|---|---|
| ស្រវ៉ា ☒ | ស្រវា ☑ |

ស្រវា

[ស្រ-វ៉ា]

កិ. លូកដៃទៅចាប់យកអ្វីៗដោយប្រញាប់, ក្រសាវយកដោយម្នីម្នា : ស្រវាយកនំតែម្នាក់ឯង។

| | |
|---|---|
| ស្រាច់ ☒ | ស្រេច ☑ |

ស្រេច

[ស្រាច់]

កិ., គុ.កិ. ចប់ហើយ, អស់កិច្ចហើយ, ដល់ទីបំផុតហើយ, ដែលបរិបូរ, គ្រប់គ្រាន់, សព្វគ្រប់ : ស្រេចការ, ចប់ស្រេច។

ស្រោះស្រាយ ☒ ស្រស់ស្រាយ ☑

ស្រស់ស្រាយ

[ស្រស់-ស្រាយ]

គុ.កិ., គុ. រាក់ទាក់រួសរាយ, រអាករពាយ; ស្រស់រីករាយ : និយាយស្រស់ស្រាយរកគ្នា; សម្តីស្រស់ស្រាយ; មុខស្រស់ស្រាយ។

ស្លន់ស្លោរ ☒ ស្លន់ស្លោ ☑

ស្លន់ស្លោ

[ស្លន់-ស្លោ]

កិ. ស្លន់ធ្វើភ្នែកស្លោឬធ្វើភ្នែកស្លោព្រោះស្លន់ឬស្លន់ឆោឡោ។

ស្លេស ☒ ស្លេស្ម ☑

ស្លេស្ម

[ស្លែស] (សំ. ឝ្លេឞ្មន៑; បា. សេម្ហ)

ន. ទឹករំអិលរាវឬខាប់ដែលចេញមកតាមបំពង់ក (ច្រើនសរសេរ ស្លេស្ម៍ ជាង) : ធ្លាក់ស្លេស្ម៍, ស្លេស្ម៍រាវ, ស្លេស្ម៍ខាប់។ (ម.ព. សេម្ហៈ ផង)។

សំណាប់ ☒ សំណាព្វ ☑

សំណាព្វ

[សំ-ណាប់]

គុ. ដែលពេញសព្វគ្រប់ក្នុងចិត្ត, ដែលគាប់ចិត្ត, ដែលគាប់គួរ, ដែលឥតមានទាស់អធ្យាស្រ័យ : ព្រះមហេសីសំណព្វ; សិស្សសំណព្វ, កូនសំណព្វ (ធ្លាប់ប្រើមកជា សំណាប់, ប៉ុន្តែកែជា សំណព្វ វិញ ដើម្បីឱ្យស្របនឹងពាក្យដើមដែល ជាកិរិយាសព្ទថា សព្វ។ (ម.ព. សព្វ៣ ផង)។

| | |
|---|---|
| សំណើរ ☒ | សំណើ ☑ |

សំណើ១

[សំ-ណើ]

ន. ពេល, វេលាដ៏ខ្លី មានរយៈប្រហែលដូចគេសើឱ្យឃើញស្មើឃើញស្រទាប់ : ត្រូវប្រើរបស់ហ្នឹងមួយសំណើទៅសិន ទម្រាំបានរបស់ថ្មីមកទៀត។

សំណើ២

[សំ-ណើ]

ន. ការស្នើ, ការសុំ, សំណូមពរ : សំណើច្បាប់, សំណើសុំ។

| | |
|---|---|
| សំនួរ ☒ | សំណួរ ☑ |

សំណួរ

[សំ-ណួ]

ន. ពាក្យសួរ; សេចក្ដីសួរសុខទុក្ខដោយសរសេរសំបុត្រ ឬ ផ្ដាំនឹងអ្នកដទៃ (ច្រើនសរសេរ សំនួរ ជាង) : កូនខ្ញុំតែងមានសំណួរ មករឿយៗ ប្រាប់ថាសុខសប្បាយទេ។

គុ. ដែលសួរ ដែលជាការសួរ : សំបុត្រសំណួរ។ ធ្លាប់សរសេរជា សំនួរ ខ្លះមកហើយ ប៉ុន្តែត្រូវសរសេរជា សំណួរវិញឱ្យដូចពាក្យឯទៀត។

| | |
|---|---|
| សំនេរ ☒ | សំណេរ ☑ |

សំណេរ

[សំ-ណេ]

ន. ការសរសេរ, អ្វីដែលគេបានសរសេរកត់ទុក : សំណេរតែងសេចក្ដី។

| | |
|---|---|
| សំបូរ ☒ | សម្បូរ ☑ |

សម្បូរ

[សំ-បូ] (សំ.បា. < សំ > សមិ "គ្រប់ព្រម; ណាស់" + បូរ "ពេញ")

កិ., គុ. ពេញពាស; បរិបូរ៍ក្រៃពេក, គរគោក : ទឹកភ្លៀងសម្បូរ, ស្រុកសម្បូរ។ (វេវ. សម្បូណ៌)។

| | |
|---|---|
| សំភារៈ ☒ | សម្ភារ ☑ |

សម្ភារៈ

[សំ-ភា-រៈ]

ន. គ្រឿងទ្រទ្រង់។

| | |
|---|---|
| សំយ៉ាប ☒ | សំយាប ☑ |

សំយាប

[សំ-យ៉ាប]

១). ន. ចុងញូកដំបូលគ្រឹហា, ចុងញូកដំបូលទាំងពួង : សំយាបផ្ទះ, សំយាបរោង។ (ជួនគេហៅត្រឹម យ៉ាក ឬ យ៉ាប ក៏មាន)។

២). (ព.ប្រ.) ចុងបំផុតកំប៉េះអ្វីមួយ : សំយាបគូទ។

| | |
|---|---|
| សំយ៉ុង ☒ | សំយុង ☑ |

សំយុង

[សំ-យ៉ុង]

កិ. ទម្លាក់ឬធ្លាក់ស្ដោកចុះក្រោម : អង្គុយសំយុងជើង, សំយុងកន្ទុយខ្សែចុះក្រោម, ធ្លាក់សំយុងក្បាលមកមុន។

| | |
|---|---|
| សំរស់ ☒ | សម្រស់ ☑ |

សម្រស់១

[សំ-រ៉ស់]

កិ. ធ្វើឱ្យស្រស់ទឹក : ជាត់បាយសម្រស់ទឹក។

សម្រស់២

[សំ-រ៉ស់]

ន. ការស្រស់, ការល្អល្អះ, ភាពប្រិមប្រិយ : មានសម្រស់ល្អណាស់, បញ្ចេញសម្រស់ដ៏ឆើតឆាយ។

សំរាក ☒ សម្រាក ☑

សម្រាក

[សំ-រ៉ាក]

កិ. ធ្វើឱ្យស្រាក, ឈប់ឱ្យស្រាកនឿយ : សម្រាកកម្លាំង, សម្រាកកាយ។

សំរាប់ ☒ សម្រាប់ ☑

សម្រាប់

[សំ-រ៉ាប់]

១). គុ. ដែលមានស្រាប់, ដែលបម្រុង, ដែលត្រូវប្រកបតាមការ : ដែកជារបស់សម្រាប់ប្រើការបានច្រើនយ៉ាង; ក្រដាសសម្រាប់សរសេរ។

២). ន. វត្ថុដែលបម្រុងឱ្យមានស្រាប់, ប្រដាប់ : ខោអាវមួយសម្រាប់, ស្បែកជើងពីរសម្រាប់។

៣). ចង្ហាន់ដែលទាយកទាយិការៀបផ្គត់ផ្គង់បម្រុងឬប្រចាំទុកឱ្យមានស្រេចស្រាប់ ដើម្បីប្រគេនបព្វជិតរាល់ថ្ងៃ : រៀបសម្រាប់ប្រគេនលោក, រៀបចង្ហាន់ពីរសម្រាប់។ (ភោជនាហារដែល

គ្រហស្ថរៀបផ្គត់ផ្គង់គ្រហស្ថជានិច្ចហៅ សម្រាប់ ដែរក៏មានតែ ម. ប្រ.)។

សំរេច ☒ សម្រេច ☑

សម្រេច

[សំ-រ៉ាច់]

១). កិ. ធ្វើឱ្យស្រេច, ឱ្យហើយស្រេច, ឱ្យដាច់ស្រេច : សម្រេចការ, សម្រេចសេចក្ដី។

២). ធ្វើឱ្យកើតការ, ឱ្យបានការ, ឱ្យសមប្រកប; បានសមតាមបំណង : សម្រេចប្រយោជន៍។

៣). បានលុះ, បានដល់ : សម្រេចគុណវិសេស, សម្រេចមគ្គផល។

សំលាប់ ☒ សម្លាប់ ☑

សម្លាប់

[សំ-ឡាប់]

១). កិ. ធ្វើឱ្យស្លាប់, បំបាត់ជីវិត, ផ្ដាច់ជីវិត : សម្លាប់សត្វ។

២). (ព.ប្រ.) កម្ចាត់បង់ឱ្យលែងកើតមានតទៅទៀត : សម្លាប់កិលេស។

៣). ធ្វើឱ្យស្លាប់សាច់ : សម្លាប់ស្បែក។

៤). បំផ្លាញ; បង្ខូចឬបង្ខាតប្រយោជន៍ : សម្លាប់ប្រយោជន៍។

៥). លាក់ពុត; សម្ដែងកលមាយាធ្វើហាក់ដូចជាស្លាប់ : សម្លាប់ពុត។ (ម.ព. ពុត ផង)។

៦). កួចចំណងមួយបែបផ្សុយពីបត់ចន្ទាស គឺទាញកន្ទុយខ្សែចំណងម្ខាងឱ្យផុតស្រឡះពីរង្វង់ចំណង : ចងសម្លាប់មុខ។ (ព.ផ្ទ. បត់ចន្ទាស)

សំលី ☒ សំឡី ☑

សំឡី

[សំ-ឡី]

ន. (ម.ព. សម្លី)។

សំលឹង ☒ សម្លឹង ☑

សម្លឹង

[សំ-ឡឹង]

កិ. មើលស្លឹង, មើលដោយធ្វើភ្នែកស្លឹងឆ្ពោះត្រង់មិនងាក: ងើយសម្លឹងមើលផ្កាយ។

សំឡក់ ☒ សម្លក់ ☑

សម្លក់

[សំ-ឡក់]

កិ. បើកភ្នែកធំសម្លឹងត្រង់ទៅរកដោយធ្វើមុខមាំឬធ្វើមុខស្មើ (ហាក់ដូចជាស្លក់) : សម្លក់ឱ្យសញ្ញាថា ឱ្យឈប់កុំនិយាយ។

សំអាត ☒ សម្អាត ☑

សម្អាត

[សំ-អាត]

កិ. ធ្វើឱ្យស្អាត, ឱ្យអស់មន្ទិល : សម្អាតផ្ទះ, សម្អាតខ្លួន, សម្អាតចិត្ត, បោសសម្អាត, ជូតសម្អាត។ (សរសេរជា សំអាត ក៏បាន)។

# ពាក្យផ្ដើមដោយព្យញ្ជនៈ

# ហ

ហឬទ័យ ☒ ហឫទ័យ ☑

ហឫទ័យ

[ហៈ-រឹ-ទៃ]

ន. (ម.ព. ហទ័យ)។

ហ៊ោរ ☒ ហ៊ោ ☑

ហ៊ោ

[ហ៊ោ]

កិ. ស្រែកបន្លឺសូរសព្ទឮខ្ពស់គ្រលួចស្រួចឡើងឬស្រែកបន្លឺសូរសព្ទគឹកកងខ្ពស់គ្រលួចស្រួចឡើងព្រមគ្នាយកជ័យឬ

ដោយសេចក្ដីរីករាយក្នុងការលេងកម្សាន្តសប្បាយជាដើម : ហ៊ោយកជ័យ, ហ៊ោសប្បាយ, ហ៊ោក្រេវៗ។

| | |
|---|---|
| ហារមាត់ ☒ | ហាមាត់ ☑ |

ហា១

[ហា]

កិ. របើកហើយច្រហាឡើង; ធ្វើឱ្យរបើកហើបឡើង; បើកមាត់ច្រហាឡើង : ហាមាត់។

គុ. ដែលរបើកហើបឡើង, ដែលប្រេះហើបច្រហ : សៀសហាលថ្ងៃហា, ផ្លែសំរោងទុំប្រេះហា។

| | |
|---|---|
| ហឹង្សា ☒ | ហិង្សា ☑ |

ហិង្សា

[ហិង-សា] (សំ.បា. ហឹសា)

ន. ការបៀតបៀន, ការពាធា, ការធ្វើអាក្រក់រកគ្នា, ការធ្វើទុក្ខគ្នា : មនុស្សត្រូវកុំឱ្យមានហិង្សារកគ្នា។

ហឹល ☒ ហឹរ ☑

ហឹរ

[ហឹល]

គុ. ដែលមានរសផ្សាក្ដៅឆួល (ដូចយ៉ាងរសម្ទេសខ្លាំង, ម្រេច) : រសហឹរ, សម្លហឹរ (និយាយក្លាយជា ហើរ ក៏មាន ប៉ុន្តែមិនដែលសរសេរទេ ដូចជាខ្ទុរ, ឆ្នាំកុរ, សម្បុរ ដែលនិយាយក្លាយជាខ្ទោរ, ឆ្នាំកោរ, សម្បោរនោះដែរ)។

ហូរហៀ ☒ ហូរហៀរ ☑

ហូរហៀរ

[ហូ-ហៀ]

គុ.កិ., គុ. (ម.ព. ហៀរ)។

ហូរហែរ ☒ ហូរហែ ☑

ហូរហែ

[ហូ-ហែ]

គុ.កិ. ដែលហែៗគ្នាមិនដាច់, ដែលចេះតែមានបន្តគ្នាមិនដាច់ : មានគេទៅមកហូរហែ។

ហែរ ☒ ហែ ☑

ហែ

[ហែ]

១). កិ. ដើរជាក្បួនចោមរោមមនុស្សឬអ្វីៗដែលត្រូវសម្ដែងសេចក្ដីគោរពទៅរក : ហែនាគ, ហែសព, ហែព្រះពុទ្ធរូប, ហែកឋិន។

ន. ការដើរចោមរោមជារបៀប : ក្បួនហែ, ទៅមើលហែ។

២). កិ. (រ.ស.) ជូនឬតាមជូនជាយសបរិវារ; ទៅឬមកកំដរជាគ្នា : ហែព្រះករុណាឬហែហ្លួង; ហែព្រះអង្គម្ចាស់។

៣). កិ. ដើរបណ្ដោយគ្នាជាជួរ : ដើរហែៗតាមគ្នា (ដើរដង្ហែគ្នា)។

ហែតុការន៍ ☒ ហេតុការណ៍ ☑

ហេតុការណ៍

[ហែត-កា] (បា.)

ន. រឿងរ៉ាវដែលកើតឡើងដោយហេតុផ្សេងៗ មានដូចជាចោរប្លន់ឬកាប់សម្លាប់គ្នា, ភ្លើងឆេះផ្ទះ, គ្រោះថ្នាក់ចរាចរណ៍ជាដើម។

ហោប៉ាវ ☒ ហោប៉ៅ ☑

ហោប៉ៅ [ហោ-ប៉ៅ] (ស.)

ន. ថង់ដេរភ្ជាប់នឹងអាវឬខោជាដើម : ហោប៉ៅអាវ, ហោប៉ៅខ្សែក្រវាត់ស្បែក (ហៅកាប៉ៅក៏បាន)។

# ពាក្យផ្ដើមដោយ

# អ

| | |
|---|---|
| អគុណ ☒ | អរគុណ ☑ |

អរគុណ

[អ-គុន]

កិ. អរចំពោះគុណគេ, មានអំណរគុណគេ : ដោយគេបានជួយសង្គ្រោះខ្ញុំបន្តិចប៉ុណ្ណឹង ខ្ញុំនឹកអរគុណគេមិនភ្លេច។

| | |
|---|---|
| អគ្គីសនី ☒ | អគ្គិសនី ☑ |

អគ្គិសនី

អ័ក-គិ-សៈ-នី] (បា. សំ., បា.អគ្គិ "ភ្លើង" + អសនិ "រន្ទះ" > អគ្យសនិ ឬ អគ្គិសនី "ភ្លើងរន្ទះ; ភ្លើងមេឃ")

១). ន. ភ្លើងអេឡិចទ្រិក (ពាក្យសន្មតប្រើតាមសម័យនិយម)។

២). (រូប.) វត្ថុមាននិងលំហូរនៃបន្ទុកអគ្គិសនី។

អង្កុញ ☒ អង្គញ់ ☑

អង្គញ់ ១

[អង់-គញ់]

ន. ឈ្មោះវល្លិមួយប្រភេទ ដើមធំរឹង ផ្លែធំវែងៗក្នុងផ្លែមួយៗ មានគ្រាប់ច្រើន គ្រាប់ធំៗរាងមូលសំប៉ែត កាលណាទុំមានសាច់រឹង , សម្រាប់យកមកលេងល្បែងមួយប្រភេទ ហៅថា ល្បែងអង្គញ់។

អង្គញ់ ២

[អង់-គញ់]

ន. ឆ្អឹងមានសណ្ឋានដូចគ្រាប់អង្គញ់ នៅត្រង់ក្បាលជង្គង់ : អង្គញ់ជង្គង់។

អណាធិបតេយ្យ ☒ អាណាធិបតេយ្យ ☑

អនាធិបតេយ្យ

[អៈ-ណា-ធិ-ប៉ៈ-តៃ] (បា. < អន៑ + អាធិបតេយ្យ)

ន. ការដែលគ្មានអាធិបតេយ្យ, គ្មានឥស្សរភាព, ដំណើរផុតសិទ្ធិសេរីភាពក្នុងការគ្រប់គ្រង, ភាពនៃប្រជារាស្ត្រដែលមិនមានមគ្គុទ្ទេសក៍ : ប្រទេសដែលឋិតនៅក្នុងអនាធិបតេយ្យ មិនអាចញ៉ាំងសេចក្ដីចម្រើនឱ្យកើតបានឡើយ។

អណែក ☒ អនេក ☑

អនេក

[អៈ-ណែក] ឬ [អៈ-ណែ-កៈ] (សំ.បា. < អន៑ "មិន, ពុំ, ឥត" + ឯក "មួយ")

គុ. មិនមែនតែមួយ គឺច្រើនដែលរាប់ពុំបាន, ប្រមាណពុំអស់ : ច្រើនអនេក ច្រើនក្រៃ។

| | |
|---|---|
| អត្តនោម័ត ☒ | អត្តនោម័តិ ☑ |

អត្តនោម័តិ

[អ័ត-តៈ-ណោ-ម៉ាត់] (បា. អត្តនោ "នៃខ្លួន" + មតិ "គំនិត, ការយល់ឃើញ")

ន. គំនិតនៃខ្លួន; ការយល់ឃើញដោយគំនិតរបស់ខ្លួន : និយាយតាមអត្តនោម័តិ, សេចក្ដីនេះជាអត្តនោម័តិ។

| | |
|---|---|
| អត់អោន ☒ | អត់ឱន ☑ |

អត់ឱន

[អត់-អោន]

កិ. បន្ទន់ចិត្តអត់ទ្រាំ; ខំទ្រាំអត់ មិនប្រកាន់ទោស : (ព.កា.) អត់ឱនឥតទោស ធ្វើចិត្តសន្តោស បង្កើតជាទ្រព្យ មេត្រីជាញាតិ រក្សាដល់ស្លាប់ ចៀសក្តីពុំគាប់ ជាគន្ធពិដោរ។ (សាស្ត្រាច្បាប់ រាជនេតិ ជាព្រះនិពន្ធនៃព្រះរាជសម្ភារ)។

ឧទ្ធម្ភាគច ☒ ឧទ្ធម្ភាចក្រ ☑

ឧទ្ធម្ភាគចក្រ

[អ៊ុត-ធ័ម-ភា-គៈ-ច័ក]

ន. យន្តហោះមួយប្រភេទដែលគ្មានស្លាប តែមានកង្ហារមួយឬពីរវិលនៅពីលើ។ វាអាចហោះឡើងត្រង់ឬសំកាំងនៅលើអាកាសបាន : ឧទ្ធម្ភាគចក្របានដឹកជនរងគ្រោះដោយសារទឹកជំនន់។

អធឹកអធម ☒ អធិកអធម ☑

អធិកអធម

[អៈ-ធិក-អៈ-ធំ] (សំ.បា. អធិក "ក្រៃលែង, លើសលែង, លើសលន់, រុងរឿង, ហ៊ឹកហ៊ាក់" + អធម "ថយថោក, ថោកទាប; មិនរុងរឿង, រម៉េះរម៉ោះ, រប៉ិចរប៉ី, រាយរង, បន្ទាប់បន្ទំ ...)

ន. ខ្មែរប្រើពាក្យនេះចំពោះតែពិធីបុណ្យឬពិធីអ្វីមួយដែលរុងរឿងផង រម៉េះរម៉ោះឬរប៉ិចរប៉ីរាយរងខ្លះផង : ធ្វើបុណ្យសីមាអធិកអធម៧យប់ គម្រប់៧ថ្ងៃ គឺធ្វើបុណ្យសីមានោះ មានរបៀបរៀបចំរុងរឿងហ៊ឹកហ៊ាក់ផង មានល្បែងរបាំរម៉េះរម៉ោះនិងការលក់ដូរចេកអំពៅនំចំណីជាដើម រប៉ិចរប៉ី រាយរង ពេញពាសនៅទីជិតៗនោះផង; បើមិនមានលក្ខណៈដូច្នោះទេ ពុំគួរហៅថា អធិកអធម ឡើយ; (ព.កា.) គេធ្វើបុណ្យសព មានអ្វីទាំងគ្រប់ អធិកអធម ទាំងថ្លៃទាំងថោក តាមគេនិយម អ្នកតូចអ្នកធំ ឈូឆរតាមពេល។ (ប្រយ័ត្នកុំអាន, កុំនិយាយច្រឡំថា អធិកអធ័ម។ ម.ព. អធិកនិងអធម)។

អធ្យាស្រៃ ☒ អធ្យាស្រ័យ ☑

អធ្យាស្រ័យ

[អ័ត-ធ្យា-ស្រៃ] (សំ. អធ្យាគយ)

ន. ដូចគ្នានឹង អជ្ឈាស័យ ដែរ (ម.ព. អជ្ឈាស័យ)។

អនាគត់ ☒ អនាគត ☑

អនាគត

[អៈ-ណា-គត់] (សំ.បា. < អនិ "មិន, មិនទាន់" + អាគត "មក" = កាលដែលមិនទាន់មក)

គុ. ដែលនៅឯមុខ : ប្រយោជន៍អនាគត, ជាតិអនាគត។

ន. កាលឬសម័យខាងមុខ : ប្រយោជន៍ក្នុងអនាគត; យើងពុំអាចដឹងអនាគតរបស់យើងទេ។ (ព.វ. កាលប្រាប់ដំណើរទៅខាងមុខ; ខ្មែរប្រើពាក្យ នឹង, គង់, គង់នឹង, គង់តែ, គង់តែនឹង, មុខជា, មុខជានឹង ជាគ្រឿងសម្គាល់។ ស្អែកខ្ញុំនឹងទៅ, ការនុះមុខជានឹងសម្រេច សព្ទជា កិរិយា កាលណាបើប្រើពាក្យ នឹង, គង់, មុខជា ...នេះរៀងបន្ទាប់ពីខាងដើម សម្គាល់សេចក្ដីថាជា អនាគតកាល)។

| | |
|---|---|
| អនុញ្ញាតិ ☒ | អនុញ្ញាត ☑ |

អនុញ្ញាត

[អៈ-នុញ-ញ៉ាត]

កិ., គុ. យល់ព្រម, បើកឱកាសឱ្យ; ដែលបានយល់ព្រមហើយ : រដ្ឋាភិបាលបានអនុញ្ញាតឱ្យធ្វើការនោះហើយ។

ន. ការយល់ព្រម, ការបើកឱកាសឱ្យ : មានអនុញ្ញាតឱ្យធ្វើហើយ។ (គួរប្រយ័ត្ន កុំច្រឡំសរសេរជា អនុញ្ញាតិ ព្រោះគ្មានពាក្យនេះទេ)។

(ប.ព.) ការផ្ដល់សិទ្ធិដល់បុគ្គលឬស្ថាប័នដើម្បីប្រើប្រាស់ប្រព័ន្ធទិន្នន័យឬធនធាននៅលើបណ្ដាញ។

អនេកកប្បការ ☒ អនេកប្បការ ☑

អនេកប្បការ

[អៈ-ណេ-ក័ប-ប៉ៈ-កា]

ន., គុ. ការច្រើន; ដែលមានប្រការច្រើន។

អនេកអន័គ្ឃ ☒ អនេកអនគ្ឃ ☑

អនេកអន័គ្ឃ

[អៈ-ណេក-អៈ-ណាក់]

គុ. ដែលច្រើនណាស់កាត់ថ្លៃពុំបាន។

អន្ទឹតអន្ទក់ ☒ អណ្ដឹតអណ្ដក ☑

អណ្ដឹតអណ្ដក

[អន់-ដឹត-អន់-ដក]

គុ.កិ. អំពីអាការៈយំខ្សឹកខ្សួលខ្សេតខ្សូតៗប៉ផ្ដឹតប៉ផ្ដក់រឿយៗ : យំអណ្ដឹតអណ្ដក។

ឥន្ទ្រនិមិត្ត ☒ ឥន្ទនិម្មិត ☑

ឥន្ទនិម្មិត

[អិន-ទៈ-និម-មិត]

ន.រូបដែលព្រះឥន្ទ្រនិម្មិត។

អន្លង់អន្លោច ☒ លន្លង់លន្លោច ☑

លន្លង់

[លន់-លង់]

គុ. ដែលស្រងេះស្រងោច ព្រោះឃើញវាលធំធេងឆ្ងាយសន្លឹមឬឃើញទីប្លែកចិត្ត : ចិត្តលន្លង់លន្លោច។

គុ.កិ. ឆ្ងាយសន្លឹមស្រងាត់ : ឆ្ងាយលន្លង់។

ប. ច្រើននិយាយផ្សំនឹងពាក្យ លន្លោច ថា : លន្លង់លន្លោច លន្លង់គួរឱ្យលន្លោចចិត្ត។ (ព.កា. ប្រើជា លន្លោចលន្លង់ ក៏បាន)។

ឧបស័គ្គ ☒ ឧបសគ្គ ☑

ឧបសគ្គ១

[អ៊ុ-ប៉ៈ-ស័ក] (បា. ឧបសគ្គ; សំ. ឧបសគ៌)

ន. ឧបទ្រព, ចង្រៃ; គ្រឿងទើសទាក់, គ្រឿងជំទាស់, គ្រឿងរារាំងដំណើរ : ពីម្សិលមិញ ខ្ញុំមកមិនរួច ព្រោះមានឧបសគ្គ។ (ព.កា.) ឧបសគ្គជាថ្នាក់នាំជំទាស់ រារាំងឱ្យងាស់ស្មោកកិច្ចការ ទោះជនកំពុងកាន់ធម៌អាថ៌ អាចារ្យក៏ដោយដូចជាគ្នា។

ឧបសគ្គ២

[អ៊ុ-ប៉ៈ-ស័ក]

ន. (ពវ.) ឈ្មោះសព្ទពួកមួយ សម្រាប់ប្រើចំពោះតែជាបុព្វបទរៀងភ្ជាប់ពីខាងដើមនាមសព្ទនិងកិរិយាសព្ទតាមគួរដល់ការប្រកប, ដូចជា អតិ, អនុ, អភិ ជាដើម : អតិកល្យាណ, អតិជាតបុត្ត; អនុគ្រោះ, អនុជ, អនុជាតបុត្ត; អភិរោធ, អភិវន្ទ, អភិវាទ។ល។ (ម.ព. បុព្វបទ)។

| | |
|---|---|
| អផ្សុខ ☒ | អផ្សុក ☑ |

អផ្សុក

[អប់-សុក] ឬ [អៈ-ផ្សុក] (បា. អផាសុក ន."សេចក្ដីមិនសប្បាយ; សេចក្ដីព្រួយចិត្ត")

១). កិ., គុ. មិនសប្បាយចិត្ត, ព្រួយចិត្ត, ខ្វល់ចិត្ត; ធុញទ្រាន់នៅមិនសុខ : ខ្ញុំចេះតែអផ្សុក; ភិក្ខុអផ្សុកចង់សឹក; កុំលេងច្រើនពេកអផ្សុកណាស់!

២). កិ. (ស.ស.) មានជំងឺ, ឈឺ : មានលោកភិក្ខុមួយរូបអផ្សុកធ្ងន់ណាស់ ដាច់ចង្ហាន់ពីរបីថ្ងៃហើយ។

អម្បាញមិញ ☒ អម្បាញ់មិញ ☑

អម្បាញ់មិញ

[អំ-បាញ់-មិញ]

គុ.កិ. មួយរំពេចមុននេះ, ភ្លាមៗមុននេះ : គេទើបនឹងចេញទៅអម្បាញ់មិញ (ព.សា. អំមិញឬអំម៉េញ)។

អម្បាលមាណ ☒ អម្បាលម៉ាន ☑

អម្បាលម៉ាន

[អំ-បាល-ម៉ាន]

គុ.កិ. ប៉ុន្មាន, ម្ល៉ា, យ៉ាងណា : ល្អអម្បាលម៉ានទៅ?; ធំអម្បាលម៉ានក៏ដោយ!

អវយវ ☒ អវៈយវៈ ☑

អវយវៈ

[អៈ-វ៉ៈ-យៈ-វៈ] (សំ.បា. អវយវ)

ន. អង្គ, រូបអង្គ, រូបរាង, សព៌ាង្គ, រាងកាយ, ខ្លួនប្រាណ; ចំណែក; ប៉ែកឬចំណែកតូចធំនៃរូបកាយ : អវយវៈតូចធំ សព៌ាង្គកាយមានដៃជើងជាដើម។ (ព.កា. ប្រើជា អពយពឬអព្យព ក៏បាន)។

| | |
|---|---|
| អវសាន្ត ☒ | អវសាន ☑ |

អវសាន

[អៈ-វៈ-សាន] (សំ.; បា. ឱសាន)

ន. ទីបំផុត; ទីចប់; ចុងបំផុត, ចុងក្រោយ; ព្រំដែន; ខេត្ត : ក្នុងអវសាននៃកថានេះ ខ្ញុំសូមជូនពរដល់អស់លោក-អ្នក ...។

| | |
|---|---|
| អសាបង់ ☒ | អសារបង់ ☑ |

អសារ

[អៈ-សា] (សំ.បា.)

គុ., គុ.កិ. ដែលឥតខ្លឹម; ឥតប្រយោជន៍, ឥតអំពើ; ដែលមិនកើតការឬមិនបានការ; ដែលមិនខ្ជាប់ខ្ជួន, មិនរឹងប៉ឹង; ដែលគ្មានតម្លៃ; ដែលមិនពិត, ពុំប្រាកដ; ...(ច្រើនប្រើផ្សំជាមួយនឹងពាក្យ ឥតការ) : សម្ដីអសារឥតការ, របស់អសារឥតការ។ (ព.ផ្ទ. សារឬសារៈ)។

អ៊ីនធីណេត ☒ អ៊ីនធីណិត ☑

អ៊ីនធីណិត

[អ៊ីន-ធី-ណិត] (អ. internet)

ន. (ប.ព.) បណ្ដាញកុំព្យូទ័រពិភពលោក ដែលអាចឱ្យមនុស្សចែករំលែកព័ត៌មាននិងទាក់ទងគ្នាទៅវិញទៅមក។

អ៊ូរអរ ☒ អ៊ូអរ ☑

អ៊ូអរ

[អ៊ូ-អ]

គុ.កិ. ឈូឆរដោយមានអំណរ, ដោយស្រុះស្រួល : បងប្អូនមកចួបជុំអ៊ូអរពេញផ្ទះ។

អាការៈ ☒ អាការ ☑

អាការ១

[អា-កា-រ៉ៈ] ឬ [អា-កា] (សំ.បា.)

ន. គ្រឿងសម្គាល់, លក្ខណៈជាគ្រឿងសម្គាល់, ជាគ្រឿងសង្កេត; រូបរាង, ទ្រង់ទ្រាយ; ភិនភេទ, ភិនភាគ; វិធី, បែបបទ, បែបភាព, លំនាំ; ទំនង; ឫកពា, កិរិយា; សភាព; គុណសម្បត្តិ : អាការរោគ, ចេញអាការឱ្យដឹងថាល្អឬអាក្រក់។

អាការ២

[អា-កា-រ៉ៈ] ឬ [អា-កា]

ន. ចំណែកឬអវយវៈតូចធំរបស់រូបកាយ : បព្វជិតគួរពិចារណាអាការ៣២ មានសក់, រោម, ក្រចក, ធ្មេញ, ស្បែកជាដើម ឱ្យឃើញជាក់ច្បាស់ថាជាបដិកូល។

អាជីវក ☒ អាជីវករ ☑

អាជីវករ

[អា-ជី-វៈ-ក]

ន. ជនអ្នកប្រកបអាជីវកម្ម : អាជីវករនៅផ្សារ។

អាញ់ ☒ អញ ☑

អញ

[អាញ់]

១). សព្វ. ខ្ញុំ (ជាអញ្ញត្រសព្ទ)។ ពាក្យសម្រាប់ហៅខ្លួនឯង ជាសម្ដីកូនក្មេង និយាយទៅរកកូនក្មេងផងគ្នា ឬមនុស្សចាស់ និយាយទៅរកកូនក្មេង, និយាយទៅរកមនុស្សស្មើភាពដែល ស្និទ្ធស្នាល ឬក៏អ្នកធំនិយាយទៅរកអ្នកតូចដោយស្និទ្ធស្នាល : ឯង ទៅចុះ អញមិនទាន់ទៅទេ!

២). ខ្មែរបុរាណព្រេងនាយប្រើជាពាក្យខ្ពស់, មានពាក្យក្នុងសិលាចារឹកថា វ្រះកម្រតាងអញ (វ្រះ-ក័ម-ម្រ៉ៈ-តាង-អាញ់) គឺ ព្រះតេជព្រះគុណរបស់ខ្ញុំ ឬលោកអ្នកធំរបស់ខ្ញុំ : អញខ្ញុំ; អញខ្ញុំព្រះអង្គ; អញខ្ញុំម្ចាស់ ខ្ញុំ; ខ្ញុំព្រះអង្គ; ខ្ញុំម្ចាស់។ (ព. បុ. ប្រើតែក្នុងសម័យព្រេងនាយ។ អញឯង គឺខ្ញុំឯង)។

អាញ្រាត្រ ☒ អញ្រាត្រ ☑

អទ្រាត្រ

[អ័ត-ទ្រាត] (សំ.ក្ល.)

ន. ពាក្យប្រើក្លាយមកពី សំ. អធិរាត្រិឬរាត្រ "ពាក់កណ្ដាលយប់"; បា. អឌ្ឍរត្តឬអឌ្ឍរត្តិ : ធ្វើការយប់តាំងពីព្រលប់ដល់អទ្រាត្រ។ (ព. កា.) លង់លុះអទ្រាត្រ ហៅឆន្ទអមាត្យ មកគិតនៃបាន ព្រះស្ដែង យកសេះ កម្លាំងហៅហាន ចងគ្រឿងនូវអាន នាំមកថ្វាយថ្វាត់។ កាព្យបទផ្កាញ៉ូមារបុរាណ។

| | |
|---|---|
| អាព្រិច ☒ | អាព្រិក ☑ |

អាហ្វ្រិក

[អា-ព្រិច] (បារ. Afrique, អ. Africa)

១). ន. (ភូមិ.) ឈ្មោះទ្វីបមួយក្នុងចំណោមទ្វីបទាំង៦ក្នុងពិភពលោក : ទ្វីបអាហ្វ្រិក, ប្រទេសអាហ្វ្រិក។ (សរសេរជា អហ្វ្រិកឬ អហ្វ្រិគ ក៏មាន)។

២). ជាតិមនុស្សអ្នកមានពូជកំណើតនៅក្នុងទ្វីបអាហ្វ្រិក។ (ម.ព. ទ្វីប ផង)។

| | |
|---|---|
| អាមេរិក ☒ | អាម៉េរិក ☑ |

អាម៉េរិក

[អា-ម៉េ-រិច] (បារ. Amérique, អ. America)

១). ន. (ភូមិ.) ឈ្មោះទ្វីបមួយក្នុងមនុស្សលោក នៅក្នុងចន្លោះលំហនៃមហាសមុទ្រអាត្លង់ទិកនិងមហាសមុទ្រប៉ាស៊ីហ្វិក (រាប់ចូលក្នុងចំនួនមហាទ្វីបទាំង៥) : ភូមិភាគនៃទ្វីបអាម៉េរិក ចែកក្នុងភូមិសាស្ត្រជា៣ភាគគឺ អាម៉េរិកខាងជើង, អាម៉េរិកកណ្ដាល, អាម៉េរិកខាងត្បូង។ (ម.ព. មហាទ្វីប ផង)។

២). ជាតិមនុស្សអ្នកមានពូជកំណើតនៅក្នុងទ្វីបអាម៉េរិកនោះ។

| | |
|---|---|
| អារម្ម ☒ | អារម្មណ៍ ☑ |

អារម្មណ៍

[អា-រ៉ម់] (បា. អារម្មណ; សំ. អារម្ពណ ឬ អាលម្ពន)

១). ន. គ្រឿងតោង; គ្រឿងព្យួរ; គ្រឿងទាញឬទាញទាក់; គ្រឿងតោងរបស់ចិត្ត; គំនិត; ការដឹង; ...។ ដែលប្រើដោយច្រើន, សំដៅត្រង់ គ្រឿងតោងរបស់ចិត្ត មាន៦ប្រភេទ គឺ រូបារម្មណ៍ (សម្រាប់ភ្នែក), សទ្ទារម្មណ៍ (សម្រាប់ត្រចៀក), គន្ធារម្មណ៍ (សម្រាប់ច្រមុះ), រសារម្មណ៍ (សម្រាប់អណ្ដាត), ផោដ្ឋព្វារម្មណ៍ (សម្រាប់សព៌ាង្គកាយ លើកអាយតនៈ៥ចេញ), ធម្មារម្មណ៍ (សម្រាប់ចិត្តសុទ្ធ) : អារម្មណ៍ល្អ, អារម្មណ៍មិនល្អ, អារម្មណ៍មិនទៀង។ (ម.ព. អាយតនៈ ផង)។

២). សំដៅត្រង់ គំនិតនិងការដឹង, ដូចជា កៀងអារម្មណ៍ កៀងប្រមូលគំនិតមិនឱ្យទាសរសេមរសាម។

អារុណ ☒ អរុណ ☑

អរុណ

[អ-ៈរុន] (សំ.បា.)

ន. ព្រះអាទិត្យដែលទើបភ្លឺច្រាលពីទិសបូព៌, ពេលក្រហមឯកើត, ពេលព្រឹកព្រាង : អរុណរះ, អរុណស, អរុណក្រហម។

អាស័យដ្ឋាន ☒ អាសយដ្ឋាន ☑

អាសយដ្ឋាន

[អា-សៈ-យ៉ាត់-ឋាន] (បា.)

ន. ទីសម្រាប់នៅអាស្រ័យ, លំនៅនៃជនណាមួយ; ទីនៅអាស្រ័យដែលគេសរសេរកាខ្នងស្រោមសំបុត្រផ្ញើទៅឱ្យបុគ្គលណាមួយ : សូមសរសេរកាខ្នងស្រោមសំបុត្រ តាមអាសយដ្ឋានរបស់ខ្ញុំដូច្នេះ...។

អាហាររូបត្ថម្ភ ☒ អាហារូបត្ថម្ភ ☑

អាហារូបត្ថម្ភ

[អា-ហា-រូ-ប័ត-ថ័ម]

ន. ការជួយទំនុកបម្រុងដោយអាហារ; ការចិញ្ចឹមជីវិត ដោយអាហារ។ល។ដំណើរការនៃការផ្តល់ឬការទទួលបាននូវ អាហារចាំបាច់សម្រាប់សុខភាពនិងការលូតលាស់។

អុច ☒ អុជ ☑

អុជ

[អុច] (បា. ឧជ្ជល; សំ. ឧជ្វល "ឆេះទ្រលោម ភ្លឺរុងរឿង, ភ្លឺ សន្ធោ, ភ្លឺសន្ធោសន្ធៅ", ខ្មែរលុបជើង ជ ឬ ជើង វ និងតួ ល ទុក ត្រឹមតែ ឧជ ប្រើជា អុជ)

១). កិ. ដុតឱ្យឆេះមានអណ្ដាតភ្លើងឡើង : អុជចង្កៀង។ (ធ្លាប់សរសេរជា អុច មកយូរហើយ ប្រើតាមទម្លាប់នោះក៏បាន)។

២). ដុតមិនមានអណ្ដាតភ្លើង : អុជបីប៉ុយឬអុជបីរណ្ដៅ ដាក់ប៉ុយទន្សែជាដើមលើស្បែក (មនុស្ស) បីអន្លើ, ត្រង់កន្លែងដែលត្រូវដាក់ ហើយដុតឱ្យឆេះប៉ុយទាំងបីនោះ ដើម្បីឱ្យជារោគសរសៃ (តាមទម្លាប់ខ្មែរខ្លះដែលធ្លាប់ប្រើ)។

៣). (ព.ប្រ.) ញុះឬញុះញង់ឱ្យក្ដៅចិត្ត : អុជឱ្យឈ្លោះគ្នា (និយាយថា ដុត ក៏បាន)។

| | |
|---|---|
| អូយម៉ូញ ☒ | អូយម៉ូយ ☑ |

អូយម៉ូយ

[អូយ-ម៉ូយ]

ន. (ម.ព. អូញម៉ូញ)។

អំពល់ទុក ☒ អំពល់ទុក្ខ ☑

អំពល់ទុក្ខ

[អំ-ពល់-ទុក]

កិ. មានទុក្ខ។

អំពើរ ☒ អំពើ ☑

អំពើ១

[អំ-ពើ]

ន. ការដែលធ្វើ, អ្វីៗដែលត្រូវធ្វើ (កម្ម) : អំពើល្អ, អំពើអាក្រក់។

អំពើ២

[អំ-ពើ]

ន. កម្មអាក្រក់ឬកិច្ចកលលាមក ដែលធ្វើអ្នកដទៃឱ្យឈឺចាប់ដោយមន្តអាគមជាដើម : ត្រូវអំពើគេ, ដោះអំពើ។ (ម.ព. អំពាន់ ផង)។

# ពាក្យផ្ដើមដោយស្រះពេញតួ

# ឥ

ឥរិយាបទ ☒ ឥរិយាបថ ☑

ឥរិយាបថ

[អិ-រិ-យ៉ា-បត់] (បា.; សំ. ឦរ្យាបថ)

ន. ផ្លូវឬគន្លងនៃឥរិយា គឺការដើរ, ឈរ, អង្គុយ, ដេក : (ព. កា. ឱ្យរក្សាឥរិយាបថទាំងបួន) ឥរិយាបថបួន គួរជនប្រុងខ្លួន តាមសុជីវធម៌ ត្រឹមត្រូវទៀងទាត់ បែបបទបវរ នឹងមានអំណរ មិននឹកស្តាយក្រោយ។ (ម.ព. ឥរិយា ផង)។

ឥលូវ ☒ ឥឡូវ ☑

ឥឡូវ

[អី-ឡូវ] ឬ [អិ-ឡូវ]

គុ.កិ. សព្ទប្រាប់សេចក្ដីជាបច្ចុប្បន្នកាលថា "កាលនេះ, វេលានេះ" : ទៅឥឡូវ ទៅក្នុងវេលានេះ។ (បុរាណសរសេរ ឥលូវ ប៉ុន្តែលើកលែងប្រើយូរហើយ)។

# ពាក្យផ្ដើមដោយស្រៈពេញតួ

# ឯ

| | |
|---|---|
| ឯកការ ☒ | ឯកា ☑ |

ឯកា

[អែ-កា]

គុ. (ម.ព. ឯក)។

| | |
|---|---|
| ឯករាជ ☒ | ឯករាជ្យ ☑ |

ឯករាជ្យ

[អែ-កៈ-រាច]

ន. រាជ្យឯក, រាជ្យនៃស្ដេចឯក; ភាពនៃរដ្ឋឬប្រទេសដែលមានសិទ្ធិនិងសេរីភាពពេញបរិបូរ ក្នុងការគ្រប់គ្រងខ្លួនឯងមិនមែនជាចំណុះនៃប្រទេសដទៃ : គ្រប់គ្រងឯករាជ្យ, ការពារឯករាជ្យ។

ឯកសា ☒ ឯកសារ ☑

ឯកសារ

[អែ-កៈ-សា]

១). គុ. ដែលសុទ្ធតែខ្លឹម; ដែលមានខ្លឹមដូចគ្នា (បុរាណប្រើសំដៅសេចក្ដីថា "សំបុត្រសន្យាសម្លាក់សំខាន់" ក៏មាន : សំបុត្រឯកសារ។

ន. ទម្រង់ឬអត្ថបទជាលាយលក្ខណ៍អក្សរ, បោះពុម្ពឬអេឡិចត្រូនិក ដែលផ្ដល់ព័ត៌មានឬភស្តុតាង ឬក៏សម្រាប់ប្រើប្រាស់ជាកំណត់ត្រាផ្លូវការ។

ន. (ប.ព.) ព័ត៌មាន កម្មវិធី សំណុំទិន្នន័យមានឈ្មោះកំណត់មួយដែលរក្សាទុកក្នុងថាសឬឧបករណ៍ផ្ទុកទិន្នន័យផ្សេងៗរបស់កុំព្យូទ័រ។

អែង ☒ ឯង ☑

ឯង១

[អែង]

សព្វ. អ្នក។ ពាក្យសម្រាប់ហៅ មនុស្សក្មេងជាងឬតូចទាបជាង ក្នុងទីចំពោះមុខ : ឯងទៅណា?; ឯងទាំងអស់គ្នា កុំអាលទៅណា!

ឯង២

[អែង]

គុ. ដែលជារបស់ខ្លួន : របស់ឯង, គ្នាឯង។

គុ.កិ. ផ្ទាល់ខ្លួន, លើខ្លួន, ពីខ្លួន, ចំពោះខ្លួន, ពីទំនើងខ្លួន : ខ្លួនឯង, ឯកឯង, ម្នាក់ឯង។

ឯង៣

[អែង]

គុ.កិ. ស្រាប់, ស្រេចស្រាប់; តាមសញ្ជាតិ, តាមធម្មតា; ដែលមិនបាច់ធ្វើ, មិនបាច់ទិញជាដើម : ត្រពាំងកើតឯង, ឈើដុះឯង, របស់បានឯង, ចេះឯង; ការនុះវាឯងៗទេ!

ឯង៤

[អែង]

គុ.កិ. មែន, ពិត, មែនពិត; គត់; ហោង : ដូច្នោះឯង, នុ៎ះឯង; តែប៉ុណ្ណោះឯង។

# ពាក្យផ្ដើមដោយស្រៈពេញតួ

# ឱ

ឱ៉ឡា ☒ ឱឡា ☑

ឱឡា

[អោ-ឡ៉ា]

ន. (ម.ព. ឧឡា)។

ឱវាត ☒ ឱវាទ ☑

ឱវាទ

[អោ-វ៉ាត] (បា. អវ > ឱ; សំ. អវវាទ)

ន. ដំបូន្មាន, អនុសាសន៍ : ឱ្យឱវាទ, ស្ដាប់ឱវាទ។

ឱឡារឹក ☒ ឱឡារិក ☑

ឱឡារិក១

[អោ-ឡា-រិក] (បា.; សំ. ឱឡារិក)

គុ. គ្រោតៗ, គ្រោតគ្រាត; ច្បាស់លាស់។ (ព.ផ្ទ. សុខុម)។

ឱឡារិក២

[អោ-ឡា-រិក]

គុ. ធំដុំ, យ៉ាងធំ, ហ៊ឹកហ៊ាក់ : ធ្វើបុណ្យខណ្ឌសីមាដ៏ឱឡារិកអធិកអធម។

អោយ/ឱយ/ឲ្យ ☒ ឱ្យ ☑

ឱ្យ

[អោយ]

(អញ្ញត្រសព្ទ ដោយអនុវត្តតាមការពិភាក្សាហើយសម្រេចនៃគណៈកម្មការរៀបរៀងវចនានុក្រមខ្មែរគ្រាដំបូងបំផុតក្នុងកាល ព.ស.២៤៥៩ គ.ស.១៩១៥ ថាត្រូវប្រើជា ឱ្យ យ៉ាងនេះមិនយល់ព្រមឱ្យប្រើជា ឱយឬអោយ ឡើយ) : ឱ្យប្រាក់, ឱ្យស្បៀង, ឱ្យទ្រព្យរបស់, ឱ្យគ្រឿងស្លៀកពាក់។ (ម.ព. ឧកនិងឪ ផង)។

កិ. ធ្វើអំណោយ គឺលះអ្វីៗដល់អ្នកដទៃ : ឱ្យប្រាក់, ឱ្យស្បៀង, ឱ្យទ្រព្យរបស់, ឱ្យគ្រឿងស្លៀកពាក់។ (ម.ព. ឧកនិងឪ ផង)។

ឱ្យ២

[អោយ]

កិ. ប្រើ, បង្គាប់, ញ៉ាំង : ឱ្យធ្វើ, ឱ្យរៀន, ឱ្យទៅ, ឱ្យមក។

| | |
|---|---|
| ១. កាំបិតតាំងតោ | កាំបិតប៉័ងតោ |
| ២. ដថ្វី | ដងី |
| ៣. តោះទៅរៀន | តស់ទៅរៀន |
| ៤. ប៊ិច | ប៊ិក |
| ៥. បទពិសោធន៍ | បទពិសោធ |
| ៦. ប៉ូលីស | ប៉ូលិស |
| ៧. ប្រឌិត | ប្រតិដ្ឋ |
| ៨. ផាសុខភាព | ផាសុកភាព |
| ៩. មិនា | មីនា |
| ១០.សម្រាម | សំរាម |
| ១១.អញ្ចឹង | អ៊ីចឹង |
| ១២.អោយ | ឱ្យ |
| ១៣.ឥវ៉ាន់ | អីវ៉ាន់ |

ចូលរួមគាំទ្រ និងលើកស្ទួយអក្សរសាស្ត្រជាតិ

9 789924 973829 >

ចងក្រងដោយ ខន ស៊ាងហោ ពាក្យខុស ពាក្យត្រូវខ្មែរ ព.ស. ២៥៦៨ គ.ស. ២០២៥